# ឧបករណ៍ទំនាក់ទំនង ផ្លាស់ប្តូរឥរិយាបថ

ការទទួលបានសិទ្ធិស្ត្រី
ការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី
អំពើហិង្សាទាក់ទងនឹងយេនឌ័រ



# ខែមករា ឆ្នាំ២០២៤

| | |
|---|---|
| រក្សាសិទ្ធិដោយៈ | អង្គការយែរកម្ពុជា |
| សរសេរដោយៈ | អាសា ខាន់ អ្នកសម្របសម្រួលក្រុមយេនឌ័ររបស់អង្គការយែរ<br>ផេតសាខន សំផុងបុតថាកាញ់ សមាជិកក្រុមយេនឌ័ររបស់អង្គការយែរ |
| សរសេរដោយៈ | លោកស្រី ជួន ដារីត ជាប្រធានគម្រោងសកម្មភាពស្ត្រីនិយមរបស់អង្គការយែរ<br>លោកស្រី ហ៊ុន ស៊ីនួន ជាទីប្រឹក្សាបច្ចេកទេសយេនឌ័រ របស់អង្គការយែរ |
| ត្រួតពិនិត្យដោយៈ | កញ្ញា មាស សុភារក្ស ជានាយកកម្មវិធីរបស់អង្គការយែរ<br>លោក ភឿន សុខចាន់ ជាប្រធានកម្មវិធីជាន់ខ្ពស់របស់អង្គការយែរ |
| ក្រោមការប្រឹក្សាបច្ចេកទេសជាមួយៈ | អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី (ជ.ច.ក.ស)<br>មីក្រូឥន្ទធនូកម្ពុជា<br>ក្រុមសន្សំប្រាក់នារី<br>អង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់ (កដទ)<br>អង្គការបន្ទាយស្រី<br>អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ |

ឯកសារនេះត្រូវបានបោះពុម្ពផ្សាយច្បាប់ដើមជាភាសាអង់គ្លេស ហើយបកប្រែមកជាភាសាខ្មែរ

បកប្រែដោយៈ កញ្ញា មុឺន សុខចាន់ដាលី
លោកស្រី ជួន ដារីត

ត្រួតពិនិត្យដោយៈ លោកស្រី នៅ សុវត្ថា
កញ្ញា ឱប ណាសា

កែសម្រួលឯកសារដោយៈ កញ្ញា ជា ស៊ីនួ

រចនារូបភាពខាងក្នុងដោយៈ កញ្ញា គន្ធ មណីរ័ត្ន

AFD AGENCE FRANÇAISE DE DÉVELOPPEMENT

care

MICRO RAINBOW INTERNATIONAL FOUNDATION

BANTEAY SREI

# មាតិកា


សារទៅកាន់អ្នកប្រើប្រាស់កញ្ចប់ឯកសារ........................................................................................ ១

**ផ្នែកទី១៖ សេចក្ដីផ្ដើម**.................................................................................................

សេចក្ដីសង្ខេបនៃគម្រោង.................................................................................................. ៣

គោលបំណងនៃកញ្ចប់ទំនាក់ទំនងផ្លាស់ប្ដូរឥរិយាបថ................................................................. ៤

ដំណើរការបង្កើតកញ្ចប់ទំនាក់ទំនងផ្លាស់ប្ដូរឥរិយាបថ................................................................. ៤

គោលការណ៍ និងសេចក្ដីសង្ខេបនៃកញ្ចប់ទំនាក់ទំនងផ្លាស់ប្ដូរឥរិយាបថ.......................................... ៥

ការទទួលបានសិទ្ធិរបស់ស្ត្រី (WAR)................................................................................. ៥

ការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី (WEE)............................................................. ៦

អំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV)................................................................................ ៧

**ផ្នែកទី២៖ ធ្វើឱ្យក្លាយជាការពិត៖ ពីគំនិតនិងទ្រឹស្ដី ឈានទៅដល់ការអនុវត្ត** ..............................

ទស្សនៈ និងចលនាស្ត្រីនិយម.......................................................................................... ៨

ចលនាស្ត្រីនិយមនិយមលោកខាងលិច ឬស្ត្រីនិយម................................................................. ៨

ស្ត្រីនិយមនៅលោកខាងត្បូង.............................................................................................. ៩

ចលនាស្ត្រី និងសមភាពយេនឌ័រ នៅកម្ពុជា........................................................................ ១០

សមភាពយេនឌ័រភាពចម្រុះ និងគោលគំនិតនៃសង្គមដែលមានបរិយាបន្ន.................................... ១០

យេនឌ័រ និងភេទ......................................................................................................... ១១

សមភាពយេនឌ័រ និងសមធម៌យេនឌ័រ.............................................................................. ១២

បរិយាបន្នសង្គម........................................................................................................... ១២

ក្របខណ្ឌសមភាពយេនឌ័រ និងការអនុវត្តនៅក្នុងគម្រោងសកម្មភាពស្ត្រីនិយម(FiA).................. ១២

ក្របខណ្ឌសមភាពយេនឌ័រ ...................................................................................... ១៣

សមភាពយេនឌ័រ ភាពចម្រុះ និងបរិយាបន្នសង្គម(GESI) ក្នុងការគ្រប់គ្រងវដ្តនៃគម្រោងសកម្មភាពស្ត្រីនិយម (FiA)................................................................................................ ១៤

ការចាត់ថ្នាក់នៃសមភាពយេនឌ័រ និងបរិយាបន្នសង្គម (GESI) ឬដំណើរការផ្លាស់ប្ដូរនៃកិច្ចអន្តរាគមន៍............................................................................................................. ១៦

**និយមន័យ**................................................................................................................ ១៨

**ផ្នែកទី៣៖ឧបករណ៍សម្រាប់អនុវត្តន៍**.................................................................................

**ម៉ូឌុលក៖ ការទទួលបានសិទ្ធិរបស់ស្ត្រី**................................................................................ ១៩

សេចក្ដីផ្ដើម................................................................................................................ ១៩

**វគ្គទី១៖យល់ដឹងអំពីសិទ្ធិរបស់អ្នក**.......................................................................... ១៩

សកម្មភាព ១ក៖ សិទ្ធិមនុស្ស និងឥថភាពជាក់ស្ដែង................................................................ ១៩

សកម្មភាព ២ក៖ ទស្សនៈនិងប្រវត្តិសិទ្ធិស្ត្រី (បន្ទាត់ពេលវេលាប្រវត្តិសាស្ត្រ)................................. ២៣

**វគ្គទី២៖ ក្របខណ្ឌច្បាប់ជាតិ និងអន្តរជាតិទាក់ទងនឹងសិទ្ធិមនុស្ស**........................................ ២៤

សកម្មភាព ៣កៈ យន្តការគាំទ្រថ្នាក់ជាតិ និងអន្តរជាតិទាក់ទងនឹងសិទ្ធិមនុស្សសិទ្ធិស្ត្រី.................... ២៤
សកម្មភាព ៤កៈ តើច្បាប់ប្រទេសកម្ពុជាចែងយ៉ាងដូចម្តេចអំពីសិទ្ធិរបស់ប្រជាជនកម្ពុជា? ................ ២៥
**វគ្គទី៣ៈ យេនឌ័រ និងអន្តរប្រសព្វទាក់ទងនឹងការរើសអើង.................................................... ២៦**
សកម្មភាព ៥កៈ ផលប៉ះពាល់នៃយេនឌ័រ និងអន្តរប្រសព្វទាក់ទងនឹងការរើសអើង........................ ២៦
**វគ្គទី៤ៈ យុទ្ធសាស្ត្រសម្រាប់លើកកម្ពស់ ឬការទទួលបានសិទ្ធិរបស់ស្ត្រី...................................... ២៨**
សកម្មភាព ៦កៈ ផែនការសកម្មភាព.................................................................................... ២៨
**និយមន័យ............................................................................................................. ២៩**

ម៉ូឌុល ខៈ ការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ច...............................................................

សេចក្តីផ្តើម.....................................................................................................
**វគ្គទី១ៈ សេចក្តីណែនាំ និងការបើកឱ្យមានបរិយាកាសសុវត្ថិភាព........................................... ៣៣**
សកម្មភាព ១ខៈ “ការណាត់ជួប” “Speed Dating” ........................................................ ៣៣
**វគ្គទី២ៈ តួនាទីស្ត្រី និងបុរសក្នុងវិស័យសេដ្ឋកិច្ច............................................................. ៣៥**
សកម្មភាព ២ខៈ “ដូងអណ្តែតទឹក” “Floating Coconut”.................................................... ៣៥
**វគ្គទី៣ៈ ការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី សុភមង្គល និងសុខុមាលភាពគ្រួសារ........ ៣៨**
សកម្មភាព ៣ខៈ “ទម្រង់បែបសម្បុកពីងពាង នៃគ្រួសារមានសុភមង្គល និងសុខុមាលភាព”, “Family Happiness and Wellbeing’s Spider Web”................................................. ៣៨
**វគ្គទី៤ៈ លើកកម្ពស់សមភាព ដើម្បីគាំទ្រការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីនៃសុភមង្គល និងសុខុមាលភាពគ្រួសារ......................................................................... ៤០**
សកម្មភាព ៤ខៈ ផែនការសកម្មភាព.................................................................................. ៤០
សកម្មភាព ៥ខៈ តើមានច្បាប់ និងគោលនយោបាយអ្វីខ្លះ ដែលនិយាយអំពីការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីនៅប្រទេសកម្ពុជា? ...................................................................... ៤១
**និយមន័យ............................................................................................................. ៤៣**

**ម៉ូឌុល គៈ អំពើហិង្សាទាក់ទងនឹងយេនឌ័រ..................................................................**

សេចក្តីផ្តើម..................................................................................................... ៤៦
**វគ្គទី១ៈ ទស្សនៈសំខាន់ៗ ពីយេនឌ័រ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ.................................. ៤៧**
សកម្មភាព ១គៈ “ប្រអប់យេនឌ័រ” “Deep Dive” Gender Box ............................................ ៤៧
សកម្មភាព ២គៈ “ជ្រើសរើសដោយប្រើជើង” “Vote with your feet”...................................... ៥០
**វគ្គទី២ៈ ផលប៉ះពាល់ និងមូលហេតុនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ...................................... ៥៣**
សកម្មភាព ៣គៈ “ភពផែនដីថ្មី” “The New Planet”......................................................... ៥៨
**វគ្គទី៣ៈ វិធីសាស្ត្រផ្លាស់ប្រែយេនឌ័រ ដើម្បីដោះស្រាយ អំពើហិង្សាទាក់ទងនឹងយេនឌ័រ.................. ៦១**
ក្របខ័ណ្ឌសមភាពយេនឌ័រ.............................................................................................. ៦១
**វគ្គទី៤ៈ យន្តការគាំទ្រក្រៅផ្លូវការ និងផ្លូវការទៅលើអំពើហិង្សាទាក់ទងនឹងយេនឌ័រ....................... ៦៣**
សកម្មភាព ៤គៈ វិធីសាស្ត្រផ្លូវការ និងក្រៅផ្លូវការចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ.................. ៦៣
សកម្មភាព ៥គៈ ផែនការសកម្មភាព.................................................................................. ៦៧
**ឯកសារយោង......................................................................................................... ៧០**




# សារទៅកាន់អ្នកប្រើប្រាស់កញ្ចប់ឯកសារ

**កញ្ចប់ទំនាក់ទំនងផ្លាស់ប្តូរឥរិយាបថ** ត្រូវបានបង្កើតឡើងដើម្បីជាការបង្ហាញផ្លូវ ដល់អ្នកសម្របសម្រួលនៅតាមតំបន់គោលដៅ។ ការអនុវត្តសកម្មភាពនេះ អាចធ្វើជាសកម្មភាពដោយឡែក ឬអាចរៀបចំបញ្ចូលជាមួយសកម្មភាពដទៃទៀត។

មាតិកាទាំង៣ផ្នែកមាន៖ **ផ្នែកទី១** សាវតានៃការបង្កើតកញ្ចប់ **ផ្នែកទី២** ការណែនាំសង្ខេបនៃគោលគំនិត និងក្របខណ្ឌ និង**ផ្នែកទី៣** ឧបករណ៍សម្រាប់អនុវត្តន៍នៅតាមសហគមន៍។

> ឧបករណ៍សម្រាប់អនុវត្តនេះមានប្រធានបទចំនួន៣ ដែលតម្រូវឱ្យចំណាយពេល៣ម៉ោងក្នុងការអនុវត្តប្រធានបទនីមួយៗ។ អ្នកសម្របសម្រួលគួរតែត្រូវបានបណ្តុះបណ្តាលពីរបៀបប្រើប្រាស់កញ្ចប់បណ្តុះបណ្តាល និងធ្វើតាមជំហានដែលបានរៀបរាប់ក្នុងកញ្ចប់បណ្តុះបណ្តាលនេះ។

ឧបករណ៍សម្រាប់អនុវត្តន៍ រាប់បញ្ចូលប្រធានបទទាំង៣ រួមមាន ការទទួលបានសិទ្ធិរបស់ស្ត្រី ការពង្រឹងសិទ្ធអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ប្រធានបទនីមួយៗនឹងត្រូវការរយៈពេលប្រហែលជា៣ម៉ោងសម្រាប់អនុវត្តន៍នៅតាមសហគមន៍ ប្រសិនបើមិនមានតម្រូវការបកប្រែភាសានោះទេ។

កញ្ចប់នេះនឹងបង្ហាញពីដំណើរការសម្របសម្រួល ទៅតាមប្រធានបទនីមួយៗ។ អ្នកសម្របសម្រួលមិនគួររំលងជំហាន ឬធ្វើតែសកម្មភាពណាមួយនោះទេ ពីព្រោះសកម្មភាពនីមួយៗ មានការពិភាក្សាដែលមានភាពប្រទាក់ក្រឡាគ្នា។ អ្នកសម្របសម្រួលអាចសួរសំណួរថ្មីៗបាន ជុំវិញប្រធានបទនៃការពិភាក្សាហើយការប្រើប្រាស់សំណួររំលឹក និងសំណួរប្រដេញគឺមានសារៈសំខាន់ណាស់ក្នុងការបន្តប្រធានបទ។

វិធីសាស្ត្រល្អបំផុតសម្រាប់អនុវត្តន៍ និងធានានូវការចូលរួម គឺចំនួនអ្នកចូលរួមមិនត្រូវឱ្យលើសពី១៥គូ ឬ៣០នាក់។ ការកំណត់ចំនួនអ្នកចូលរួមគឺអាស្រ័យទៅតាមទីតាំង និងភាពងាយស្រួលរបស់គម្រោង។ ទោះជាយ៉ាងណា ការកំណត់ចំនួនអ្នកចូលរួមអាស្រ័យទៅតាមទីតាំង ភាពងាយស្រួលរបស់គម្រោង និងទីតាំងអនុវត្តន៍សកម្មភាព។ ក្នុងករណីដែលអ្នកចូលរួមស្ថិតក្នុងក្រុមមនុស្សវ័យក្មេង អ្នកមិនទាន់រៀបការ ឬមេម៉ាយ/ពោះម៉ាយ អ្នកមានពិការភាព អ្នកមានយេនឌ័រចម្រុះ នោះអ្នកសម្របសម្រួលត្រូវប្រាកដថា ការបែងចែកក្រុមមានភាពចម្រុះ និងបរិយាបន្ន។ ក្រុមអ្នកសម្របសម្រួលត្រូវរៀបចំការងារ និងបញ្ជីកិច្ចការដូចខាងក្រោម៖

- ☑ ជួបជាមួយក្រុមដើម្បីធ្វើផែនការ បែងចែកទំនួលខុសត្រូវ។
- ☑ រៀបចំសម្ភារៈ និងឧបករណ៍ដែលត្រូវការ។
- ☑ ពិគ្រោះជាមួយសហគមន៍ជាមុន ក្នុងការអនុញ្ញាតធ្វើសកម្មភាព និងកំណត់ពេលវេលា។
- ☑ ធានាថាអ្នកចូលរួមបានទទួលព័ត៌មានពេញលេញ និងយល់ព្រមរៀបចំសកម្មភាព។
- ☑ ការជួបជាមួយអ្នកភូមិ ដើម្បីរៀបចំសកម្មភាព គួរតែធ្វើឡើងពី៣ ទៅ ៥ថ្ងៃមុន។
- ☑ ធានាសុវត្ថិភាព និងផ្តល់ការមើលថែសម្រាប់ក្មេងៗ នៅពេលដែលឪពុកម្តាយមកចូលរួមសកម្មភាព។
- ☑ បញ្ជាក់ កិច្ចព្រមព្រៀងអនុញ្ញាតថតរូបភាព ឬវីដេអូ។
- ☑ រៀបចំអាហារសម្រាប់ក្រុមរបស់អ្នក ដើម្បីចៀសវាងការដាក់បន្ទុកទៅឱ្យអ្នកភូមិ និងរៀបចំអាហារសម្រន់ (ដែលមានអាហារូបត្ថម្ភ និងមិនប៉ះពាល់ដល់បរិស្ថាន) សម្រាប់កុមារប្រសិនជាត្រូវការ។

ការរៀបចំទីតាំងអង្គុយគួរតែនៅកន្លែងទូលាយ និងមានរាងជាអក្សរ U ។ ព្យាយាមទុកចន្លោះរវាងបុរស និងស្ត្រីឬឱ្យអ្នកចូលរួមអាចជ្រើសរើសកន្លែងអង្គុយដោយខ្លួនឯង អាស្រ័យនឹងភាពងាយស្រួលរបស់ពួកគេ។
ក្រុមអ្នកសម្របសម្រួល គួរពិនិត្យមើលសម្ភារៈ និងត្រៀមទុកមុនចាប់ផ្តើមសកម្មភាព មានដូចជា៖

- ☑ ទីតាំងទូលាយ មានពន្លឺគ្រប់គ្រាន់ មានអនាម័យ ស្ងៀមស្ងាត់ និងមិននៅជិតផ្លូវធ្វើដំណើរ។
- ☑ អ្នកចូលរួមទាំងអស់អង្គុយជារាងអក្សរU និងមានចម្រុះយេនឌ័រ។
- ☑ អ្នកចូលរួមមិនឱ្យលើសពី១៥គូ ឬ៣០នាក់។ ប្រសិនជាអាច គួរមានស្ត្រីពាក់កណ្តាល និងបុរសពាក់កណ្តាល។
- ☑ ក្នុងករណីមានអ្នកចូលរួមសកម្មភាពជាមនុស្សចាស់ និងអ្នកមានពិការភាព ត្រូវធានាថា មានកន្លែងអង្គុយដែលមានភាពងាយស្រួល ហើយពួកគេអាចចូលរួមពិភាក្សាបានពេញលេញ។
- ☑ ប្រសិនបើមាននរណាម្នាក់មិនអាចនិយាយបាន ហើយមិនចេះភាសាខ្មែរ ត្រូវធានាថា មានមាននរណាម្នាក់ដើម្បីបកប្រែ។

# ផ្នែកទី១

# សេចក្ដីផ្ដើម

# ផ្នែកទី១៖ សេចក្តីផ្តើម

## សេចក្តីសង្ខេបនៃគម្រោង

**អង្គការឃែរ** ត្រូវបានបង្កើតឡើងដំបូងនៅក្នុងឆ្នាំ១៩៤៥ ផ្តើមចេញពីការបង្កើត «កញ្ចប់ជំនួយមនុស្សធម៌ »។ អង្គការឃែរ គឺជាអង្គការមនុស្សធម៌ដែលឈានមុខគេ ក្នុងការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើស្ត្រី និងក្មេងស្រី ដោយមានគោលបំណងផ្តល់ និងជម្រុញរាល់ធនធានសមស្របដែលនាំឱ្យស្ត្រី និងក្មេងស្រីពង្រឹងសិទ្ធិអំណាចក្នុងការលើកស្ទួយគ្រួសារ និងសហគមន៍ទាំងមូលឱ្យរួចផុតពីភាពក្រីក្រ។ ត្រឹមឆ្នាំ២០២៣ អង្គការឃែរធ្វើការនៅក្នុងប្រទេសចំនួន ១០៩ប្រទេស និងបានទៅដល់មនុស្សចំនួន ១៦៧លាននាក់ តាមរយៈគម្រោងជាង ១៦០០គម្រោង។ ដើម្បីស្វែងយល់បន្ថែម ពីអង្គការឃែរសូមចូលទៅកាន់គេហទំព័រ www.care.org ។

អង្គការឃែរ បានចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួននៅក្នុងប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៧៣ ដោយផ្តល់ជំនួយក្នុងការស្តារឡើងវិញ នៅតាមបន្ទាត់ព្រំដែន។ តាំងពីការបើកឱ្យដំណើរការឡើងវិញនូវការិយាល័យប្រចាំប្រទេសនៅឆ្នាំ១៩៩១ អង្គការឃែរបានពង្រីកវិសាលភាពនៃការងារអភិវឌ្ឍន៍។ សព្វថ្ងៃនេះ អង្គការឃែរធ្វើការជាមួយក្រុមស្ត្រីជនជាតិដើមភាគតិច និងក្រុមស្ត្រីនៅតាមទីជនបទដែលត្រូវបានគេរំលោភបំពានសិទ្ធិ ដែលក្នុងនោះផ្តោតសំខាន់លើអ្នកដែលរស់នៅប៉ែកពាយ័ព្យសាន ភ្នំពេញ និងតំបន់នៅជុំវិញ។

ជារៀងរាល់ឆ្នាំ អង្គការឃែរប្រចាំកម្ពុជា អនុវត្តន៍គម្រោងប្រមាណ១០គម្រោង ដែលអាចមានឥទ្ធិពលជាប្រយោជន៍ដល់ប្រជាជនប្រមាណ ១០០,០០០នាក់ដោយផ្ទាល់ និងប្រមាណ ៣០០,០០០នាក់ដោយប្រយោល ជាមួយនឹងការសហការជាមួយអង្គការ និងស្ថាប័នស្ត្រីនិយម ក្នុងស្រុកជាច្រើន។

**ចលនាស្ត្រីនិយម** មានការរីកចម្រើនជាច្រើនជាសកលក្នុងទសវត្សរ៍ចុងក្រោយនេះ ដោយបានបង្កើតនូវឥទ្ធិពលវិជ្ជមានជាច្រើនលើគោលនយោបាយ ផ្នត់គំនិតសង្គម និងភាពជាតំណាង ។ យ៉ាងណាមិញ បញ្ហាកង្វះកញ្ចប់ថវិកាគាំទ្រ កិច្ចការងារនេះនៅបន្តមាន។ **គម្រោងសកម្មភាពស្ត្រីនិយម (FiA)** ជាមួយនឹងការគាំទ្រថវិកាពីអង្គការឃែរប្រចាំសាធារណរដ្ឋបារាំង មានគោលដៅចូលរួមចំណែកនៅក្នុងការធានាឱ្យបាននូវនិរន្តរភាពនៃចលនាទាំងនេះ។ គម្រោងនេះមានបំណងជួយគាំទ្រជាកញ្ចប់ថវិកា ការគាំទ្រធនធានមនុស្ស សម្ភារៈ និងធនធានស្ថាប័ន ដែលសមស្របទៅដល់អង្គការស្ត្រីនានា ក្នុងការអនុវត្តការងារដើម្បីសម្រេចបាននូវចក្ខុវិស័យរបស់ខ្លួន និងលើកទឹកចិត្តម្ចាស់ជំនួយដទៃទៀត ក្នុងការជួយគាំទ្រពួកគេដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងការអភិវឌ្ឍសង្គមទាំងនៅក្នុងប្រទេសកម្ពុជា និងប្រទេសកំពុងអភិវឌ្ឍន៍។

គម្រោងសកម្មភាពស្ត្រីនិយម (FiA) ផ្តោតទៅលើប្រធានបទចំនួន ៤ ៖
១.សុខភាពផ្លូវភេទ និងបន្តពូជ និងសិទ្ធិ (SRHR)
២.ការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV)
៣.ការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី (WEE)
៤.ការទទួលបានសិទ្ធិរបស់ស្ត្រី (WAR)

គម្រោងសកម្មភាពស្ត្រីនិយម (FiA) នៅក្នុងប្រទេសកម្ពុជា បានជួយគាំទ្រដល់អង្គការសង្គមស៊ីវិលដែលធ្វើការដើម្បីសិទ្ធិស្ត្រីចំនួន ៦ស្ថាប័ន ដើម្បីលើកកម្ពស់សមភាពយេនឌ័រ ភាពចម្រុះ និងការអភិវឌ្ឍសង្គម ពិសេសតាមរយៈការផ្តល់នូវការអភិវឌ្ឍសមត្ថភាពរបស់អង្គការសង្គមស៊ីវិលទាំងនេះ។ អង្គការសង្គមស៊ីវិលទាំងនេះ បានធ្វើការនៅតំបន់គោលដៅផ្សេងៗ ក្នុងប្រទេសកម្ពុជា។ អ្នកទទួលផលផ្ទាល់នៃគម្រោងរបស់អង្គការទាំងនេះ រួមមានស្ត្រីរស់នៅតាមទីប្រជុំជន ស្ត្រីអាជីវករតាមផ្លូវ ស្ត្រីដែលមានធុរកិច្ចខ្នាតតូច ស្ត្រីចំណាកស្រុក (ទាំងប្រជាជនកម្ពុជា និងជនបរទេស) ក្រុមជនជាតិដើមភាគតិច ស្ត្រីជាកសិករ និងក្រុមអ្នកដែលស្រលាញ់ភេទដូចគ្នា។

ក្រុមការងារបច្ចេកទេសអង្គការយែរកម្ពុជា និងសមាជិកនៃបណ្តាញក្រុមយេនឌ័ររបស់អង្គការយែរ បានផ្តល់នូវសេវាកម្មដើម្បីបង្កើតនូវ «កញ្ចប់ទំនាក់ទំនងផ្លាស់ប្តូរឥរិយាបថ ផ្តោតទៅលើទស្សនៈស្ត្រីនិយម និងការបណ្តុះបណ្តាលគ្រូបង្គោល សម្រាប់អង្គការសង្គមស៊ីវិលលើប្រធានបទស្ត្រីនិយម»។ កញ្ចប់បណ្តុះបណ្តាលនេះផ្តោតសំខាន់ទៅលើគោលគំនិតចំនួន ៣ រួមមាន **(១) ការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV) (២) ការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី (WEE) និង (៣) ការទទួលបានសិទ្ធិរបស់ស្ត្រី (WAR)** ។

## គោលបំណងនៃកញ្ចប់ទំនាក់ទំនងផ្លាស់ប្តូរឥរិយាបថ

កញ្ចប់ទំនាក់ទំនងផ្លាស់ប្តូរឥរិយាបថនេះ មានគោលដៅផ្តល់ជាឧបករណ៍ និងវិធីសាស្ត្រអនុវត្ត បង្កើនចំណេះដឹង និងដោះស្រាយ តម្រូវការពង្រឹងសមត្ថភាពរបស់អង្គការសង្គមស៊ីវិលដែលធ្វើការដើម្បីសិទ្ធិស្ត្រី ក្នុងការអនុវត្តការងាររបស់ខ្លួននៅតាមសហគមន៍គោលដៅ។

**គោលបំណងទី១** នៃកញ្ចប់ទំនាក់ទំនងផ្លាស់ប្តូរឥរិយាបថនេះ គឺការចូលរួមលើកកម្ពស់សមភាពយេនឌ័រ ភាពចម្រុះ គោលការណ៍ និងយុទ្ធសាស្ត្រប្រកបដោយបរិយាបន្នសង្គម ដែលជំរុញដល់ការលុបបំបាត់ចោលនូវរនាំងដែលមាននៅពេលបច្ចុប្បន្នក្នុងការទទួលបានសិទ្ធិ។ មិនតែប៉ុណ្ណោះ កញ្ចប់ទំនាក់ទំនងផ្លាស់ប្តូរឥរិយាបថនេះ ក៏មានគោលដៅលុបបំបាត់នូវផ្នត់គំនិតសង្គមអវិជ្ជមាននានា ដែលជាកត្តាធ្វើឱ្យមានអំពើហិង្សាលើស្ត្រី និងក្មេងស្រី ព្រមទាំងក្រុមដែលមិនសូវទទួលបានសិទ្ធិពេញលេញ និងជំរុញឱ្យមានការចូលរួមប្រកបដោយអត្ថន័យ និងការសម្រេចចិត្តនានានៅក្នុងការងារសេដ្ឋកិច្ច និងជីវិតនៅក្នុងសង្គមរបស់ពួកគេ។

**គោលបំណងទី២** នៃកញ្ចប់ទំនាក់ក់ទំនងផ្លាស់ប្តូរឥរិយាបថនេះគឺ ធានាឱ្យបាននូវសិទ្ធិស្មើគ្នា សមភាព យុត្តិធម៌ ឱកាស និងពង្រឹងគុណភាពសេវាកម្មសម្រាប់ប្រជាជន នៅតាមតំបន់គោលដៅ ជាជាងត្រឹមតែពង្រឹងសុខុមាលភាពបុគ្គល។ ទស្សនៈមួយនេះ ផ្តោតសំខាន់ទៅលើការផ្លាស់ប្តូរភាពលម្អៀងនៃទំនាក់ទំនងយេនឌ័រ ដែលជាឧបសគ្គដល់ក្រុមដែលងាយរងគ្រោះ និងក្រុមដែលមិនត្រូវបានគេរាប់បញ្ចូល និងទទួលបានផលប្រយោជន៍តិច។ នេះមិនសំដៅត្រឹមតែស្ត្រីដែលរស់នៅក្នុងទីប្រជុំជន និងទីដាច់ស្រយាលនោះទេ តែក៏រួមបញ្ចូលទាំងក្រុមអ្នកស្រលាញ់ភេទដូចគ្នា ជនជាតិដើមភាគតិច និងក្រុមដែលមានពិការភាពផងដែរ។

## ដំណើរការបង្កើតកញ្ចប់ទំនាក់ទំនងផ្លាស់ប្តូរឥរិយាបថ

មូលដ្ឋានគ្រឹះ នៃកញ្ចប់ទំនាក់ទំនងផ្លាស់ប្តូរឥរិយាបថនេះ គឺត្រូវបានបង្កើតឡើងដោយផ្អែកទៅលើក្របខណ្ឌសមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចរបស់ស្ត្រី របស់អង្គការយែរ ក្នុងការបង្កើនសមត្ថភាពរបស់ភ្នាក់ងារផ្លាស់ប្តូរទំនាក់ទំនង និងរចនាសម្ព័ន្ធ ក៏ដូចជាពង្រីកឥទ្ធិពលរបស់អង្គការសង្គមស៊ីវិលដែលធ្វើការដើម្បីសិទ្ធិស្ត្រី ក្នុងការបង្កើតឱ្យមានការផ្លាស់ប្រែ។ កញ្ចប់ផ្លាស់ប្តូរឥរិយាបថនេះ ត្រូវបានបង្កើតឡើង ដោយយកលំនាំតាម ឧបករណ៍ទាក់ទងនឹងសមភាពយេនឌ័ររបស់អង្គការយែរ និងដៃគូ ដោយមានការសហការ និងពិភាក្សាជាមួយនឹងក្រុមការងារបច្ចេកទេសរបស់អង្គការយែរប្រចាំកម្ពុជា និងអង្គការសង្គមស៊ីវិលដែលធ្វើការដើម្បីសិទ្ធិស្ត្រី ដែលត្រូវបានជ្រើសរើសទាំង ៦ស្ថាប័ន។

ខ្លឹមសារនៃកញ្ចប់ផ្លាស់ប្តូរឥរិយាបថនេះ ស្របតាមក្របខណ្ឌនៃផែនការសកម្មភាពជាតិរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ នារីរតនៈតំណាក់កាលទី៥ឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ ផែនការយុទ្ធសាស្ត្រ៥ឆ្នាំដើម្បីជំរុញការបញ្ជ្រាបយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី យុទ្ធសាស្ត្របញ្ចកោណដើម្បីការអភិវឌ្ឍ កំណើនការងារ សមធម៌ និងប្រសិទ្ធភាព៖ ការកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅរកការសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ដំណាក់កាលទី១ នៅកម្ពុជា។ ខាងក្រោមនេះគឺជាសេចក្តីសង្ខេបនៃដំណើរការអភិវឌ្ឍន៍ កញ្ចប់ទំនាក់ទំនងផ្លាស់ប្តូរឥរិយាបថនេះ។




## សនិទានភាព និងសេចក្តីសង្ខេបនៃកញ្ចប់ទំនាក់ទំនងផ្លាស់ប្តូរឥរិយាបថ

កញ្ចប់ទំនាក់ទំនងផ្លាស់ប្តូរឥរិយាបថនេះ ត្រូវបានបង្កើតឡើង ជាមួយនឹងការយកចិត្តទុកដាក់ជាពិសេសទៅលើបរិបទនៃប្រទេសកម្ពុជា និងស្របតាមកម្រិតផ្សេងៗគ្នានៃអ្នកប្រើប្រាស់ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងយុត្តិធម៌សង្គមសម្រាប់ស្ត្រី កុមារី និងក្រុមអ្នកដែលបាត់បង់សិទ្ធិនៅតាមតំបន់ទិសដៅក្រោមគម្រោងរបស់អង្គការដៃគូ ក៏ដូចជាដើម្បីលើកកម្ពស់ការយល់ដឹងរបស់បុរស និងក្មេងប្រុស។ ម៉ូឌុលនីមួយៗនៃកញ្ចប់ទំនាក់ទំនងផ្លាស់ប្តូរឥរិយាបថ គ្របដណ្តប់លើផ្នែកផ្សេងៗ ដោយចាប់ផ្តើមពីការពិភាក្សាទូទៅ ការបំផុសគំនិត ការវិភាគចន្លោះប្រហោង និងឆ្លុះបញ្ចាំងពីការអនុវត្ត តាមសហគមន៍នៅតាមទីប្រជុំជន និងជនបទនៃប្រទេសកម្ពុជា។

គោលនយោបាយ និងយន្តការគាំទ្រយេនឌ័រ ក៏ត្រូវបានរួមបញ្ចូលផងដែរនៅក្នុងកញ្ចប់នីមួយៗ ដើម្បីឱ្យអ្នកចូលរួមធ្វើការឆ្លុះបញ្ចាំងអំពីការអនុវត្ត និងការពង្រឹងឡើងវិញ។ ដំណើរការនៃកញ្ចប់នីមួយៗ ណែនាំអ្នកសម្របសម្រួលដើម្បីជួយសម្រួលដល់ការពិភាក្សាជាក្រុមធំ និងក្រុមតូច។ សកម្មភាពនីមួយៗត្រូវបានរចនាដោយរួមបញ្ចូលនូវវិធីសាស្ត្ររៀនសូត្រដែលមានលក្ខណៈចូលរួម ការរៀនសូត្របែបមនុស្សពេញវ័យ និងវិធីទំនាក់ទំនងទៅមក ហើយកញ្ចប់នីមួយៗ ក៏រួមបញ្ចូលសម្ភារៈជាទម្រង់រូបភាព សំណួរណែនាំ និងករណីសិក្សា ដើម្បីជួយពង្រឹងការយល់ដឹងរបស់អ្នកចូលរួម និងសមត្ថភាពវិភាគបញ្ហា និងឧបសគ្គប្រឈម របស់ក្រុមផ្សេងៗគ្នាទាក់ទងនឹងការទទួលបានសិទ្ធិធនធាន សេដ្ឋកិច្ច ការគាំពារ ឬការបង្ការហិង្សា និងយុត្តិធម៌។

## ការទទួលបានសិទ្ធិរបស់ស្ត្រី (WAR)

ការទទួលបានសិទ្ធិរបស់ស្ត្រី (WAR) គឺជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងសុខុមាលភាពរបស់បុគ្គល សហគមន៍ និងប្រទេសទាំងមូល។ មានកត្តាជាច្រើនដែលជះឥទ្ធិពលដល់ស្ត្រី និងកុមារី (រួមទាំងភាពចម្រុះនៃស្ត្រី និងកុមារី និងយេនឌ័រចម្រុះ) ក្នុងការទទួលបានសិទ្ធិរបស់ខ្លួនក្នុងប្រទេសកម្ពុជា ជាពិសេសនៅក្នុងតំបន់គោលដៅដែលអង្គការដែលធ្វើការដើម្បីសិទ្ធិស្ត្រីទាំង៦ កំពុងធ្វើការជាមួយ។

ការវាយតម្លៃតម្រូវការសមត្ថភាព និងការធ្វើសិក្ខាសាលាពិគ្រោះយោបល់ ជាមួយអង្គការសង្គមស៊ីវិលដែលធ្វើការដើម្បីសិទ្ធិស្ត្រីទាំង៦ បានបង្ហាញថា ការទទួលបានការអប់រំទាបរបស់ស្ត្រី បានកំណត់ពួកគេក្នុងការទទួលបានសិទ្ធិរបស់ស្ត្រីក្នុងសង្គម និងចូលរួមក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច។ បទដ្ឋានយេនឌ័រ និងផ្នត់គំនិតសង្គមដែលផ្តល់តម្លៃខ្ពស់ដល់បុរស និងក្មេងប្រុស កំណត់ការទទួលបានសិទ្ធិរបស់ស្ត្រី។ បុរសត្រូវបានចាត់ទុកថាជាអ្នករកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ ស្ត្រីជាអ្នកមើលថែក្នុងផ្ទះ គ្រួសារ និងនៅក្រៅផ្ទះ។

ម៉ូឌុលនេះ គឺធ្វើឡើងដើម្បីផ្តល់ជាឧបករណ៍ជំរុញដល់អង្គការដែលធ្វើការដើម្បីសិទ្ធិស្ត្រី ដើម្បីប្រើប្រាស់ក្នុងគោលបំណងលើកកម្ពស់ និងគាំទ្រដល់ការទទួលបានសិទ្ធិរបស់ស្ត្រីនៅក្នុងសហគមន៍ ជាពិសេសសម្រាប់ការអនុវត្តសកម្មភាពរបស់គម្រោងសកម្មភាពស្ត្រីនិយម (FiA) នៅក្នុងប្រទេសកម្ពុជា។

ម៉ូឌុល ការទទួលបានសិទ្ធិរបស់ស្ត្រី (WAR) ផ្តល់នូវឧបករណ៍ដើម្បីលើកកម្ពស់ការយល់ដឹងកាន់តែប្រសើរឡើងអំពីការទទួលបានសិទ្ធិរបស់ស្ត្រី ដែលជាសិទ្ធិដូចទៅនឹងសិទ្ធិមនុស្សទូទៅដែរ។ ម៉ូឌុលនេះមានគោលបំណងពង្រឹងជំនាញរបស់អ្នកសម្របសម្រួល ក្នុងការពិភាក្សាប្រកបដោយការចុះសម្រុង ដោយផ្តោតលើសិទ្ធិ គោលនយោបាយ និងអនុសញ្ញាក្នុងបរិបទកម្ពុជា ហើយឆ្លុះបញ្ចាំងពីសិទ្ធិប្រជាពលរដ្ឋ និងសិទ្ធិស្ត្រីក្នុងតថភាពសង្គមជាក់ស្តែង។ សកម្មភាព និងលំហាត់ត្រូវបានបង្កើត និងរៀបចំ ដោយលើកទឹកចិត្តអ្នកចូលរួមឱ្យចែករំលែកបទពិសោធន៍របស់ខ្លួន និងធ្វើការជាមួយគ្នា តាមរយៈដំណើរការ ឆ្លុះបញ្ចាំងពីសិទ្ធិផ្ទាល់ខ្លួន និងការសង្កេតលើសិទ្ធិរបស់អ្នកដទៃ។ បន្ទាប់មក អ្នកចូលរួមភ្ជាប់ការឆ្លុះបញ្ចាំងទាំងនេះទៅនឹងអ្វីដែលពួកគេឃើញ សង្កេត និងជួបប្រទះ នៅក្នុងជីវិតរបស់ពួកគេ ទាំងនៅផ្ទះ ក្នុងសហគមន៍ និងសង្គម។ ដំណើរការនេះលើកកម្ពស់សិទ្ធិបុគ្គល ឬសិទ្ធិរបស់ភ្នាក់ងារពីកម្រិតមូលដ្ឋាន ទៅកាន់កម្រិតខ្ពស់ និងគោរពសិទ្ធិរបស់អ្នកដទៃនៅជុំវិញខ្លួន។

ខ្លឹមសារសំខាន់នៃម៉ូឌុលរួមមាន៖

- ការដឹងពីសិទ្ធិរបស់អ្នក
- ក្របខ័ណ្ឌច្បាប់អន្តរជាតិ និងជាតិស្តីពីសិទ្ធិ
- យេនឌ័រ និងការរើសអើងដែលមានលក្ខណៈអន្តរប្រសព្វ
- យុទ្ធសាស្ត្រលើកកម្ពស់ ឬការទទួលបានសិទ្ធិរបស់ស្ត្រី តាមរយៈការធ្វើផែនការសកម្មភាព

## ការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី (WEE)

លទ្ធផលនៃការវាយតម្លៃតម្រូវការពង្រឹងសមត្ថភាព ពីអង្គការដែលធ្វើការដើម្បីសិទ្ធិស្ត្រីទាំង៦ នៅក្នុងប្រទេសកម្ពុជា បង្ហាញថា អង្គការនីមួយៗធ្វើការជាមួយស្ត្រីនៅក្នុងទីក្រុង និងក្នុងសហគមន៍លើការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី (WEE)។ សកម្មភាពពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី (WEE) ជំរុញឱ្យមានការរីកចម្រើនជាវិជ្ជមានសម្រាប់ក្រុមស្ត្រីដែលរស់នៅក្នុងតំបន់ទីក្រុង ជាពិសេសតាមរយៈក្រុមស្ត្រីសន្សំប្រាក់ និងកសាងទំនុកចិត្តលើខ្លួនឯង។ យ៉ាងណាក៏ដោយ លទ្ធផលនៃសិក្ខាសាលាពិគ្រោះយោបល់ បានបង្ហាញថាការធ្វើការជាមួយស្ត្រីក្នុងសហគមន៍ ប្រឈមជាមួយឧបសគ្គផ្សេងៗជាច្រើនដែលស្ត្រីកំពុងតែជួបប្រទះ។ ឧទាហរណ៍៖ បទដ្ឋានសង្គមទាក់ទងនឹងយេនឌ័របានដាក់កំហិតស្ត្រីជាភេទ «ទន់ខ្សោយ» និងជា «អ្នកដើរតាម»។ ស្ត្រីគឺជាអ្នកមើលថែគ្រួសារដ៏សំខាន់ ហើយស្ត្រីមិនអាចចូលរួមក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចបានពេញលេញទេ ដោយសារតម្លៃដែលសង្គមផ្តល់ឱ្យគឺការនៅតែផ្ទះ និងចាត់ចែងចំណូលគ្រួសារ។ បញ្ហាប្រឈមមួយទៀតសម្រាប់ស្ត្រី គឺការអប់រំទាប ខ្វះជំនាញក្នុងការចរចាជាមួយដៃគូ ពេលធ្វើការសម្រេចចិត្តលើការប្រើប្រាស់លុយកាក់ ការវិនិយោគ និងកង្វះព័ត៌មាន ទាក់ទងនឹងការរីកលូតលាស់អាជីវកម្ម និងការលើកកម្ពស់ហិរញ្ញវត្ថុ។

ម៉ូឌុលនេះផ្តល់នូវការណែនាំសម្រាប់អ្នកសម្របសម្រួល ក្នុងការធ្វើការជាមួយសហគមន៍ដើម្បីយល់កាន់តែច្បាស់អំពីតួនាទីយេនឌ័រ នៅក្នុងសេដ្ឋកិច្ចតាមបែបវិធីសាស្ត្រចូលរួម និងឆ្លុះបញ្ចាំង។ ម៉ូឌុលក៏ផ្តល់នូវឧបករណ៍ដើម្បីវិភាគផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមាននៃការអភិវឌ្ឍសេដ្ឋកិច្ច និងការចូលរួមរបស់ស្ត្រី និងបុរស ជនមានពិការភាព ជនជាតិដើមភាគតិច និងភាពចម្រុះនៃយេនឌ័រនៅក្នុងគ្រួសារ និងសហគមន៍។ លើសពីនេះ ឧបករណ៍នេះនឹងនាំអ្នកចូលរួមពិភាក្សាអំពីសុភមង្គល និងសុខុមាលភាពរបស់ពួកគេ តាមរយៈការលើកកម្ពស់សមភាពយេនឌ័រទាក់ទងនឹងការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី។

ម៉ូឌុលក៏មានគោលបំណងដោះស្រាយឧបសគ្គដែលស្ត្រីប្រឈមមុខ ដោយបង្កើតផែនការសកម្មភាពនៅចុងបញ្ចប់នៃវគ្គ។ អ្នកចូលរួមនឹងសិក្សា និងដឹងពីគោលនយោបាយជាតិដែលគាំទ្រ ការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី (WEE)។ ខ្លឹមសារនៃម៉ូឌុលរួមមាន:

- ការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី (WEE) និងយន្តការគាំទ្រថ្នាក់ជាតិ
- តួនាទីយេនឌ័រនៅក្នុងសេដ្ឋកិច្ច
- ការវិភាគអំពីការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី និងផលប៉ះពាល់
- យុទ្ធសាស្ត្រលើកកម្ពស់សមភាព ដើម្បីគាំទ្រដល់ការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី តាមរយៈការធ្វើផែនការសកម្មភាព។

## អំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV)

អំពើហិង្សាក្នុងគ្រួសារគឺជាបញ្ហាទូទៅ ដែលត្រូវបានចែករំលែកពីអ្នកចូលរួមដែលបានចូលរួម នៅក្នុងវគ្គវាយតម្លៃតម្រូវការសមត្ថភាព និងនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ ជាមួយអង្គការដែលធ្វើការដើម្បីសិទ្ធិស្ត្រីទាំង៦។ ទម្រង់នៃអំពើហិង្សារួមមានការបំពានផ្លូវភេទ និងអំពើហិង្សាផ្លូវអារម្មណ៍។ ឫសគល់ដែលនាំឱ្យមានករណីទាំងនេះ គឺមានទំនាក់ទំនងទៅនឹងអតុល្យភាពអំណាចយេនឌ័រ ស្ត្រីរស់នៅក្រោមបទដ្ឋានសង្គម និងការប្រតិបត្តិបែបបិតាធិបតេយ្យ ។ បទដ្ឋានសង្គម លើកទឹកចិត្តស្ត្រីមិនគួរមានការអប់រំខ្ពស់ជាងបុរសទេ ហើយ «បុរសពិត» គួរតែមានឥរិយាបថហិង្សា រឹងមាំ និងដឹកនាំអ្នកដទៃ។ ប្រពន្ធត្រូវស្តាប់បង្គាប់ប្តី។

ឧបសគ្គដែលជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ កំពុងប្រឈម គឺកង្វះយន្តការរាយការណ៍ដែលអាចទុកចិត្ត និងដោះស្រាយបាន។ ស្ត្រីមិនមានអារម្មណ៍សុវត្ថិភាពក្នុងការរាយការណ៍ ដោយសារតែផ្នត់គំនិតសង្គមកំណត់ថា តួនាទីរបស់គាត់នៅក្នុងគ្រួសារ គឺត្រូវពឹងផ្អែកលើប្តីរបស់ខ្លួន។ ស្ត្រីខ្លះបានដកពាក្យបណ្តឹងចេញ បន្ទាប់ពីពាក្យបណ្តឹងនោះត្រូវបានបញ្ជូនទៅតុលាការ។ មូលហេតុ គឺស្ត្រីត្រូវទទួលខុសត្រូវចំពោះកូនទាំងអស់នៅក្នុងបន្ទុកដោយខ្លួនឯង ក្នុងករណីដែលពួកគេឈានដល់ដំណាក់កាលលែងលះ និងមួយវិញទៀត ពួកគេខ្វះមធ្យោបាយក្នុងការរកប្រាក់ចំណូល ដែលមានស្ថិរភាពសម្រាប់ខ្លួនឯង និងកូនៗ។

ម៉ូឌុលនេះ មានគោលដៅដោះស្រាយបញ្ហាដែលស្ត្រីប្រឈម ហើយលើកកម្ពស់ការយល់ដឹងដល់សមាជិកសហគមន៍ ដើម្បីត្រិះរិះ និងស្វែងរកការគាំទ្រនៅក្នុងសហគមន៍ ពីសេវាឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងពីអង្គការអភិវឌ្ឍន៍ នៅពេលដែលពួកគេជួបប្រទះអំពើហិង្សា។

សកម្មភាព និងលំហាត់ដែលបានរៀបរៀងនៅក្នុងម៉ូឌុលនេះ ផ្តល់ជូននូវគោលគំនិតសំខាន់ៗ មូលហេតុ ផលវិបាក និងយន្តការដែលមានប្រសិទ្ធភាព ក្នុងការជួយគាំទ្រដល់បុគ្គល គ្រួសារ និងសហគមន៍ពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ឧបករណ៍នេះក៏ផ្តល់នូវក្របខណ្ឌណែនាំមួយ សម្រាប់អ្នកចូលរួមដើម្បីធ្វើការ កាត់បន្ថយ អំពើហិង្សាទាក់ទងនឹងយេនឌ័រ ដោយសិក្សាពីយន្តការគាំទ្រនៅក្នុងបរិបទក្នុងស្រុក។

ខ្លឹមសារនៃម៉ូឌុលរួមមាន៖
- គំនិតសំខាន់ៗ អំពីយេនឌ័រ អំពើហិង្សាទាក់ទងនឹងយេនឌ័រ (ទម្រង់បែបបទ ប្រភេទនៃអំពើហិង្សា)
- ឥទ្ធិពលនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងមូលហេតុរបស់អំពើហិង្សាទាក់ទងនឹងយេនឌ័រ
- ក្របខណ្ឌសមភាពយេនឌ័រ
- យន្តការគាំទ្រ (ក្រៅផ្លូវការ និងផ្លូវការ) និងផែនការសកម្មភាព។

# ផ្នែកទី២

## ធ្វើឱ្យក្លាយជាការពិត៖

## ពីគំនិតនិងទ្រឹស្ដី ឈានទៅដល់ ការអនុវត្ត

## ផ្នែកទី២៖ ធ្វើឱ្យក្លាយជាការពិត៖ ពីគំនិត និងទ្រឹស្តី ឈានទៅដល់ការអនុវត្ត

ផ្នែកនេះបង្ហាញពីទ្រឹស្តី និងគោលគំនិតពាក់ព័ន្ធ ដែលជាទូទៅត្រូវបានប្រើប្រាស់ក្នុងកម្មវិធីអភិវឌ្ឍន៍ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងបរិយាបន្នដែលមានភាពចម្រុះគ្នានៅតាមគម្រោង ឬកម្មវិធី។ វគ្គបណ្តុះបណ្តាលនេះនឹងមានជាសកម្មភាពអន្តរកម្ម ដោយមានការចូលរួមសកម្ម ការពិភាក្សា និងការឆ្លុះបញ្ចាំងដោយប្រៀបធៀបទស្សនៈ ទ្រឹស្តី ទៅនឹងការពិតនៅក្នុងបរិបទកម្ពុជា។

### ទស្សនៈ និងចលនាស្ត្រីនិយម

មកដល់ពាក់កណ្តាលសតវត្សទី១៩ គំនិតស្ត្រីនិយមត្រូវបានជំរុញដំបូងដោយបុគ្គល ទាំងស្ត្រី និងបុរស ជាមួយនឹងចលនាស្ត្រីនិយមដំបូងគេបំផុត ដែលបានបង្កើតឡើង នៅក្នុងទ្វីបអឺរ៉ុបនៅពាក់កណ្តាលសតវត្សទី១៩ ។

ដំបូងឡើយ ចលនាទាំងនេះផ្តោតសំខាន់បំផុតក្នុងការតស៊ូមតិ ដើម្បីសិទ្ធិរបស់ស្ត្រីដើម្បីទទួលបានការអប់រំ និងសិទ្ធិប្រើប្រាស់ទេពកោសល្យរបស់ពួកគេដោយសេរី ជាពិសេសក្នុងទម្រង់នៃសកម្មភាព និងការចូលរួមក្នុងកិច្ចការសាធារណៈនានា ដែលទទួលបានប្រាក់កម្រៃ។ ខណៈពេលដែលចលនាទាំងអស់នោះ ភាគច្រើនត្រូវបានរៀបចំនៅតាមប្រទេសរៀងៗខ្លួន ពួកគេក៏មានការរៀបចំនៅលើឆាកអន្តរជាតិទន្ទឹមគ្នាផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ចលនាជាតិនិយម និងសង្គ្រាមលោកទាំងពីរលើកក្នុងអំឡុងសតវត្សទី២០ បានក្លាយជាការសាកល្បងទៅលើលទ្ធិអន្តរជាតិដែលគេតែងអះអាងនោះ។

ក្នុងអំឡុងឆ្នាំ១៩៧០ និងឆ្នាំ១៩៨០ ចលនាស្ត្រីនិយមចាប់ផ្តើមសារជាថ្មី និងពេលវេលាដ៏សំខាន់មួយ ដោយផ្តោតលើការរំដោះស្ត្រីឱ្យមានសេរីភាពទៅលើទាំងកម្រិតធនធាន និងវប្បធម៌។ ជាមួយនឹងសកលភាវូបនីយកម្មដែលអនុគ្រោះដល់ទំនាក់ទំនងអន្តរប្រទេស ចលនាស្ត្រីនិយមនាពេលបច្ចុប្បន្ន អាចធ្វើសកម្មភាពក្នុងក្របខណ្ឌស្ថាប័នច្រើនកម្រិត ចាប់ពីថ្នាក់មូលដ្ឋាន រហូតដល់អន្តរជាតិ ។

### ចលនាស្ត្រីនិយមលោកខាងលិច ឬស្ត្រីនិយម

ចលនាស្ត្រីនិយមលោកខាងលិចបានវិវត្តនៅទ្វីបអាមេរិក និងទ្វីបអឺរ៉ុបអំឡុងទសវត្សរ៍ឆ្នាំ១៩៦០ ។ គោលគំនិតនៃចលនាស្ត្រីនិយមនេះ ភាគច្រើនត្រូវបានកំណត់ដោយស្ត្រីនៅសហរដ្ឋអាមេរិក។ រលកនៃចលនាស្ត្រីនិយមនេះ គឺជាការឆ្លើយតបទៅនឹងការរឹតបន្តឹង ដែលស្ត្រីលោកខាងលិចបានស៊ូទ្រាំក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ។ ពេញមួយប្រវត្តិសាស្ត្រលោកខាងលិច ស្ត្រីត្រូវបានកំណត់ឱ្យនៅក្នុងបរិបទជីវិតនៅក្នុងផ្ទះ ហើយបុរសនៅក្នុងជីវិតនៅក្រៅផ្ទះ។ តួនាទីអចិន្ត្រៃយ៍ នៅក្នុងសង្គមបិតាធិបតេយ្យទាំងនេះ ត្រូវបានពន្យល់តាមរយៈតួនាទីយេនឌ័រតែមួយ ដែលជាហេតុនាំឱ្យស្ត្រីនិយមលោកខាងលិចបានចាប់ផ្តើមរើបំរះ (cf. Brunell & Burkett) ។ យោងតាមប្រវត្តិសាស្ត្រគេឃើញមានចលនា (Wave) ចំនួន ៣ផ្សេងគ្នានៃចលនាស្ត្រីនិយម។ ទោះជាយ៉ាងណាក៏ដោយ វាជារឿងសំខាន់ដែលត្រូវដឹងថា «វ៉េហ្វ» នៅក្នុងបរិបទនេះមិនមែនពិពណ៌នាអំពីចលនារលូនដែលវិវត្តដូចរលកទេ ប៉ុន្តែជាចលនាដែលចាប់ផ្តើមដោយការប្រយុទ្ធ និងការតវ៉ា ដែលដើរតួជាពេលវេលាសំខាន់ដែលសម្គាល់ការចាប់ផ្តើមនៃរលកស្ត្រីនិយមថ្មី (cf. Stokowski 2016, 134) ។

រលកលោកខាងលិចដំបូងនៃចលនាស្ត្រីនិយម គឺចាប់ផ្តើមនៅចុងបញ្ចប់នៃសតវត្សទី១៩ និងនៅដើមសតវត្សទី២០ (ឆ្នាំ១៨៨០ ដល់ឆ្នាំ១៩២០)។ ចលនានេះពាក់ព័ន្ធនឹងសិទ្ធិទ្រព្យសម្បត្តិ និងបញ្ហាចំបងជាបណ្តុំទាក់ទងនឹងសិទ្ធិបោះឆ្នោតរបស់ស្ត្រី។ ការតវ៉ានាពេលក្រោយមកបានរួមបញ្ចូលប្រាក់ឧបត្ថម្ភគ្រួសារ ការពន្យារកំណើត ការរំលូតកូន សិទ្ធិសុខុមាលភាព៖ ការងារផ្ទះ ការលះបង់ និងទំនួលខុសត្រូវក្នុងភាពជាម្តាយ ការការពារ ក្របខណ្ឌច្បាប់ និងឋានៈផ្លូវច្បាប់របស់ស្ត្រី។ រលកស្ត្រីនិយមអាមេរិកទី១បានបញ្ចប់ជាមួយនឹងវិសោធនកម្មលើកទី១៩ នៅក្នុងរដ្ឋធម្មនុញ្ញរបស់សហរដ្ឋអាមេរិកក្នុងឆ្នាំ១៩១៩ ដែលផ្តល់សិទ្ធិឱ្យស្ត្រីក្នុងការចូលរួមបោះឆ្នោត (cf. Drucker 2018)។

[1] https://ehne.fr/en/encyclopedia/themes/gender-and-europe/feminisms-and-feminist-movements/feminisms-and-feminist-movements-in-europe

រលកទី២ បានចាប់ផ្តើមនៅក្នុងទសវត្សរ៍ឆ្នាំ១៩៤០ និងឈានដល់ចំណុចខ្ពស់បំផុតក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ និង ឆ្នាំ១៩៧០។ ក្នុងសម័យនោះ ស្ត្រីបានតស៊ូទាមទារសិទ្ធិសង្គមស្មើគ្នា។ ពាក្យស្លោកនៃចលនានាពេលនោះគឺ «បុគ្គលភាពគឺជានយោបាយ» ដែលប្រកួតប្រជែងនឹងជំនឿទូទៅថាស្ត្រីអាចមានអត្តសញ្ញាណបានតែតាមរយៈបុរស និងកូនៗ ក្នុងនាមជាប្រពន្ធ និងជាម្តាយប៉ុណ្ណោះ។[2]

រលកទី៣ នៃភាពជាស្ត្រីនិយមបានលេចឡើងនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០។ រលកនេះត្រូវបានដឹកនាំដោយ ជំនាន់អ៊ិច (Generation Xers) ជាប្រជាជនដែលកើតក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៦០ និង ៧០ នៅក្នុងប្រទេសអភិវឌ្ឍន៍ ដោយជាជំនាន់មួយដែលមានប្រព័ន្ធផ្សព្វផ្សាយទូលំទូលាយ ពោរពេញដោយវប្បធម៌ នឹងសេដ្ឋកិច្ចសំបូរបែប។ ទោះបីជាពួកគេទទួលបានអត្ថប្រយោជន៍យ៉ាងសំខាន់ពីសិទ្ធិ និងការការពារផ្លូវច្បាប់ ដែលទទួលបានពីចលនាស្ត្រីនិយមរលកទី១ និងទី២ក៏ដោយ ក៏ពួកគេនៅមានមតិរិះគន់ទៅលើមុខតំណែង និងអ្វីដែលពួកគេមាន ហើយថាជាការងារដែលមិនទាន់បញ្ចប់នៅឡើយទេ ពីចលនាស្ត្រីនិយមរលកទី២។[3]

## ស្ត្រីនិយមនៅលោកខាងត្បូង

ចលនាស្ត្រីនិយម នៅភាគខាងត្បូង ត្រូវគេស្គាល់ថាជាចលនាស្ត្រីនិយម ដែលរិះគន់ទៅលើចលនាស្ត្រីនិយមលោកខាងលិច និងទ្រឹស្តីទាំងក្នុងរលកទី១ និងទី២ ហើយផ្តោតទៅលើបញ្ហាជាក់លាក់របស់ស្ត្រី និងវិសមភាពយេនឌ័រនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ប្រធានបទ «ស្ត្រីដែលងាយរងគ្រោះក្នុងប្រទេសកំពុងអភិវឌ្ឍន៍» ត្រូវបានគេចាប់ផ្តើមយកចិត្តទុកដាក់ដំបូងបំផុត ពីសំណាក់ធនាគារពិភពលោក នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៧០ ។ ស្របពេលជាមួយគ្នានឹង «ទសវត្សរ៍សម្រាប់ស្ត្រី» របស់អង្គការសហប្រជាជាតិ (ឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៨៥) ធនាគារពិភពលោកបានចាប់ផ្តើមស៊ើបអង្កេតពីស្ថានភាពជាក់ស្តែងរបស់ស្ត្រីនៅបណ្តាប្រទេសក្រីក្រ ទាក់ទងនឹងការងារចូលរួមក្នុងវិស័យផ្សេងៗ រួមទាំងការអប់រំ ទឹកស្អាត សុខភាពមាតា ផលិតកម្មស្បៀងអាហារ និងកសិកម្ម។ បញ្ហាទាក់ទងនឹងសិទ្ធិ និងការទទួលស្គាល់ផ្លូវច្បាប់របស់ស្ត្រីត្រូវបានរកឃើញ។ ការស្រាវជ្រាវទៅលើប្រធានបទទាំងនេះត្រូវបានផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងឡើង ហើយសន្និសីទ និងសិក្ខាសាលាជាច្រើនត្រូវបានរៀបចំឡើង។ ការវាយតម្លៃគម្រោងក៏បានចាប់ផ្តើមរួមបញ្ចូល នូវការផ្តោតសំខាន់លើផលប៉ះពាល់ ដែលអាចគម្រោងអាចមានទៅលើស្ត្រីផងដែរ។

ចលនាស្ត្រីនិយម នៅភាគខាងត្បូងពិភពលោក អំពាវនាវឱ្យមានការយកចិត្តទុកដាក់កាន់តែខ្លាំងចំពោះស្ត្រីនៅក្នុងប្រទេសកំពុងអភិវឌ្ឍ ដោយផ្តោតទៅលើការអភិវឌ្ឍ និងការអនុវត្តគោលនយោបាយ និងសង្កត់ធ្ងន់លើការទាមទារឱ្យមានការរួមបញ្ចូលផលប្រយោជន៍ស្ត្រី ទៅក្នុងដំណើរការអភិវឌ្ឍ។ មានវិធីសាស្ត្រចំនួន៣ ត្រូវបានបង្កើត ណែនាំ និងអនុវត្តទៅក្នុងគម្រោងអភិវឌ្ឍន៍ដោយអ្នកសិក្សាអំពីស្ត្រីនិយម និងអ្នកជំនាញផ្នែកអភិវឌ្ឍន៍នៅលើពិភពលោក រួមទាំងស្ត្រីនិយមមកពីភាគខាងត្បូងពិភពលោកផងដែរ។ វិធីសាស្ត្រចំនួន៣ ត្រូវបានគេស្គាល់យ៉ាងច្បាស់ថាជា «ស្ត្រីក្នុងការអភិវឌ្ឍ» (WID) «ស្ត្រី និងការអភិវឌ្ឍ» (WAD) និង «យេនឌ័រ និងការអភិវឌ្ឍ» (GAD)។

ចលនាស្ត្រីក្នុងការអភិវឌ្ឍ (WID) ទទួលបានសន្ទុះក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ដែលត្រូវបានជំរុញដោយការងើបឡើងវិញនៃចលនារបស់ស្ត្រីនៅក្នុងប្រទេសអភិវឌ្ឍន៍ និងជាពិសេសតាមរយៈចលនាស្ត្រីនិយមសេរី ដែលខិតខំទាមទារសិទ្ធិ និងឱកាសការងារស្មើគ្នា នៅសហរដ្ឋអាមេរិក ដោយគិតស្មានថាភាពលំបាករបស់ស្ត្រីនៅក្នុងសង្គម អាចត្រូវបានលុបចោលតាមរយៈការលុបបំបាត់ការរំពឹងទុករបស់សង្គមបែបប្រពៃណីទៅលើស្ត្រី ដោយផ្តល់ឱ្យនូវការអប់រំកាន់តែប្រសើរដល់ស្ត្រី និងការបង្កើតឱ្យមានកម្មវិធីដែលផ្តល់ឱកាសស្មើគ្នា ដែលឥទ្ធិពលគួរឱ្យកត់សម្គាល់លើការបង្កើតវិធីសាស្ត្រ ស្ត្រីក្នុងការអភិវឌ្ឍ (WID) ។

[2] https://www.grin.com/document/1243735?lang=en#:~:text=Western%20feminism%20evolved%20in%20America,endure%20in%20their%20daily%20lives
[3] https://www.britannica.com/topic/feminism/The-third-wave-of-feminism
[4] https://www.worldbank.org/en/archive/history/exhibits/Women-in-Development-and-the-World-Bank-Group

ស្ត្រី និងការអភិវឌ្ឍ (WAD) គឺជាទ្រឹស្តី និងការអនុវត្តសម្រាប់ការអភិវឌ្ឍ។ វិធីសាស្ត្រនេះត្រូវបានណែនាំ នៅក្នុងកម្មវិធីសិក្សាអាហារូបករណ៍សិក្សាអំពីយេនឌ័រ នៅពាក់កណ្តាលទី២ នៃទសវត្សរ៍ឆ្នាំ ១៩៧០ ដែលយើងអាចដឹងពីប្រភពដើមរបស់វាថា ត្រូវបានលើកឡើងដំបូងនៅក្នុងសន្និសីទពិភពលោកលើកទី១ ស្តីពីស្ត្រី នៅទីក្រុងម៉ិកស៊ិកក្នុងឆ្នាំ១៩៧៥ ដែលរៀបចំដោយអង្គការសហប្រជាជាតិ។ ស្ត្រី និងការអភិវឌ្ឍកើតចេញពីទ្រឹស្តីដែលលេចធ្លោ គឺ ស្ត្រីក្នុងការអភិវឌ្ឍ (WID) ហើយច្រើនតែត្រូវបានគេច្រឡំថា WID ប៉ុន្តែវាមានលក្ខណៈខុសគ្នាច្រើន។

វិធីសាស្ត្រយេនឌ័រ និងការអភិវឌ្ឍ (GAD) ផ្តោតលើភាពខុសគ្នាក្នុងសង្គមរវាងបុរស និងស្ត្រី តម្រូវការក្នុងការដោះស្រាយបញ្ហាក្នុងតួនាទី និងទំនាក់ទំនងយេនឌ័រដែលមានស្រាប់ ព្រមទាំងការបង្កើត និងឥទ្ធិពលនៃភាពខុសគ្នានៃការបែងចែកឋានៈក្នុងការអភិវឌ្ឍ។ វិធីសាស្ត្រនេះត្រូវបានជះឥទ្ធិពលយ៉ាងសំខាន់ពីសំណាក់សំណេរសិក្សា របស់អ្នកប្រាជ្ញដូចជា អូខ្លេ (Oakley) (១៩៧២) និង រ៉ូប៊ីន (Rubin) (១៩៧៥) ដែលអះអាងថាទំនាក់ទំនងសង្គមរវាងបុរសនិងស្ត្រី បានធ្វើអោយស្ត្រីជាអ្នកនៅក្រោមបង្គាប់ជាប្រព័ន្ធ រួមជាមួយនឹងអ្នកប្រាជ្ញសេដ្ឋវិទូ ឡូត បឺណឺរៀ និង អាម៉ាទីយ៉ា សេន (Lourdes Benería and Amartya Sen ) (១៩៨១) ដែលវាយតម្លៃផលប៉ះពាល់នៃអាណានិគមនិយម លើការអភិវឌ្ឍ និងវិសមភាពយេនឌ័រ។[5]

ចលនាស្ត្រីនិយម (Feminist) សំដៅលើស្ត្រីដែលតស៊ូមតិ និងលើកកម្ពស់សិទ្ធិស្ត្រី និងក្មេងស្រី។ ចលនាស្ត្រីនិយម មិនត្រឹមតែតស៊ូមតិដើម្បីសិទ្ធិស្ត្រី និងក្មេងស្រីប៉ុណ្ណោះទេ ប៉ុន្តែដើម្បីសិទ្ធិរបស់បុរស និងក្រុមអ្នកមានយេនឌ័រចម្រុះទាំងអស់ និងសិទ្ធិ និងសមភាពរបស់ជនជាតិដើមភាគតិច សិទ្ធិជនមានពិការភាព និងក្រុមងាយរងគ្រោះដែលរស់នៅក្នុងតំបន់ជនបទ និងទីប្រជុំជន ដើម្បីធានា ថាពួកគេមានសមភាព ក្នុងការទទួលបានធនធាន ព័ត៌មាន ការថែទាំសុខភាព សេដ្ឋកិច្ច គ្មានអំពើហិង្សា និងរស់នៅក្នុងកន្លែងមានសុវត្ថិភាព បរិស្ថានល្អ និងសុខុមាលភាព ។[6]

## ចលនាស្ត្រី និងសមភាពយេនឌ័រ នៅកម្ពុជា

ស្ត្រី និងចលនាស្ត្រីនិយមនៅកម្ពុជា មិនត្រូវបានកត់ត្រា ឬសិក្សាលម្អិតឱ្យបានទូលំទូលាយទេ។ ទោះយ៉ាងណាក៏ដោយ ថ្មីៗនេះមានអ្នកសិក្សាបរទេសជាច្រើននាក់ បានរួមសហការជាមួយអ្នកសិក្សានៅកម្ពុជាក្នុងការសរសេរអំពីសារៈសំខាន់នៃតួនាទីស្ត្រីក្នុងកិច្ចការសាធារណៈ ជាពិសេសស្ត្រីក្នុងវិស័យនយោបាយ។ ដូច្នេះ មានឯកសារជាច្រើនត្រូវបានចងក្រង និងកត់ត្រាទាក់ទងនឹងចលនាសង្គមរបស់ស្ត្រី ដែលបានកើតឡើងជាច្រើនបន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ និងជាពិសេសនៅពេលដែល «កិច្ចព្រមព្រៀងទីក្រុងប៉ារីស» ត្រូវបានចុះហត្ថលេខានៅឆ្នាំ១៩៩១ និងការបោះឆ្នោតលើកដំបូងនៅឆ្នាំ១៩៩៣ ដែលស្ថិតនៅក្រោមការសម្របសម្រួលរបស់អង្គការសហប្រជាជាតិ។

ការទាមទារសិទ្ធិស្ត្រីចំពោះសុខភាព ការអប់រំ សន្តិភាព និងការអភិវឌ្ឍត្រូវបានធ្វើឡើង ទោះបីជាមានការប្រឈម និងឧបសគ្គជាច្រើនក្នុងការជំរុញសិទ្ធិទាំងនេះក្នុងអំឡុងពេលនោះក៏ដោយ។ ចលនាមួយចំនួនត្រូវបានកំណត់គោលដៅច្បាស់លាស់ ពោលគឺទាមទារឱ្យមានការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យនយោបាយ ជាពិសេសទៅលើ «សិទ្ធិបោះឆ្នោត» ហើយចលនាទាំងនេះត្រូវបានដំណើរការបន្តិចម្តងៗ រហូតឈានដល់ចំណុចដែលស្ត្រីមួយចំនួនត្រូវបានតែងតាំងឱ្យចូលរួមក្នុងចលនានយោបាយដោយអ្នកដឹកនាំគណៈបក្សនយោបាយធំៗមួយចំនួន។

សមាគម និងអង្គការសង្គមស៊ីវិលជាច្រើន ដែលមានស្ត្រីជាអ្នកដឹកនាំ បានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជាតាំងពីពេលនោះមក ហើយពួកគេជាច្រើនបានបន្តដំណើរការរហូតដល់សព្វថ្ងៃនេះ ដើម្បីបន្តលើកកម្ពស់សិទ្ធិស្ត្រី ។[7]

[5] https://en.wikipedia.org/wiki/Gender_and_development#Gender_and_development_(GAD)
[6] Collective definition from the six feminist organizations in Cambodia
[7] Journal of Current Southeast Asian Affaire – Social movement in Cambodia, April 2019

បច្ចុប្បន្ននេះ អង្គការ ឬសមាគមដែលដឹកនាំស្ត្រីនៅក្នុងប្រទេសកម្ពុជា ត្រូវបានទទួលស្គាល់នូវតួនាទី និងការរួមចំណែកយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយ និងលើកកម្ពស់សិទ្ធិស្ត្រីនៅកម្ពុជា។ ស្ថាប័នដ៏សំខាន់មួយ ក្នុងការលើកកម្ពស់ និងគាំទ្រសិទ្ធិស្ត្រីនៅកម្ពុជា គឺក្រសួងកិច្ចការនារី (MoWA) ដែលបង្កើតឡើងក្រោមរដ្ឋលេខាធិការដ្ឋានកិច្ចការនារី ក្នុងឆ្នាំ១៩៩៣។ ក្រសួងកិច្ចការនារី គឺជាយន្តការថ្នាក់ជាតិឈានមុខគេ សម្រាប់ការលើកកម្ពស់ស្ត្រីនៅកម្ពុជាដោយត្រូវបានបង្កើតឡើងដើម្បីដឹកនាំ សម្របសម្រួល ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីសមភាពយេនឌ័រ និងការពង្រឹងសិទ្ធិអំណាចរបស់ស្ត្រី។

ក្រសួងកិច្ចការនារី ដើរតួនាទីជាកាតាលីករ និងជាអ្នកតស៊ូមតិដើម្បីលើកទឹកចិត្តដល់ស្ថាប័នសាធារណៈ អង្គការសង្គមស៊ីវិល និងវិស័យឯកជនឱ្យធ្វើសមាហរណកម្ម សមភាពយេនឌ័រទៅក្នុងគោលនយោបាយ និងកម្មវិធីរបស់ពួកគេ។ ស្ថាប័ននេះក៏មានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃគោលនយោបាយ និងកម្មវិធីរបស់រដ្ឋាភិបាល ក្នុងគោលបំណងសម្រេចបានសមភាពយេនឌ័រ។[8]

ទោះយ៉ាងណាក៏ដោយ បញ្ហាប្រឈមជាច្រើននៅតែជាឧបសគ្គ ហើយត្រូវការកិច្ចខិតខំប្រឹងប្រែង និងយន្តការដ៏មានប្រសិទ្ធភាព ដើម្បីតស៊ូមតិសម្រាប់ការកែលម្អ និងអនុវត្តសិទ្ធិស្ត្រីនៅកម្ពុជា។

## សមភាពយេនឌ័រភាពចម្រុះ និងគោលគំនិតនៃសង្គមដែលមានបរិយាបន្ន

ផ្នែកនេះផ្តល់នូវនិយមន័យខ្លីៗ ឬទស្សនៈនៃយេនឌ័រ ភេទ សមភាព និងសមធម៌យេនឌ័រ និងបរិយាបន្នសម្រាប់ចំណេះដឹងជាមូលដ្ឋាន និងការយល់ដឹងទូទៅរបស់អ្នកចូលរួម។

### យេនឌ័រ និងភេទ

យេនឌ័រ សំដៅលើការកំណត់របស់សង្គម និងឱកាសក្នុងសង្គមដែលទាក់ទងនឹងភាពជាបុរស និងស្ត្រី ក៏ដូចជាទំនាក់ទំនងរវាងស្ត្រី និងបុរស និងរវាងក្មេងស្រី និងក្មេងប្រុស ព្រមទាំងទំនាក់ទំនងរវាងស្ត្រី និងស្ត្រី និងរវាងបុរស និងបុរសផងដែរ។ ការកំណត់របស់សង្គម និងឱកាសក្នុងសង្គមទាំងនេះត្រូវបានកសាងឡើងក្នុងសង្គម ហើយត្រូវបានសិក្សាតាមរយៈដំណើរការសង្គមភាវូបនីយកម្ម។ ទាំងអស់នេះអាស្រ័យលើបរិបទ និងពេលវេលាជាក់លាក់ ហើយអាចផ្លាស់ប្តូរបានទៅតាមពេលវេលា។ ជាទូទៅ យេនឌ័រកំណត់នូវអ្វីដែលត្រូវបានរំពឹងទុក អនុញ្ញាត និងផ្តល់តម្លៃចំពោះស្ត្រី ឬបុរសនៅក្នុងបរិបទណាមួយ។ នៅក្នុងសង្គមភាគច្រើនមានភាពខុសប្លែកគ្នា និងវិសមភាពរវាងស្ត្រី និងបុរសទៅលើទំនួលខុសត្រូវដែលគេដាក់ឱ្យ សកម្មភាពដែលទទួលខុសត្រូវ ការទទួលបាន និងការគ្រប់គ្រងលើធនធាន ក៏ដូចជាឱកាសដើម្បីធ្វើការសម្រេចចិត្ត ។[9]

ភាគច្រើន យេនឌ័រត្រូវបានគេសម្គាល់ទៅលើភេទទាំងពីរគឺ ស្ត្រី ឬក៏បុរស។ «អត្តសញ្ញាណយេនឌ័រ និងភាពចម្រុះនៃយេនឌ័រ» ត្រូវបានប្រើដើម្បីធានាបាននូវបរិយាបន្ន ទាំងនៅក្នុងវិធីសាស្ត្រ និងការទំនាក់ទំនង។ យេនឌ័រ ខុសពី «ភេទ»។ ភេទ សំដៅលើភាពខុសគ្នាខាងផ្នែកជីវសាស្ត្ររវាងបុរស និងស្ត្រី។ មនុស្សស្រី និងមនុស្សប្រុស កើតមកមានសរីរាង្គបន្តពូជខុសគ្នា។

តារាងខាងក្រោមបានសង្ខេបពីភាពខុសគ្នារវាងយេនឌ័រ និងភេទ។

[8] https://www.mowa.gov.kh/en/history
[9] Gender Lens in Social & Behaviour Change Guideline, UNICEF Ethiopia, 2022

| ភេទ | យេនឌ័រ |
| --- | --- |
| កំណត់ដោយកត្តាជីវសាស្ត្រ | កំណត់ដោយសង្គម |
| សម្រាប់មនុស្សទូទៅក្នុងសកលលោក | ពហុលក្ខណៈ៖ វប្បធម៌ និងតាមទីតាំងភូមិសាស្ត្រ លក្ខខណ្ឌអាកាសធាតុ។ល។ |
| មិនអាចផ្លាស់ប្តូរបាន | មានភាពថាមវន្ត អាចផ្លាស់ប្តូរបានតាមពេលវេលា |

## សមភាពយេនឌ័រ និងសមធម៌យេនឌ័រ[10]

សមភាពយេនឌ័រ គឺជាសមភាពរវាងយេនឌ័រទាំងអស់ រួមបញ្ចូលនូវទស្សនៈដែលថាមនុស្សទាំងអស់មានសេរីភាពក្នុងការអភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួនរបស់ពួកគេ និងធ្វើការជ្រើសរើសដោយគ្មានដែនកំណត់ ផ្តត់គំនិតយេនឌ័រ តួនាទីយេនឌ័រដែលមានលក្ខណៈរឹងមាំ និងការរើសអើង។

សមភាពយេនឌ័រ មានន័យថាឥរិយាបថ សេចក្តីប្រាថ្នា និងតម្រូវការខុសៗគ្នារបស់ស្ត្រី និងបុរស ត្រូវបានគិតគូរ ផ្តល់តម្លៃ និងអនុគ្រោះស្មើៗគ្នា។ វាមិនមែនមានន័យថាស្ត្រី និងបុរស និងអ្នកចម្រុះយេនឌ័រត្រូវតែដូចគ្នានោះទេ ប៉ុន្តែបានន័យថាសិទ្ធិ ទំនួលខុសត្រូវ និងឱកាសរបស់បុគ្គលម្នាក់គឺមិនអាស្រ័យលើថាតើមនុស្សម្នាក់កើតមកជាបុរស ឬស្ត្រី ឬពីរបៀបដែលពួកគេកំណត់អត្តសញ្ញាណខ្លួនឯងនោះទេ។

សមធម៌យេនឌ័រ គឺជាការផ្តល់ឱ្យដោយសមស្រប និងយុត្តិធម៌ នូវឱកាស សិទ្ធិ ទំនួលខុសត្រូវ និងអត្ថប្រយោជន៍រវាងស្ត្រី និងបុរស (រួមទាំងអ្នកចម្រុះយេនឌ័រ ជាតិសាសន៍ និងជនមានពិការភាព) ក្នុងផ្នែកនៃសង្គម សេដ្ឋកិច្ច វប្បធម៌ ច្បាប់ និងនយោបាយ។ វាទាក់ទងនឹងសេរីភាពនៃការជ្រើសរើស និងការបែងចែកឥទ្ធិពលប្រកបដោយសមធម៌រវាងបុរស និងស្ត្រី។

**រូបភាពទី១ និងទី២៖ ភាពខុសគ្នារវាងសមភាព និងសមធម៌**




និយមន័យមួយផ្សេងទៀតគឺ៖ សមភាពយេនឌ័រ មានន័យថា ភាពយុត្តិធម៌នៃការអនុវត្តចំពោះមនុស្សគ្រប់រូប អាស្រ័យតាមតម្រូវការរៀងៗខ្លួន។

ទាំងនេះអាចរាប់បញ្ចូលទាំងការអនុវត្តស្មើៗគ្នា ឬខុសគ្នា ប៉ុន្តែត្រូវបានធ្វើឱ្យសមស្របតាមលក្ខខណ្ឌ សិទ្ធិ អត្ថប្រយោជន៍ កាតព្វកិច្ច និងឱកាស។

10] Author's description by adapted from various training manuals and based on outcome from capacity need assessment and consultation workshop

## បរិយាបន្នសង្គម

បរិយាបន្នសង្គម គឺជាការកាត់បន្ថយវិសមភាពរវាងក្រុមដែលជួបការលំបាកក្នុងសង្គម និងបុគ្គលក្នុងសង្គមដទៃទៀត។ ករណីនេះអាចសម្រេចទៅបាន ដោយទប់ស្កាត់គម្លាតនិងបង្កើតឱកាសតូចទៅតាមបរិយាកាសដែលអំណោយផលសម្រាប់ពួកគេក្នុងការចូលរួមកាន់តែច្រើនប្រកបដោយសមធម៌។ វាគឺជាសកម្មភាព ឬវិធីសាស្ត្រនៃការបង្កើនការចូលរួមដោយស្មើភាពគ្នា ក្នុងដំណើរការមួយ ដែលជំរុញឱ្យមានសុខុមាលភាព និងធ្វើការបង្កើតទម្រង់សង្គមមួយប្រកបដោយ សេរីភាពស្មើគ្នា និងបរិយាកាសល្អសម្រាប់មនុស្សក្នុងការបន្តការអភិវឌ្ឍរបស់ខ្លួន ។[11]




## ក្របខណ្ឌសមភាពយេនឌ័រ និងការអនុវត្តនៅក្នុងគម្រោងសកម្មភាពស្ត្រីនិយម (FIA)

ផ្នែកនេះបង្ហាញពីទ្រឹស្តីដែលគាំទ្រក្របខណ្ឌសមភាពយេនឌ័ររបស់អង្គការយែរ និងរបៀបដែលក្របខណ្ឌនេះត្រូវបានប្រើប្រាស់ដើម្បីឆ្លុះបញ្ចាំងពីគម្រោងសកម្មភាពស្ត្រីនិយម (FiA) នៅក្នុងប្រទេសកម្ពុជា។ រូបភាពខាងក្រោមបង្ហាញពីចំនុចនៃការផ្លាស់ប្តូរ ដើម្បីលើកកម្ពស់ និងគាំទ្រសមភាពយេនឌ័រ ក៏ដូចជាគោលបំណងសម្រាប់ការបង្កើតបរិយាកាសប្រកបដោយបរិយាបន្ននៅក្នុងតំបន់គោលដៅគម្រោង។




[11] SNV SSH4A GESI Guideline, 2012

**ក្របខណ្ឌសមភាពយេនឌ័រ (GEF) របស់អង្គការឃែរ** គឺជាវិធីសាស្ត្រគ្របដណ្តប់ដ៏ទូលំទូលាយមួយ នៅក្នុងការងារទាំងអស់របស់អង្គការឃែរ។ វាត្រូវបានបង្កើតឡើងដើម្បីជួយបុគ្គលិកអង្គការឃែរ ក្នុងការបង្កើតគំនិត និងរៀបចំផែនការសមភាពយេនឌ័រ និងកម្មវិធីទាក់ទងនឹងភាពចម្រុះ ។ វាបង្កើតនៅលើក្របខណ្ឌ និងឧបករណ៍របស់អង្គការឃែរដែលមានស្រាប់ ជាពិសេសក្របខណ្ឌពង្រឹងសិទ្ធិអំណាចរបស់ស្ត្រី ដែលកំណត់ការពង្រឹងសិទ្ធិអំណាចរបស់ស្ត្រីថាជា លទ្ធផលចុងក្រោយនៃការផ្លាស់ប្តូរដែលត្រូវការ គាំទ្រដល់ស្ត្រី និងភាពចម្រុះ ដើម្បីដឹងពីសិទ្ធិមនុស្សពេញលេញរបស់ពួកគេនៅក្នុង៖

- ភ្នាក់ងារ៖ បំណងប្រាថ្នា និងសមត្ថភាពរបស់ពួកគេផ្ទាល់
- រចនាសម្ព័ន្ធ៖ បរិយាកាសជុំវិញខ្លួនគេ និងលក្ខខណ្ឌនៃជម្រើសរបស់ពួកគេ និង
- ទំនាក់ទំនង៖ ទំនាក់ទំនងអំណាចដែលស្ត្រី ឬក្រុមស្ត្រី ចរចាសម្រាប់ដំណើរជីវិតរបស់ស្ត្រី ឬក្រុមស្ត្រី

## សមភាពយេនឌ័រ និងបរិយាបន្នសង្គម (GESI) ក្នុងការគ្រប់គ្រងវដ្តគម្រោង សកម្មភាពស្ត្រីនិយម (FIA)[12]

គម្រោង ឬកម្មវិធីមានគោលបំណងលើកកម្ពស់សមភាពយេនឌ័រ ភាពចម្រុះ និងបរិយាបន្នសង្គមក្នុងការអនុវត្តគម្រោងរបស់ពួកគេ ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ខ្ពស់ លើចំណុចសំខាន់ៗចំនួន៦ នៃបទអន្តរាគមន៍ក្នុងការគ្រប់គ្រងវដ្តគម្រោង។ រាល់បទអន្តរាគមន៍ទាំងនេះ គឺចាំបាច់ខ្លាំង ប្រសិនបើគម្រោងណាមួយ មានគោលដៅសម្រេចបាននូវសមភាពយេនឌ័រ ភាពចម្រុះ និងបរិយាបន្នក្នុងសង្គម។ រូបភាពខាងក្រោមផ្តល់នូវបទអន្តរាគមន៍នីមួយៗ នៃការគ្រប់គ្រងវដ្តគម្រោង និងការបរិយាយសង្ខេបនៃបទអន្តរាគមន៍ ហើយប្រតិបត្តិការ ក៏ត្រូវបានផ្តល់ជូនក្នុងតារាងខាងក្រោមនេះដែរ។




[12] Adapted from training of trainer workshop manual from CARE Canada (Make it real: Gender Equality in everyday project management).

| បទអន្តរាគមន៍ GESI | និយមន័យ | ការអនុវត្ត |
|---|---|---|
| ការវិភាគទាក់ទងនឹង GESI (GESI analysis) | ដើម្បីធ្វើការវិភាគយេនឌ័រ យើងអាចប្រើប្រាស់ឧបករណ៍វិភាគអំណាចយេនឌ័ររបស់អង្គការឃែរ[13] ដើម្បីជៀសវាងការសន្មតអំពីអ្វីដែលស្ត្រី និងបុរស ជនមានពិការភាព ជាតិសាសន៍ និងភាពចម្រុះយេនឌ័រធ្វើ ដើម្បីពួកគេអាចយល់អំពីទំនាក់ទំនងអំណាចយេនឌ័រចម្រុះនៅក្នុងក្រុមមនុស្សផ្សេងៗគ្នាក្នុងបរិបទមួយ និងបង្កើតផែនការសមស្របដើម្បី ដោះស្រាយតម្រូវការនៃភាពចម្រុះនៃបុគ្គល និងក្រុម។ | **ពេលវេលា៖** ការវិភាគ GESI ត្រូវធ្វើនៅដើមដំបូង ឬនៅពេលសរសេរសំណើរសម្រាប់ការវិភាគបរិបទ។ **ភស្តុភារ និងសមត្ថភាព៖** រួមបញ្ចូល បុរស និងស្ត្រី និងភាពចម្រុះយេនឌ័រ ជាតិសាសន៍ និងពិការភាព តាមភាពសមស្របនៅក្នុងក្រុមការងារវិភាគ ហើយធានាថាអ្នកគ្រប់គ្នាមានចំណេះដឹងគ្រប់គ្រាន់អំពីយេនឌ័រ និងចំណេះដឹងផ្នែក GESI ដូចជាការសម្ភាសន៍ និងជំនាញសួរដេញដោល ក៏ដូចជាជំនាញវិភាគយេនឌ័រ ដែលវានឹងត្រូវការជាចាំបាច់។ |
| បញ្ហាទាក់ទងនឹង GESI | ផ្តត់គំនិតសង្គម និងការអនុវត្ត បង្កើតជាឧបសគ្គដល់ស្ត្រី និងបុរស ភាពចម្រុះយេនឌ័រ និងអន្តរប្រសព្វរបស់មនុស្ស ដើម្បីធានាចំពោះការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការអនុវត្តពេញលេញនូវសិទ្ធិមនុស្សជាមូលដ្ឋាន។ បញ្ហា GESI ត្រូវបានកំណត់អត្តសញ្ញាណដោយធ្វើការវិភាគ GESI និងកំណត់យុទ្ធសាស្ត្រដើម្បីលុបបំបាត់បញ្ហា លើកកម្ពស់សមភាពយេនឌ័រ និងបង្កើតបរិយាកាសបែបបរិយាបន្នសម្រាប់ភាពចម្រុះគ្នា នៅក្នុងកន្លែងធ្វើការ នៅក្នុងគ្រួសារ និងក្នុងសហគមន៍។ | **យុទ្ធសាស្ត្រ និងការផ្តោតលើចំនុចសំខាន់** ៖ ត្រូវប្រាកដថា ក្រុមការងារបានលើកយកបញ្ហាដែលទាក់ទងនឹងគម្រោង ហើយវាជារឿងសំខាន់ ដើម្បីធានាថាក្រុមការងារអាចបង្កើតលទ្ធផលឆ្ពោះទៅរកការដោះស្រាយបញ្ហានៅក្នុងរយៈពេលគម្រោង និងដែនកំណត់នៃការងារគម្រោង។ |
| យុទ្ធសាស្ត្រទាក់ទងនឹង GESI | វិធីសាស្ត្រនេះត្រូវបានប្រើដើម្បីធានាថាគម្រោង ឬកម្មវិធីកំពុងដំណើរការឆ្ពោះទៅរកសមភាពយេនឌ័រ និងបរិយាបន្នសង្គម នៅគ្រប់ដំណាក់កាលនៃការអនុវត្តគម្រោង។ យុទ្ធសាស្ត្រនេះ គួរតែរួមបញ្ចូលយ៉ាងច្បាស់នូវគោលដៅយុទ្ធសាស្ត្រ GESI ហានិភ័យ បញ្ហាប្រឈម សកម្មភាព ធនធាន តួនាទី ការទទួលខុសត្រូវរបស់តួអង្គសំខាន់ៗនីមួយៗ និងផែនការវាស់វែងលទ្ធផលផងដែរ។ | **ការអនុវត្ត៖** គណនេយ្យភាពគឺជាគន្លឹះសំខាន់។ វាត្រូវការជាចាំបាច់ដើម្បីកំណត់ថាអ្នកណាជាអ្នកទទួលខុសត្រូវពិតប្រាកដ ហើយអ្នកណាជាក្រុមការងារទទួលខុសត្រូវក្នុងការអនុវត្តយុទ្ធសាស្ត្រ។ ត្រូវប្រាកដថា អ្នកជំនាញ GESI មានវត្តមាន ហើយការបែងចែកថវិកាគឺគ្រប់គ្រាន់ដើម្បីអនុវត្តសកម្មភាពដែលបានកំណត់។ |
| សូចនាករដែលមានលក្ខណៈរសើបទាក់ទងនឹង GESI (GESI sensitive indicators) | បរិមាណ (ទិន្នន័យដែលបែងចែក ភេទ ជនជាតិដើមភាគតិច ពិការភាព និងភាពចម្រុះយេនឌ័រ) របាយការណ៍ជាភាគរយ និងគុណភាពត្រូវបានប្រើដើម្បីវាស់វែង ថាតើការផ្លាស់ប្តូរឆ្ពោះទៅរក GESI បានកើតឡើងដែលជាលទ្ធផលជោគជ័យ ដោយសារសកម្មភាពគម្រោងដែរឬទេ។ | **ភស្តុភារ និងសមត្ថភាព៖** ត្រូវប្រាកដថាក្រុមការងារ និងអ្នកដែលត្រួតពិនិត្យ វាយតម្លៃ និងរៀនសូត្រ (MEAL) មានចំណេះដឹង និងសមត្ថភាពអំពីGESI គ្រប់គ្រាន់ ដើម្បីអាចវិភាគ និងកំណត់សូចនាករសំខាន់ៗ ដើម្បីវាស់ស្ទង់ការផ្លាស់ប្តូរដោយផ្អែកលើបញ្ហាដែលបានរកឃើញពីការវិភាគ GESI។ |

[13] https://www.careemergencytoolkit.org/gender/

| | | |
|---|---|---|
| សកម្មភាពកាត់បន្ថយបញ្ហាទាក់ទងនឹង GESI (Activities to mitigate GESI issues) | កញ្ចប់ការងារជាក់លាក់ សកម្មភាព ឬកិច្ចការរងដែលផ្តោតលើការផ្លាស់ប្តូរផ្នត់គំនិតដែលបង្ករគ្រោះថ្នាក់ អតុល្យភាពទំនាក់ទំនងអំណាចយេនឌ័រ និងរចនាសម្ព័ន្ធវិសមភាពដែលមានផលប៉ះពាល់អវិជ្ជមានដល់ស្ត្រី បុរស ជនមានពិការភាព និងភាពចម្រុះយេនឌ័រ។ ឧទាហរណ៍ ការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំសម្រាប់ស្ត្រី និងក្រុមសន្សំប្រាក់ ការបណ្តុះបណ្តាលលើកកម្ពស់ការយល់ដឹងសម្រាប់បុរស និងក្មេងប្រុស ការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនមានពិការភាព និងភាពចម្រុះនៃយេនឌ័រ ការអប់រំស្តីពីសិទ្ធិពលករចំណាកស្រុក ការបណ្តុះបណ្តាលសិទ្ធិស្ត្រី និងការបណ្តុះបណ្តាលជំនាញជីវិតជាមូលដ្ឋាន ។ល។ | **ជំនាញបច្ចេកទេស និងថវិកា៖** ពិនិត្យមើលធនធានរបស់អ្នក ថាតើអ្នកមានធនធានមនុស្សដែលមានបទពិសោធន៍ និងជំនាញច្បាស់លាស់ក្នុងក្រុមការងារឬទេ។ ការមានអ្នកជំនាញ និងបុគ្គលិកដែលមានសមត្ថភាពខ្ពស់ដើម្បីអនុវត្តសកម្មភាពទាំងនេះ គឺអាចធានាថាការអនុវត្តគម្រោងនឹងទទួលបានលទ្ធផលល្អ។ **យុទ្ធសាស្រ្ត 'មិនបង្កគ្រោះថ្នាក់'៖** ត្រូវប្រាកដថាគម្រោង និងស្ថាប័នរបស់អ្នកមានយុទ្ធសាស្រ្តដើម្បីគ្រោងទុក និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានពីការព្យាយាមផ្លាស់ប្តូរទំនាក់ទំនងអំណាចយេនឌ័រនៅក្នុងសហគមន៍ និងសង្គម។ យុទ្ធសាស្រ្តកាត់បន្ថយហានិភ័យត្រូវបានបង្កើតឡើង និងធានានូវការបែងចែកថវិកាសម្រាប់ផ្នែកនេះ ប្រសិនបើអាចអនុវត្តបាន។ |
| សកម្មភាពគម្រោងដែលមានលក្ខណៈរសើបទាក់ទងនឹង GESI (GESI sensitive project activities) | សកម្មភាពត្រូវបានអនុវត្តក្នុងលក្ខណៈរសើប ទាក់ទងនឹង GESI។ ឧទាហរណ៍ ផ្តល់ការបណ្តុះបណ្តាលដែលផ្តោតលើការងារកសិកម្មផ្សេងៗគ្នារបស់ស្ត្រី និងបុរស ជនមានពិការភាព និងភាពចម្រុះយេនឌ័រ ឬការបណ្តុះបណ្តាលដែលកំពុងដំណើរការ នៅពេលដែលមនុស្សគ្រប់គ្នាមានពេលវេលា និងអាចចូលរួមបាន។ | **សមត្ថភាព៖** ពិនិត្យមើលថាតើគម្រោង និងស្ថាប័នរបស់អ្នកមានធនធាន GESI ដើម្បីអាចអនុវត្តន៍សកម្មភាពទាំងនេះក្នុងលក្ខណៈរសើបទាក់ទងនឹង GESI ដែរឬទេ។ |

## ការចាត់ថ្នាក់សមភាពយេនឌ័រ និងបរិយាបន្នសង្គម (GESI) / ដំណើរនៃការផ្លាស់ប្តូរក្នុងបទអន្តរាគមន៍



គម្រោង ឬកម្មវិធីរបស់អង្គការឃែរជាទូទៅ រួមទាំងអង្គការឃែរកម្ពុជាផងដែរ ជំរុញឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាននូវសិទ្ធិទទួលបានសិទ្ធិរបស់ស្ត្រី ការផ្តល់សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ ការលើកកម្ពស់ជីវភាពរស់នៅ។ គម្រោងសកម្មភាពស្ត្រីនិយម (FiA) មានគោលបំណងបង្កើតបរិយាកាសវិជ្ជមានដែលអាចទទួលយកបាននៅកន្លែងធ្វើការ និងនៅកម្រិតសហគមន៍ ដោយមិនត្រឹមតែកាត់បន្ថយឧបសគ្គប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដោះស្រាយមូលហេតុដែលជាឫសគល់នៃផ្នត់គំនិតសង្គម និងប្រពៃណីដែលបង្កគ្រោះថ្នាក់ដល់សង្គមផងដែរ។

ឧបករណ៍សម្រាប់ធ្វើឱ្យប្រសើរឡើងនូវសមភាពយេនឌ័រ ភាពចម្រុះ និងបរិយាបន្នដែលបានបញ្ចូលទៅក្នុងគម្រោងគឺយេនឌ័រ ឬដំណើរការផ្លាស់ប្តូរបន្តនៃ GESI។ តារាងខាងក្រោមនេះ បង្ហាញពីកម្រិតផ្សេងគ្នានៃការរួមបញ្ចូល GESI អមជាមួយនឹងដំណើរការផ្លាស់ប្តូរបន្តនៃ GESI ក្នុងដំណាក់កាលនីមួយៗ។ ដំណើរការផ្លាស់ប្តូរបន្តនៃ GESIនេះ នឹងជួយក្រុមគម្រោង ឬកម្មវិធី ជាមួយនឹងការវាយតម្លៃនៃសកម្មភាព និងបទអន្តរាគមន៍របស់ពួកគេ ហើយថែមទាំងផ្តល់នូវទិសដៅអំពីរបៀបដែលពួកគេអាចធ្វើឱ្យប្រសើរឡើងនូវបទអន្តរាគមន៍ ឬសកម្មភាពដែលនឹងធានាថា GESI របស់ពួកគេកាន់តែមានលក្ខណៈផ្លាស់ប្រែ។

| **GESI ដែលធ្វើឱ្យបង្កគ្រោះថ្នាក់ ឬមិនដឹង** | **GESI ដែលមើលមិនឃើញ** | **GESI ដែលមានលក្ខណៈរសើប** | **GESI ដែលមានលក្ខណៈឆ្លើយតប** | **GESI ដែលមានលក្ខណៈផ្លាស់ប្រែ** |
|---|---|---|---|---|
| វិធីសាស្ត្រអនុវត្តនៃគម្រោង ឬកម្មវិធី ជំរុញឱ្យមានភាពមិនស្មើភាពនៃ ផ្នត់គំនិតទាក់ទងនឹងGESI ឬមិនផ្តល់សិទ្ធិអំណាចដល់ក្រុមមនុស្សជាក់លាក់ណាមួយក្នុងដំណើរការអនុវត្តនិងសម្រេចបាននូវគោលដៅគម្រោង ឬកម្មវិធី។ | វិធីសាស្ត្រ គម្រោង ឬកម្មវិធី ឬសកម្មភាពដែលដឹងពីបញ្ហា និងឧបសគ្គនៅក្នុងសហគមន៍ ប៉ុន្តែសកម្មភាពមិនត្រូវបានដោះស្រាយយ៉ាងសកម្មនូវផ្នត់គំនិតសង្គម និង ផ្នត់គំនិតទាក់ទងនឹង GESI ដែលបានកើតមានឡើងនោះទេ។ | វិធីសាស្ត្រ ឬកម្មវិធី ឬសកម្មភាព បានទទួលស្គាល់បញ្ហា និងឧបសគ្គ ហើយដោះស្រាយបញ្ហា និងឆ្លើយតបទៅនឹងតម្រូវការរបស់បុគ្គល ឬក្រុម។ បទអន្តរាគមន៍របស់គម្រោង ឬកម្មវិធី មានគោលបំណងពង្រឹងសិទ្ធិនៃការប្រើប្រាស់សេវាកម្ម ប៉ុន្តែសម្រាប់ខ្លួនពួកគេផ្ទាល់ ពួកធ្វើការតិចតួចដើម្បីផ្លាស់ប្តូរបញ្ហាក្នុងបរិបទទូលំទូលាយ ដែលស្ថិតនៅជាឫសគល់នៃវិសមភាព GESI ។ សកម្មភាពទាំងនេះគឺមិនគ្រប់គ្រាន់ឡើយ ដើម្បីផ្លាស់ប្តូរតុល្យភាពនៃអំណាចនៅក្នុងទំនាក់ទំនងយេនឌ័រ និងភាពចម្រុះជាមូលដ្ឋាននោះទេ។ | វិធីសាស្ត្រ ឬកម្មវិធីឬសកម្មភាព ទទួលស្គាល់បញ្ហា និងឧបសគ្គ សកម្មភាពគាំទ្រ និងជួយស្ត្រី បុរស ជនមានពិការភាព ជាតិសាសន៍ និងភាពចម្រុះយេនឌ័រ ពិនិត្យមើលការរំពឹងទុក ផ្នត់គំនិតយេនឌ័រ ឧបសគ្គ និងផលប៉ះពាល់ លើតួនាទីសិទ្ធិ និងទំនាក់ទំនងរបស់ស្ត្រី បុរស និងជនក្រីក្រ។ | វិធីសាស្ត្រ ឬសកម្មភាពរបស់គម្រោង ឬកម្មវិធី ទទួលស្គាល់បញ្ហា និងឧបសគ្គ ដោះស្រាយបញ្ហាយ៉ាងសកម្ម និងកសាងផ្នត់គំនិតសង្គមដែលស្មើភាពគ្នា រចនាសម្ព័ន្ធទំនាក់ទំនង និងអាកប្បកិរិយា និងឥរិយាបថប្រកបដោយសមធម៌ GESI របស់បុគ្គល ឬក្រុម។ |

## និយមន័យ[14]

**ផ្នត់គំនិតយេនឌ័រ៖** គឺជាគំនិតអំពីរបៀបដែលបុរស និងស្ត្រីគួរមាន និងប្រព្រឹត្ត។ យើងបានដឹង និងរៀនពី «ច្បាប់» ទាំងនេះតាំងពីដំណាក់កាលដំបូងក្នុងជីវិត។ ផ្នត់គំនិតនេះបានបង្កើតវដ្តជីវិតនៃទំនាក់ទំនងសង្គមយេនឌ័រ និងការរើសអើងទាក់ទងនឹងយេនឌ័រ។ អាចនិយាយម្យ៉ាងទៀតថា ផ្នត់គំនិតយេនឌ័រ គឺជាស្តង់ដារ និងការរំពឹងទុកដែលអត្តសញ្ញាណយេនឌ័រជាទូទៅ ត្រូវបានអនុលោមក្នុងបែបផែនសង្គម វប្បធម៌ និងសហគមន៍ជាក់លាក់មួយនៅពេលណាមួយនោះ។

**តួនាទីយេនឌ័រ៖** តួនាទីយេនឌ័រសំដៅទៅលើផ្នត់គំនិត និងឥរិយាបថសង្គម ក្នុងវប្បធម៌ជាក់លាក់ណាមួយ ដែលត្រូវបានចាត់ទុកថាជា រឿងធម្មតាក្នុងសង្គមសម្រាប់បុគ្គលម្នាក់ៗ។ ទាំងនេះច្រើនតែកំណត់ទំនួលខុសត្រូវ និងភារកិច្ចតាមទម្លាប់ដែលដាក់ឱ្យបុរស ស្ត្រី ក្មេងប្រុស និងក្មេងស្រីអនុវត្ត។ តួនាទីយេនឌ័រជាក់លាក់ ជារឿយៗត្រូវបានកំណត់លក្ខណៈដោយរចនាសម្ព័ន្ធគ្រួសារ និងការបែងចែកកម្លាំងពលកម្ម ការទទួលបានធនធាន ផលប៉ះពាល់ជាក់លាក់នៃសេដ្ឋកិច្ចពិភពលោក ការកើតឡើងនៃជម្លោះ ឬគ្រោះមហន្តរាយ និងកត្តាពាក់ព័ន្ធក្នុងតំបន់ផ្សេងទៀត ដូចជាលក្ខខណ្ឌអេកូឡូស៊ី។ ដូចជាយេនឌ័រដែរ តួនាទីយេនឌ័រអាចវិវឌ្ឍទៅតាមពេលវេលា ជាពិសេសតាមរយៈការផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងការផ្លាស់ប្តូរនៃភាពជាបុរស និងការបំបែករបាំងយេនឌ័រ។

**ការពង្រឹងសិទ្ធិអំណាច៖** ស្ត្រី និងក្មេងស្រីតែងមានការព្រួយបារម្ភពីការទទួលបានអំណាច និងការគ្រប់គ្រងលើជីវិតផ្ទាល់ខ្លួនរបស់ពួកគេ។ វាពាក់ព័ន្ធនឹងការលើកកម្ពស់ការយល់ដឹង ការកសាងទំនុកចិត្តលើខ្លួនឯង ការពង្រីកជម្រើសក្នុងជីវិត ការបង្កើនលទ្ធភាពទទួលបាននិងការគ្រប់គ្រងលើធនធាន និងសកម្មភាពនានា ដែលធ្វើឡើងដើម្បីផ្លាស់ប្តូររចនាសម្ព័ន្ធ និងស្ថាប័នដែលបង្កើត និងបន្តឱ្យមានការរើសអើងយេនឌ័រ និងវិសមភាព។ នេះបញ្ជាក់ថា ដើម្បីទទួលបានសិទ្ធិអំណាច ពួកគេមិនត្រឹមតែត្រូវមានសមត្ថភាពស្មើគ្នា (ដូចជាការអប់រំ និងសុខភាព) និងការទទួលបានធនធាន និងឱកាសស្មើៗគ្នា (ដូចជាដីធ្លី និងការងារ)ប៉ុណ្ណោះទេ ក៏ប៉ុន្តែពួកគេក៏ត្រូវតែមានភ្នាក់ងារដើម្បីប្រើប្រាស់សិទ្ធិ សមត្ថភាព ធនធាន និងឱកាសទាំងនេះដើម្បីធ្វើការជ្រើសរើស និងការសម្រេចចិត្តជាយុទ្ធសាស្ត្រ (ដូចជាការផ្តល់ឱ្យតាមរយៈឱកាសភាពជាអ្នកដឹកនាំ និងការចូលរួមក្នុងស្ថាប័ននយោបាយ ឬក្រុមការងារក្នុងតំបន់)។

[14]Taken from Gender Lens in Social & Behavior Change Guideline, UNICEF Ethiopia, 2022




# ផ្នែកទី ៣៖

# ឧបករណ៍សម្រាប់អនុវត្តន៍

## ការទទួលបានសិទ្ធិរបស់ស្ត្រី
## ការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី
## អំពើហិង្សាទាក់ទងនឹងយេនឌ័រ

# ម៉ូឌុល ក៖
# ការទទួលបានសិទ្ធិរបស់ស្ត្រី



**ថេរវេលា៖ ៣ម៉ោង**
**វត្ថុបំណង៖** បង្កើនចំណេះដឹង ស្ដីពីសិទ្ធិក្នុងការទទួលបានសិទ្ធិរបស់ស្ត្រី រាប់បញ្ចូលទាំងសិទ្ធិជនមានពិការភាព ជនជាតិដើមភាគតិច និងភាពចំរុះយេនឌ័ររវាងស្ត្រី បុរស និងអ្នកស្រឡាញ់ភេទដូចគ្នា ក្នុងសហគមន៍ ទីប្រជុំជន និងទីជនបទ។

## សេចក្ដីផ្ដើម

**ថេរវេលា៖ ១០នាទី**
វត្ថុបំណង៖ ស្វាគមន៍អ្នកចូលរួម ឬសមាជិកសហគមន៍មកកាន់វគ្គបណ្ដុះបណ្ដាល។ បង្ហាញពីដំណើរការ ប្រាប់ និងបង្កើតបរិយាកាសការងារវិជ្ជមានមុននឹងចាប់ផ្ដើមធ្វើសកម្មភាព។

## ការណែនាំសម្រាប់អ្នកសម្របសម្រួល៖

**ជំហានទី១៖** ស្វាគមន៍អ្នកចូលរួម ឬសមាជិកសហគមន៍។ ណែនាំអំពីក្រុមអ្នកសម្របសម្រួល ស្ថាប័នដៃគូក្នុងតំបន់ អាជ្ញាធរភូមិ និងអ្នកផ្សេងទៀតដែលមានវត្តមាននៅក្នុងវគ្គបណ្ដុះបណ្ដាល។
**ជំហានទី២៖** បង្ហាញពីគោលបំណងនៃវគ្គ ប្រាប់អ្នកចូលរួមអំពីថេរវេលាដែលត្រូវការសម្រាប់វគ្គ ពន្យល់ពីដំណើរការ និងសុំអនុញ្ញាតអ្នកចូលរួមក្នុងការថតរូប និងប្រើប្រាស់រូបថត (ប្រើប្រាស់ទម្រង់នៃគោលការណ៍ណែនាំរបស់ស្ថាប័ន និងទម្រង់នៃគោលការណ៍កិច្ចព្រមព្រៀង)។
**ជំហានទី៣៖** បង្កើតបរិយាកាសវិជ្ជមានជាមួយអ្នកចូលរួមដោយដាក់ចេញនូវផ្នត់គំនិតសង្គមដែលសាមញ្ញៗ។ ប្រើប្រាស់សំណួរខាងក្រោមដើម្បីពិភាក្សា៖

- តើយើងគួរធ្វើដូចម្ដេច ដើម្បីធានាថាអ្នកគ្រប់គ្នាមានឱកាសបង្ហាញពីគំនិតរបស់ពួកគេ និងមានអារម្មណ៍ល្អ និងសុវត្ថិភាព ក្នុងការចូលរួមក្នុងកិច្ចពិភាក្សា?
- តើយើងគួរធ្វើដូចម្ដេច នៅពេលអ្នកដទៃទៀត បញ្ចេញយោបល់របស់គេ?
- តើយើងគួរធ្វើដូចម្ដេច ក្នុងការបង្ហាញពីការគោរពទៅកាន់អ្នកដទៃ ដើម្បីទទួលបានភាពសុខដុម និងសាមគ្គីភាព?
- តើយើងគួរធ្វើដូចម្ដេចទៀត ដើម្បីធានាថាការពិភាក្សារបស់យើងនឹងបញ្ចប់ទៅតាមពេលកំណត់ និងមានអត្ថន័យ?

កំឡុងពេល ការពិភាក្សាលើសំណួរខាងលើ អ្នកសហការសម្របសម្រួល កត់ត្រាចម្លើយរបស់អ្នកចូលរួមនៅលើក្រដាសផ្ទាំងធំ និងសង្ខេបសារគន្លឹះទៅអ្នកចូលរួម និងរំលឹកឡើងវិញអំពីអ្វី ដែលសមាជិកនឹងធ្វើតាម។ សួរអ្នកចូលរួម ថាតើពួកគេមានសំណួរដែរឬទេ ប្រសិនបើមាន សូមចំណាយពេល ២ ទៅ ៣នាទី ឆ្លើយសំណួរដោយភ្ជាប់ជាមួយសកម្មភាពបន្ទាប់ និងធ្វើសកម្មភាពបន្ត។

## វគ្គទី១៖ យល់ដឹងអំពីសិទ្ធិរបស់អ្នក

### សកម្មភាព ១ក៖ សិទ្ធិមនុស្ស និងតថភាពជាក់ស្ដែង

**វត្ថុបំណង៖** បង្កើតការយល់ដឹងស៊ីជម្រៅ និងការវិភាគអំពីសិទ្ធិដែលស្ត្រីទទួលបាន
**ថេរវេលា៖** ៤០នាទី

**វិធីសាស្ត្រ៖** ចែករំលែកលក្ខណៈបុគ្គល និងជាក្រុម
**សម្ភារៈ និងការរៀបចំ៖** ព្រីនក្រដាសកិច្ចការស្តីពីសិទ្ធិមនុស្ស និងក្រដាសកិច្ចការអំពីតថភាពជាក់ស្តែង ដែលនឹងត្រូវផ្តល់ជូន នៅចុងបញ្ចប់នៃការណែនាំនេះ (១សន្លឹកសម្រាប់អ្នកចូលរួមម្នាក់)

- បង្កើតជាទម្រង់ក្រដាសកិច្ចការស្តីពីសិទ្ធិមនុស្ស និងក្រដាសកិច្ចការអំពីតថភាពជាក់ស្តែង នៅលើក្រដាសផ្ទាំងធំ។ អ្នកមិនចាំបាច់សរសេរគ្រប់ប្រយោគទាំងអស់ទេ ប៉ុន្តែសរសេរប្រធានបទសំខាន់ៗ ដូច្នេះអ្នកអាចបង្ហាញទៅកាន់អ្នកចូលរួម។
- រៀបចំក្រដាសផ្ទាំងធំដែលមានគូរប្រអប់៖ ប្រធានបទមួយអំពី **«បុរស»** ហើយប្រធានបទមួយទៀតអំពី **«ស្ត្រី»** ហើយបិតនៅលើជញ្ជាំង ហើយផ្ដាប់វាសិនដើម្បីកុំឱ្យអ្នកចូលរួមឃើញប្រធានបទ។

**អ្វីគួរធ្វើ និងអ្វីមិនគួរធ្វើ៖** អ្នកសម្របសម្រួលគួរតែលើកទឹកចិត្តឱ្យមានធាតុចូលពីអ្នកចូលរួមក្នុងការចែករំលែកទស្សនៈ និងបទពិសោធន៍របស់ពួកគេអំពីសិទ្ធិ។ អ្នកសម្របសម្រួលគួរតែចៀសវាងការនិយាយតែម្នាក់ឯង ឬផ្តល់ធាតុចូលទៅលើអ្វីដែលគេគិតថាត្រឹមត្រូវ។

## ការណែនាំសម្រាប់អ្នកសម្របសម្រួល៖

**ជំហានទី១៖** បង្កើតការពិភាក្សាជាមួយអ្នកចូលរួម អំពីអ្វីដែលពួកគេយល់ដឹងអំពីពាក្យ «សិទ្ធិ» ឬអ្វីដែលពួកគេគិតដល់នៅពេលដែលពួកគេឮ ពាក្យ «សិទ្ធិ»?

**ជំហានទី២៖** បន្ទាប់ពីអ្នកចូលរួមចែករំលែកយោបល់ ឬពាក្យពេចន៍របស់ពួកគេ ធ្វើការកត់ត្រាពាក្យពេចន៍ ឬគំនិតទាំងនោះ។ លើកសរសើរពីការចែករំលែករបស់អ្នកចូលរួម ដោយអានយោបល់ទាំងនោះឱ្យបានឮទាំងអស់គ្នា។

**ជំហានទី៣៖** បង្ហាញពីនិយមន័យនៃពាក្យ «សិទ្ធិ» នៅក្នុងស្លាយបទបង្ហាញ អង្គការសហប្រជាជាតិ បានឱ្យនិយមន័យ «សិទ្ធិ» ថា "សិទ្ធិមនុស្សគឺជាសិទ្ធិដែលមានជាប់មកជាមួយមនុស្សទាំងអស់ ដោយមិនគិតពីពូជសាសន៍ ភេទ សញ្ជាតិ ជាតិសាសន៍ ភាសា តំបន់ ឬឋានៈតួនាទីផ្សេងទៀតឡើយ។ សិទ្ធិមនុស្ស រាប់បញ្ចូលទាំងសិទ្ធិរស់រានមានជីវិត និងសេរីភាព សិទ្ធិរួចផុតពីទាសភាព និងទារុណកម្ម សិទ្ធិក្នុងការបញ្ចេញមតិយោបល់ សិទ្ធិប្រកបការងារ និងទទួលបានការអប់រំ និងជាសិទ្ធិជាច្រើនទៀត"។

**ជំហានទី៤៖** បន្តធ្វើការពិភាក្សា ដោយសួរសំណួរនៅលើក្រដាសផ្ទាំងធំ ដោយគូរប្រអប់ចំនួន២។ សរសេរពាក្យ «សិទ្ធិបុរស» នៅក្នុងប្រអប់ខាងឆ្វេងដៃ ហើយសរសេរពាក្យ «សិទ្ធិស្ត្រី» នៅចំកណ្ដាល និងសរសេរពាក្យ «សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា» នៅក្នុងប្រអប់ខាងស្តាំដៃ។ ចែកក្រដាសកិច្ចការ អំពីសិទ្ធិមនុស្សទៅឱ្យអ្នកចូលរួម។ (ឧបសម្ព័ន្ធទី ១ក-១) ព្យួរតារាងដែលបានគូរលើក្រដាសផ្ទាំងធំរួចនៅលើជញ្ជាំង។

**ជំហានទី៥៖** ពន្យល់អ្នកចូលរួមថា ក្រដាសកិច្ចការ ចាប់ផ្តើមដោយប្រយោគ "ខ្ញុំជឿថាអ្នកគ្រប់គ្នាមានសិទ្ធិ..." (បង្ហាញថាឃ្លានេះនៅលើក្រដាសផ្ទាំងធំ)។ នៅក្នុងប្រអប់ខាងក្រោម សរសេរពីគំនិតខុសគ្នាសម្រាប់អ្នកចូលរួមបំពេញបន្ថែមឱ្យបានជាប្រយោគ។ ឧទាហរណ៍៖ "ធ្វើការសម្រេចចិត្ត" ឬ "និយាយពីអារម្មណ៍របស់ពួកគេ" (ដូច្នេះប្រយោគពេញគឺ "ខ្ញុំជឿថាអ្នកគ្រប់គ្នាមានសិទ្ធិធ្វើការសម្រេចចិត្ត" និង "ខ្ញុំជឿថាអ្នកគ្រប់គ្នាមានសិទ្ធិនិយាយពីអារម្មណ៍របស់ពួកគេ")។ ចង្អុលបង្ហាញពីលេខរៀង និងប្រយោគដែលបានសរសេរនៅលើក្រដាសផ្ទាំងធំ។

**ជំហានទី៦៖** បន្តពន្យល់ថាអ្នកនឹងអានឮៗនូវគំនិតនីមួយៗ ដើម្បីបំពេញប្រយោគ «ខ្ញុំជឿថាអ្នកទាំងអស់គ្នាមានសិទ្ធិ...»។ ប្រាប់អ្នកចូលរួមឱ្យគិតថា តើពួកគេជ្រើសរើស យល់ស្រប មិនយល់ស្រប ឬមិនច្បាស់អំពីប្រយោគដែលអ្នកបានអាន។ ហើយប្រាប់ពួកគេឱ្យគូសសញ្ញា √ ក្នុងប្រអប់ដែលមាននៅក្នុងក្រដាសកិច្ចការរបស់ពួកគេសម្រាប់ជម្រើស «យល់ស្រប» «មិនយល់ស្រប» ឬ «មិនច្បាស់» ដោយផ្អែកលើអ្វីដែលពួកគេយល់ឃើញ។

ឧទាហរណ៍៖ ប្រសិនពួកគេជឿថាអ្នកគ្រប់គ្នាមិនមានសិទ្ធិធ្វើការសម្រេចចិត្ត បន្ទាប់មកពួកគេអាចគូរយកប្រអប់ «មិនយល់ស្រប»។ ប្រសិនជាពួកគេមិនច្បាស់ថាតើអ្នកគ្រប់គ្នាមានសិទ្ធិធ្វើការសម្រេចចិត្ត ឬអត់ នោះពួកគេអាចគូសយកចម្លើយ «មិនច្បាស់»។

**ជំហានទី៧៖** អ្នកសម្របសម្រួលសួរថាតើមានសំណួរ និងចម្លើយ ឬអ្វីផ្សេងទៀតដែលអ្នកចូលរួមត្រូវការបញ្ជាក់ឬទេ។

**ជំហានទី៨៖** ចាប់ផ្តើមអានប្រយោគទី១។ អានប្រយោគឡើងវិញ និងផ្អាកសិនមុននឹងបន្តទៅទៀត។ បន្តធ្វើបែបនេះរហូតអ្នកបានបញ្ចប់ក្រដាសកិច្ចការទី១។ ពន្យល់បន្ថែមថានេះជាលំហាត់ផ្ទាល់ខ្លួន ហើយអ្នកចូលរួមមិនចាំបាច់ពិភាក្សាជាមួយអ្នកចូលរួមផ្សេងទេ។

**ជំហានទី៩៖** បន្ទាប់ពីបានបំពេញក្រដាសកិច្ចការរួចរាល់ហើយ អ្នកសម្របសម្រួលសួរថា៖ តើមានសិទ្ធិមនុស្សណាទៀតដែលអ្នកមិនយល់ស្របជាមួយ ឬមិនច្បាស់? ពិភាក្សា (៥នាទី)។ ក្រដាសកិច្ចការទី២ នឹងឱ្យអ្នកស្វែងយល់ស៊ីជម្រៅជាងនេះ ពីតថភាពពិតនៃសិទ្ធិ។

**ជំហានទី១០៖** ពន្យល់ថា ពួកយើងនឹងមើលទៅលើក្រដាសកិច្ចការមួយទៀត (ឧបសម្ព័ន្ធ ១ក-២)។ ក្រដាសកិច្ចការបន្ទាប់នឹងតម្រូវឱ្យបំពេញតាមក្រុមតូច។ សូមមើលលើក្រដាសកិច្ចការនេះទាំងអស់គ្នា។

**ជំហានទី១១៖** ប្រគល់ក្រដាសកិច្ចការអំពីតថភាពពិត ទៅឱ្យអ្នកចូលរួម។ ព្យួរក្រដាសផ្ទាំងធំដែលបានគូររួចទៅលើជញ្ជាំង។

**ជំហានទី១២៖** ពន្យល់ថា ក្រដាសនេះចាប់ផ្តើមជាមួយនឹងសំណួរ "តើភាគច្រើននៃ...(ចន្លោះ)...មានអំណាចក្នុងការ..." ជាមួយនឹងស្ថានភាពដែលមានរៀបរាប់ដូចខាងក្រោម។ នៅជិតសំណួរ មានប្រអប់ចំនួន២សម្រាប់បំពេញក្នុងចន្លោះ៖ "បុរសក្នុងសហគមន៍របស់អ្នក" "នារីក្នុងសហគមន៍របស់អ្នក" និង "ក្រុមអ្នកស្រឡាញ់ភេទដូចគ្នាក្នុងសហគមន៍របស់អ្នក" (ដូច្នេះសំណួរនឹងទៅជា "តើបុរសនៅក្នុងសហគមន៍របស់អ្នកមានអំណាចក្នុងការ..." ហើយ "តើស្ត្រីភាគច្រើនក្នុងសហគមន៍របស់អ្នកមានអំណាចក្នុងការ..." "តើភាគច្រើននៃអ្នកស្រឡាញ់ភេទដូចគ្នាក្នុងសហគមន៍របស់អ្នកមានអំណាចក្នុងការ...") ហើយក្រុមនីមួយៗគួរគិតអំពីតថភាពពិត ថាតើបុរសភាគច្រើននៅក្នុងសហគមន៍របស់អ្នក និងស្ត្រីភាគច្រើននៅក្នុងសហគមន៍របស់អ្នកមានអំណាចធ្វើសកម្មភាពដែលបានសរសេរក្នុងបញ្ជីឬទេ។

ចម្លើយរបស់អ្នកគួរតែឆ្លុះបញ្ចាំងពីអ្វីដែលកើតឡើងពិតប្រាកដ មិនមែនអ្វីដែលអ្នកចង់ឱ្យកើតឡើងនោះទេ។ អ្នកនឹងកត់ចំណាំចម្លើយរបស់អ្នកដោយគូសសញ្ញា √ យក "ពិតមែន" "ទេ" ឬក៏ "មិនច្បាស់" នៅក្នុងប្រអប់សម្រាប់បុរស ស្ត្រី និងក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ដោយស្របតាមការជឿរបស់អ្នក។ ចងចាំថាអ្នកកំពុងឆ្លើយសំណួរថាតើបុរសភាគច្រើន ស្ត្រីភាគច្រើន និងក្រុមអ្នកស្រឡាញ់ភេទដូចគ្នាភាគច្រើន នៅក្នុងសហគមន៍របស់អ្នកមានអំណាចអាចធ្វើសកម្មភាពនេះបាន មិនមែនគ្រប់បុរស ឬគ្រប់ស្ត្រីទាំងអស់ទេ។ តែងតែមានករណីលើកលែង ប៉ុន្តែយើងក៏ចង់ដឹង ថាតើអ្វីដែលភាគច្រើនមានដូចគ្នា។

**ជំហានទី១៣៖** អ្នកសម្របសម្រួលត្រូវប្រាកដថា មិនមានសំណួរពីអ្នកចូលរួមទៀតទេ។ ឱ្យអ្នកចូលរួមបង្កើតជាក្រុមតូចៗ ដោយរាប់លេខលឺៗ ហើយចែកជាក្រុមទៅតាមលេខ។ ក្រុមពិភាក្សាមានពេល៥នាទី ដើម្បីធ្វើសកម្មភាពនេះ។

**ជំហានទី១៤៖** ឱ្យក្រុមរាប់ចំនួនសរុបដែលបានគូសសម្រាប់ចម្លើយ «ពិតមែន» នៅក្នុងប្រអប់របស់បុរស, ឱ្យក្រុមរាប់ចំនួនសរុបដែលបានគូសសម្រាប់ចម្លើយ «ពិតមែន» នៅក្នុងប្រអប់របស់ស្ត្រី, ឱ្យក្រុមរាប់ចំនួនសរុបដែលបានគូសសម្រាប់ចម្លើយ «ពិតមែន» នៅក្នុងប្រអប់របស់ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា។ ឱ្យក្រុមនីមួយៗចែករំលែកចំនួនដែលបូកសរុបរួច ជាមួយអ្នកចូលរួមទាំងអស់។ បើកក្រដាសផ្ទាំងធំដែលមានគូសប្រអប់ «បុរស» «ស្ត្រី» និង «ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា» រួចសរសេរលេខនៅលើក្រដាសផ្ទាំងធំឱ្យត្រូវទៅតាមប្រអប់។

**ជំហានទី១៥៖** សួរសំណួរ៖

ក. តើស្ត្រីទទួលបានគំនូសសម្រាប់ចម្លើយ «ពិតមែន» ច្រើនជាងបុរសដែរឬទេ? ហេតុអ្វី?

ខ. តើអ្នកគិតថាវាត្រឹមត្រូវ ឬស្មើភាពឬទេ? ហេតុអ្វី?

**ជំហានទី១៦៖** អ្នកសម្របសម្រួលសង្ខេបខ្លឹមសារពីការពិភាក្សាថា ប្រសិនបើយើងគិតថាអ្នកគ្រប់គ្នាអាចទទួលបានសិទ្ធិមនុស្សដូចៗគ្នា ប៉ុន្តែពាក់កណ្តាលនៃប្រជាជន មិនអាចប្រើប្រាស់សិទ្ធិទាំងនេះដោយភាពរីករាយបាន ដូច្នេះវាគឺជាភាពអយុត្តិធម៌។ ភាពអយុត្តិធម៌នេះកើតមានឡើងដោយសារបុរសត្រូវបានសង្គមផ្តល់អំណាចឱ្យច្រើនជាងស្ត្រី។ ជនមានពិការភាព ក្រុមជនជាតិដើម ឬជនជាតិភាគតិច និងក្រុមអ្នកស្រឡាញ់ភេទដូចគ្នា គឺជាអ្នកងាយរងគ្រោះជាងគេ និងត្រូវបានគេជាត់ចោលនៅក្នុងសង្គម។ ក្រុមទាំងនេះត្រូវបានសង្គមរើសអើង និងមិនឱ្យតម្លៃ។ ពួកគេគឺជាមនុស្ស និងមានសិទ្ធិដូចគ្នានឹងមនុស្សទាំងអស់គ្នាដែរ។

**ជំហានទី១៧៖** អ្នកសម្របសម្រួលសួរអ្នកចូលរួមថា តើមានអ្វីកើតឡើងប្រសិនបើមានភាពអយុត្តិធម៌ដូចនេះនៅក្នុងជីវិត និងសហគមន៍របស់យើង? តើវាមានន័យដូចម្តេចសម្រាប់ស្ត្រី និងបុរស កូនៗ និងគ្រួសារ សហគមន៍ និងសង្គម? (ចម្លើយអាចជា៖ ស្ត្រីមិនអាចបញ្ចេញនូវសក្តានុពលរបស់ពួកគេបានទេ សហគមន៍មិនអាចអភិវឌ្ឍន៍ឱ្យខ្លាំងក្លាបានទេ ទំនាក់ទំនងមិនមានភាពរឹងមាំបាននោះទេ បុរសក៏មិនអាចបញ្ចេញនូវសក្តានុពលរបស់ខ្លួនបានពេញលេញដែរ)។

**ជំហានទី១៨៖** សង្ខេបថា ការមិនអើពើអំពីសិទ្ធិ គឺជាភាពអយុត្តិធម៌។ ភាពអយុត្តិធម៌កើតមានឡើងនៅពេលក្រុមមនុស្សមួយចំនួនមានអំណាចជាង ក្រុមដទៃទៀត។ ភាពអយុត្តិធម៌ជះឥទ្ធិពលទៅលើសមាជិកសហគមន៍ទាំងអស់។ ភាពអយុត្តិធម៌នេះ ភាពលំអៀងនៃអំណាចនេះ គឺជាឫសគល់នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការរើសអើង។

**កំណត់ចំណាំ សម្រាប់អ្នកសម្របសម្រួល៖** គួរតែបន្ថែមសញ្ញាសម្គាល់ទៅក្នុងប្រអប់នីមួយៗ ដើម្បីជួយអ្នកដែលមិនអាចអានបាន ឱ្យចងចាំពីប្រអប់ដែលបង្ហាញចម្លើយ «យល់ព្រម» «មិនយល់ព្រម» និង «មិនច្បាស់»។ ត្រូវប្រាកដថាបានចង្អុលបង្ហាញសញ្ញាសម្គាល់ និងពន្យល់ថាណាមួយត្រូវនឹងចម្លើយណាមួយ។ ត្រូវប្រាកដថាបានប្រើប្រាស់ និងចង្អុលបង្ហាញសញ្ញាសម្គាល់ និងពន្យល់ថាមួយណាត្រូវនឹងចម្លើយមួយណា ដើម្បីឱ្យអ្នកចូលរួមដែលមិនអាចអានបាន អាចតាមទាន់ជំហាននៃលំហាត់។

## សកម្មភាព ២ក៖ ទស្សនៈ និងប្រវត្តិរបស់សិទ្ធិស្ត្រី (បន្ទាត់ពេលវេលាប្រវត្តិសាស្ត្រ)

**វត្ថុបំណង៖** ស្វែងយល់អំពី ថាតើសិទ្ធិស្ត្រី មានការវិវត្តក្នុងប្រទេសកម្ពុជាដោយរបៀបណា និងនៅពេលណា
**ថេរវេលា** ៖ ២០នាទី
**វិធីសាស្ត្រ៖** ការពិភាក្សាដែលមានទំនាក់ទំនងគ្នា និងការឆ្លុះបញ្ចាំងទៅលើការយល់ឃើញក្នុងប្រវត្តិសាស្ត្រ
**សម្ភារៈ និងការរៀបចំ៖** ក្រដាសផ្ទាំងធំ និងហ្វឺត
**អ្វីគួរធ្វើ និងអ្វីមិនគួរធ្វើ៖** ការទទួលបានព័ត៌មានជាក់លាក់ មានសារសំខាន់ណាស់ ដើម្បីស្វែងយល់ពីបន្ទាត់ពេលវេលាប្រវត្តិសាស្ត្រ។ អ្នកសម្របសម្រួលត្រូវតែរៀបចំឱ្យបានល្អ និងមានព័ត៌មានពាក់ព័ន្ធនឹងឆ្នាំនៃព្រឹត្តការណ៍បន្ថែមពីលើការលើកទឹកចិត្តឱ្យមានការចូលរួមពីអ្នកចូលរួម។

## ការណែនាំសម្រាប់អ្នកសម្របសម្រួល៖

**ជំហានទី១៖** យកក្រដាសផ្ទាំងធំ ឬប្រសិនបើមានក្តារខៀន គូរប្រអប់ចំនួន ៥ ទៅ ៦ ដើម្បីដាក់ពេលរយៈពេល៥ឆ្នាំនៅក្នុងប្រអប់នីមួយៗ ចាប់ផ្តើមពី ១៩XX រហូតដល់បច្ចុប្បន្ន ដើម្បីគូសវាសអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដែលទាក់ទងនឹងសមភាពយេនឌ័រ ឬសិទ្ធិស្ត្រីនៅក្នុងប្រទេសកម្ពុជា។ ព្រឹត្តការណ៍ប្រវត្តិសាស្ត្រអាចយកចេញពីលទ្ធផលនៃចលនាសកលលោក ច្បាប់ និងគោលនយោបាយជាតិ។ ឧទាហរណ៍៖ តើនៅឆ្នាំណាខ្លះ ដែលប្រទេសកម្ពុជាបានប្រារព្ធទិវាអន្តរជាតិនារី លើកតំបូងគេបង្អស់ ហើយតើអ្វីជាដើមហេតុក្នុងការផ្តើមឱ្យមានការប្រារព្ធទិវានេះ។

**ជំហានទី២៖** នាំអ្នកចូលរួមឱ្យជជែកពីបន្ទាត់ពេលវេលាប្រវត្តិសាស្ត្រ និងបំពេញទាំងអស់គ្នា។ ផ្តួចផ្តើមឱ្យមានការជជែកពីសារសំខាន់នៃព្រឹត្តការណ៍ប្រវត្តិសាស្ត្រ និងផលជះ។ ដើម្បីឱ្យមានការវិភាគស៊ីជម្រៅ ការពិភាក្សាអាចផ្តោតទៅលើអ្វីដែលជាលទ្ធផល និងព្រឹត្តិការណ៍សំខាន់ៗដែលជាលទ្ធផលនៃព្រឹត្តិការណ៍ទាំងនេះ។

**ជំហានទី៣៖** សួរអ្នកចូលរួមតើពួកគេយល់យ៉ាងណាចំពោះសកម្មភាពនេះ តើគាត់បានរៀនអ្វីខ្លះ និងរកឃើញអ្វីខ្លះដែលគួរឱ្យចាប់អារម្មណ៍។

**ជំហានទី៤៖** សន្និដ្ឋានដោយពន្យល់ថា ការយល់ដឹង និងចំណេះដឹងអំពីព្រឹត្តិការណ៍សំខាន់ៗដែលកើតចេញពីតម្រូវការការកៀរគរកមតិគាំទ្រសម្រាប់សិទ្ធិស្ត្រី និងសមភាពយេនឌ័រ ពិតជាមានសារៈសំខាន់ណាស់ ដែលវាអាចជួយជាមូលដ្ឋានគ្រឹះដើម្បីកំណត់បញ្ហាថ្មីៗ ឬបញ្ហាដែលកើតឡើងទាក់ទងនឹងសិទ្ធិស្ត្រី។

## ខណ្ឌទី ២៖ ក្របខ័ណ្ឌច្បាប់ជាតិ និង អន្តរជាតិទាក់ទងនឹងសិទ្ធិ

ផ្នែកនេះ នាំអ្នកចូលរួមឱ្យស្វែងរកចំណេះដឹងអំពីយន្តការគាំទ្រថ្នាក់ជាតិ និងអន្តរជាតិទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងឆ្លុះបញ្ចាំងពីតថភាពពិតនៃសិទ្ធិ។

## សកម្មភាព ៣ក៖ យន្តការគាំទ្រថ្នាក់ជាតិ និងអន្តរជាតិទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី

**វត្ថុបំណង៖** រំលេចនូវយន្តការគាំទ្រថ្នាក់អន្តរជាតិ ក្នុងការគាំទ្រស្ត្រីឱ្យទទួលបានសិទ្ធិ។
**ថេរវេលា៖** ១០នាទី
**វិធីសាស្ត្រ៖** សង្ខេប ពិភាក្សា និង ធ្វើបទបង្ហាញ
សម្ភារៈ និងការរៀបចំ៖ កាតពណ៌១ប្រអប់ ឬក្រដាសបិទតូចៗ ហ្វឺតពណ៌ចំនួន៣ ស្កុតក្រដាសចំនួន១ដុំ រៀបចំសំណួរណែនាំសម្រាប់ការពិភាក្សា និងធ្វើស្លាយបទបង្ហាញ PowerPoint ។

**អ្វីគួរធ្វើ ឬអ្វីមិនគួរធ្វើ៖** លើកទឹកចិត្តឱ្យអ្នកចូលរួមចែករំលែកគំនិតរបស់ពួកគេ ប៉ុន្តែមិនបង្ខិតបង្ខំ មិនវិនិច្ឆ័យ ដោយការឱ្យតម្លៃចំពោះគ្រប់គ្នា។ ប្រើប្រាស់សំឡេង និងការលើកដាក់សំឡេងឱ្យបានត្រឹមត្រូវ។ ធានាថាគ្រប់គ្នាមានភាពងាយស្រួល និងរួចរាល់ក្នុងការចូលរួមក្នុងការពិភាក្សា។ អ្នកសម្របសម្រួលជានិច្ចកាលគួរប្រើប្រាស់ការទំនាក់ទំនងទៅវិញទៅមក និងលើកកម្ពស់ឱ្យមានការពិភាក្សាតាមរយៈវិធីសាស្ត្ររៀនសូត្របែបមនុស្សពេញវ័យ។ មិនត្រូវប្រើប្រាស់ «កំប្លែងបែបអាសអាភាស» ឬ «រឿងអស់សំណើច» ដែលទាក់ទងនឹង ជាតិសាសន៍ អំបូរ យេនឌ័រ នៅក្នុងសកម្មភាពល្បែងថាមពលទេ។ ការណែនាំសម្រាប់អ្នកសម្របសម្រួល៖

**ជំហានទី១៖** ឱ្យអ្នកចូលរួមគិតពីអនុសញ្ញាអន្តរជាតិ និងសេចក្តីថ្លែងការទាក់ទងនឹងសិទ្ធិដែលពួកគេដឹង ឬបានឮ។ ប្រើប្រាស់សំណួរណែនាំខាងក្រោម ដើម្បីនាំឱ្យមានការពិភាក្សា៖

- តើមានច្បាប់អន្តរជាតិ ឬអនុសញ្ញាអន្តរជាតិអ្វីខ្លះដែលនិយាយពីសិទ្ធិស្ត្រី? សិទ្ធិបុរស? និងសិទ្ធិរបស់អ្នកដែលមានយេនឌ័រចម្រុះ?

កំឡុងពេលពិភាក្សា អ្នកសម្របសម្រួលកត់ត្រាព័ត៌មានដែលចែករំលែកដោយអ្នកចូលរួម នៅលើនៅកាតពណ៌ ឬក្រដាសបិតតូចៗ (ប្រើប្រាស់ឧបករណ៍ Pile Sorting)។

**ជំហានទី២៖** សង្ខេបខ្លី ឬនិយាយឡើងវិញនូវព័ត៌មានដែលបានចែករំលែក និងកត់ត្រាលើកាត។ បន្ទាប់មកបង្ហាញពីអនុសញ្ញាអន្តរជាតិ និងប្រាប់អ្នកចូលរួមថាទាំងនេះជាក្របខ័ណ្ឌអន្តរជាតិ ដើម្បីនាំផ្លូវពួកយើង ឬប្រទេសរបស់ពួកយើង ដើម្បីលើកកម្ពស់សមភាពយេនឌ័រ សិទ្ធិមនុស្ស និងសិទ្ធិស្ត្រី។ ប្រើប្រាស់អនុសញ្ញាគន្លឹះខាងក្រោម និងមើលទៅលើស្លាយបង្ហាញ PowerPoint សម្រាប់ព័ត៌មានបន្ថែម។

- ធម្មនុញ្ញអំពីសិទ្ធិមនុស្ស ទទួលស្គាល់សិទ្ធិប្រជាពលរដ្ឋទូទៅចំនួន៣០ចំណុច រាប់បញ្ចូលទាំងប្រជាជនកម្ពុជាផងដែរ។
- អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើង ប្រឆាំងនឹងស្ត្រី (CEDAW) (ប្រទេសកម្ពុជា បានផ្តល់សច្ចាប័ន នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២)។
- អនុសញ្ញាស្តីពីសិទ្ធិកុមារ (ប្រទេសកម្ពុជាផ្តល់សច្ចាប័ននៅខែឧសភា ឆ្នាំ១៩៩២)។
- អនុសញ្ញា របស់អង្គការពលកម្មអន្តរជាតិលេខ១៩០ (C190) ទៅលើសិទ្ធិកម្មករចំណាកស្រុក, ការងារដែលមានតម្លៃ និងការទប់ស្កាត់ការបៀតបៀន នៅក្នុងពិភពការងារ (ប្រទេសកម្ពុជាមិនទាន់ផ្តល់សច្ចាប័ន ទៅលើអនុសញ្ញានេះនៅឡើយទេ, អង្គការយេរកម្ពុជា និងអង្គការសង្គមស៊ីវិលដទៃទៀត រាប់បញ្ចូល ទាំងសហជីពក្នុងប្រទេសកម្ពុជាបានសហការគ្នាក្នុងការកៀរគររកមតិគាំទ្រដើម្បីឱ្យមានការផ្តល់សច្ចាប័នលើ អនុសញ្ញានេះចាប់តាំងពីឆ្នាំ២០១៩រហូតដល់បច្ចុប្បន្ន)។

**ជំហានទី៣៖** សន្និដ្ឋាន និងសង្ខេបលទ្ធផលសំខាន់ៗបានមកពីការពិភាក្សា។ សួរអ្នកចូលរួមប្រសិនបើពួកគេមានសំណួរ។ ចំណាយពេលមួយនាទី ឆ្លើយតបប្រសិនបើមានសំណួរ បន្ទាប់មកបន្តទៅសកម្មភាពបន្ទាប់។

## សកម្មភាព ៤ក៖ តើច្បាប់ប្រទេសកម្ពុជាចែងយ៉ាងដូចម្តេចអំពីសិទ្ធិរបស់ប្រជាជនកម្ពុជា?

**វត្ថុបំណង៖**

- ចែករំលែកការយល់ដឹងនូវសិទ្ធិថ្នាក់ជាតិដែលមានស្រាប់ ដែលគាំទ្រការទទួលបានសិទ្ធិរបស់ស្ត្រី។
- ធ្វើការពិនិត្យមើលតថភាពជាក់ស្តែងអំពីសិទ្ធិដែលអាចមាន និងងាយស្រួលក្នុងការប្រើប្រាស់។

**ថេរវេលា ៖១០នាទី**

**វិធីសាស្ត្រ៖** សង្ខេប ពិភាក្សា និងធ្វើបទបង្ហាញ។

**សម្ភារៈ និងការរៀបចំ៖** កាតពណ៌១ប្រអប់ ឬក្រដាសបិទតូចៗ ហ្វឺតពណ៌ចំនួន៣ ស្កុតក្រដាសចំនួន១ដុំ រៀបចំបញ្ជីសំណួរណែនាំ សម្រាប់ពិភាក្សា និងស្លាយ បទបង្ហាញ PowerPoint ។

**អ្វីគួរធ្វើ និងអ្វីមិនគួរធ្វើ៖** លើកទឹកចិត្តឱ្យអ្នកចូលរួមចែករំលែកពីគំនិតរបស់ពួកគេ ប៉ុន្តែមិនបង្ខិតបង្ខំ មិនវិនិច្ឆ័យ និងឱ្យតម្លៃចំពោះគំនិតអ្នករាល់គ្នា។

## ការណែនាំសម្រាប់អ្នកសម្របសម្រួល៖

**ជំហានទី១៖** ពន្យល់ពីដំណើរការសកម្មភាព វត្ថុបំណង និងថេរវេលាដែលត្រូវការ។

**ជំហានទី២៖** ស្នើអ្នកចូលរួមគិតពីច្បាប់កម្ពុជា គោលនយោបាយ និងបទបញ្ញត្តិទាក់ទងនឹងសិទ្ធិដែលពួកគេដឹង ឬធ្លាប់ឮ។ ប្រើប្រាស់សំណួរណែនាំខាងក្រោមដើម្បីនាំឱ្យមានការពិភាក្សា៖

- តើមានច្បាប់ គោលនយោបាយ បទបញ្ញត្តិអ្វីខ្លះក្នុងប្រទេសកម្ពុជាដែលចែងអំពីសិទ្ធិមនុស្ស ដូចជាសិទ្ធិស្ត្រី? សិទ្ធិបុរស? និងសិទ្ធិអ្នកមានយេនឌ័រចម្រុះ?

កំឡុងពេលពិភាក្សា អ្នកសម្របសម្រួលត្រូវកត់ត្រាព័ត៌មានដែលចែករំលែកដោយអ្នកចូលរួម នៅលើកាតពណ៌ ឬក្រដាសបិតតូចៗ (ប្រើប្រាស់ឧបករណ៍ Pile Sorting)។

**ជំហានទី៣៖** សង្ខេបខ្លី ឬនិយាយឡើងវិញនូវព័ត៌មានដែលបានចែករំលែក និងកត់ត្រាលើកាត, បន្ទាប់មកបង្ហាញពីឯកសារគន្លឹះ ទាក់ទងនឹងសិទ្ធិអ្នកចូលរួម។ ប្រាប់អ្នកចូលរួមថា មានក្របខ័ណ្ឌជាតិ ដើម្បីនាំផ្លូវពួកយើង ឬអង្គការរបស់យើង ឬសមាជិកសហគមន៍របស់យើង ដើម្បីលើកកម្ពស់ សមភាពយេនឌ័រ សិទ្ធិមនុស្ស និងសិទ្ធិស្ត្រី។

ប្រើប្រាស់ឯកសារគន្លឹះខាងក្រោម និងមើលទៅលើស្លាយបង្ហាញ PowerPoint សម្រាប់ព័ត៌មានបន្ថែម។

- ជំពូកទី៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥
- ច្បាប់ស្តីពីការបង្ក្រាបអំពើ ជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨

**ជំហានទី៤៖** សង្ខេបលទ្ធផលសំខាន់ៗ ពីការពិភាក្សាក្នុងសកម្មភាពទី៣ និងទី៤។

**ជំហានទី៥៖** ស្នើអ្នកចូលរួម ឱ្យឆ្លុះបញ្ចាំងពីការរស់នៅប្រចាំថ្ងៃ។ យោងតាមសិទ្ធិមនុស្សដែលបានបញ្ជាក់ក្នុងក្របខណ្ឌអន្តរជាតិ និងជាតិ តើមួយណាដែលពួកគេអាចប្រើប្រាស់បានដោយងាយស្រួល ហើយមួយណាដែលពួកគេមានឧបសគ្គក្នុងការប្រើប្រាស់ មូលហេតុអ្វី? ប្រើពេល២ ទៅ៣នាទីក្នុងការពិភាក្សា។

**ជំហានទី៦៖** សន្និដ្ឋាន និង សង្ខេបលទ្ធផលសំខាន់ៗពីការពិភាក្សាឆ្លុះបញ្ចាំង អំពីសិទ្ធិក្នុងពេលបច្ចុប្បន្នរបស់អ្នកចូលរួម។ បន្ទាប់មកប្រាប់អ្នកចូលរួមថាសកម្មភាពបន្ទាប់ ពួកយើងនឹងរៀនសូត្រ និងពិភាក្សាអំពីសិទ្ធិរបស់អ្នកដទៃទៀតនៅក្នុងសង្គម ជាពិសេសសម្រាប់ក្រុមអ្នកយេនឌ័រចម្រុះ ជនមានពិការភាព និងជនជាតិដើម។ បន្តទៅសកម្មភាពបន្ទាប់ទៀត។

## ផ្នែកទី៣៖ យេនឌ័រ និងអន្តរប្រសព្វទាក់ទងនឹងការរើសអើង

ផ្នែកនេះមានគោលបំណងបង្កើនចំណេះដឹងស្តីអំពីផលប៉ះពាល់នៃការរើសអើង ចំពោះស្ត្រី ក្រុមចម្រុះយេនឌ័រ ជនមានពិការភាព និងជនជាតិដើមក្នុងការទទួលបានសិទ្ធិក្នុងសង្គមកម្ពុជា។

### សកម្មភាព ៥ក៖ ផលប៉ះពាល់នៃយេនឌ័រ និងអន្តរប្រសព្វទាក់ទងនឹងការរើសអើង

**វត្ថុបំណង៖** ដើម្បីស្វែងយល់ពីធាតុផ្សំនៃការរើសអើង ដែលរារាំងស្ត្រី (រាប់បញ្ចូលទាំងក្រុមចម្រុះយេនឌ័រ ស្ត្រីជនជាតិដើម និងស្ត្រីមានពិការភាព) ពីការទទួលបានសិទ្ធិ។
**ថេរវេលា ៖** ៤០នាទី
**វិធីសាស្ត្រ៖** ការអនុវត្តបង្ហាញ ដោយសម្តែងតួ ពិភាក្សា និងធ្វើបទបង្ហាញ។
**សម្ភារៈ និងការរៀបចំ៖** កាតពណ៌ ហ្វឺត តួអង្គ (សរសេរតួអង្គមួយនៅលើក្រដាសមួយសន្លឹក) និងប្រយោគ។
**អ្វីគួរធ្វើ និងអ្វីមិនគួរធ្វើ៖** ពន្យល់ឱ្យច្បាស់ពីដំណើរការលំហាត់ សម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយអ្នកចូលរួម ប៉ុន្តែមិនគួរផ្តល់យោបល់ថាគួរធ្វើអ្វីនោះទេ មិនធ្វើការវិនិច្ឆ័យ ហើយត្រូវប្រាកដថាមានការចូលរួមដោយភាពចម្រុះ។[15]

### ការណែនាំសម្រាប់អ្នកសម្របសម្រួល៖

លំហាត់អនុវត្ត “Life walk”[15]

**ជំហានទី១៖** ពន្យល់ពីដំណើរការសកម្មភាព វត្ថុបំណង និងថេរវេលាដែលត្រូវការ។

**ជំហានទី២៖** ស្វែងរកអ្នកស្ម័គ្រចិត្តចំនួន ៩នាក់ ចម្រុះទៅដោយស្ត្រី និងបុរស និងឱ្យពួកគេ ទៅកាន់កន្លែងដែលធំទូលាយ ដែលពួកគេអាចតម្រង់ជួរបាន។ ត្រូវប្រាកដថា មានទីធ្លាទូលាយអាចឈានជើងបានទៅដល់ចំនួន ១៤ជំហាន ទាំងទៅពីមុខ និងពីទៅក្រោយ។ ប្រាប់អ្នកស្ម័គ្រចិត្តទាំងអស់នោះឱ្យរក្សាការសម្ងាត់អំពីតួអង្គដែលពួកគេចាប់បាន។ រួចប្រាប់អ្នកចូលរួមថា ពួកគេនឹង ឮប្រយោគពីអ្នកសម្របសម្រួល។ ហើយរាល់ប្រយោគទាំងអស់ដែលទាក់ទងទៅកាន់តួអង្គរបស់ពួកគាត់ និងត្រូវឆ្លើយ «ពិតមែន» ឬត្រូវទៅនឹងបុគ្គលិកលក្ខណៈរបស់តួអង្គនីមួយៗ ឱ្យពួកគេឈានទៅមុខមួយជំហាន។

[15] Character roles could be decided based on context. Suggested characters for this package are: (1) a pregnant woman with disability, (2) a woman migrant worker and cannot speak Khmer language well, (3) an adolescent girl who faced GBV; (4) a man with disability and live alone, (5) a male provincial governor, (6) a male project manager, (7) a female director from CSO network, (8) a male police officer, (9) a sex worker.
[16] This activity has been adapted from CARE International “Preventing Sexual Exploitation and Abuse Staff Training Facilitator Guide”

ប្រសិនបើប្រយោគមិនត្រូវនឹងបុគ្គលិកលក្ខណៈរបស់តួអង្គនេះទេ ប្រាប់ពួកគេឱ្យឈានទៅក្រោយមួយជំហាន។ ប្រសិនពួកគេមិនច្បាស់ ពួកគេអាចទាយទៅតាមបរិបទជាក់ស្តែងនៃបុគ្គលិកលក្ខណៈតួអង្គនីមួយៗ។

**ជំហានទី៣៖** អានប្រយោគខាងក្រោមឮៗ ហើយត្រូវប្រាកដថាតួអង្គនីមួយៗ មានសកម្មភាព។

1. **ខ្ញុំអាចមានឥទ្ធិពលទៅលើការសម្រេចចិត្តនៅថ្នាក់សហគមន៍។**
2. **ខ្ញុំអាចទទួលបានព័ត៌មានទាក់ទងនឹងសុខភាព ការអប់រំ ការងារ មុខជំនួញ ជាដើម។**
3. **ខ្ញុំមានគណនីធនាគារផ្ទាល់ខ្លួន។**
4. **ខ្ញុំអាចនិយាយ និងធ្វើការសម្រេចចិត្តនៅក្នុងការប្រជុំភូមិរបស់ខ្ញុំបាន។**
5. **ខ្ញុំមានទំនុកចិត្ត និងអាចចរចារជាមួយអ្នកជំនួញបាន។**
6. **ខ្ញុំបានចូលរៀនថ្នាក់វិទ្យាល័យ និងសាកលវិទ្យាល័យ។**
7. **ខ្ញុំអាចបង់ថ្លៃព្យាបាលនៅមន្ទីរពេទ្យឯកជនថ្លៃៗបាន។**
8. **ខ្ញុំអាចទទួលបានសេវាកម្ម និងព័ត៌មានពេញលេញទាក់ទងនឹងអំពើហិង្សា។**
9. **ខ្ញុំមិនមានភាពភ័យខ្លាចទេ ពេលខ្ញុំដើរតែម្នាក់ឯងនៅពេលយប់។**
10. **ខ្ញុំមិនចាំបាច់តម្រង់ជួរ ដើម្បីយកទិដ្ឋាការសម្រាប់កម្មករចំណាកស្រុកទេ។**
11. **ខ្ញុំមានទំនុកចិត្ត ក្នុងការស្លៀកសំលៀកបំពាក់ដែលខ្ញុំចង់ស្លៀក ដោយមិនមានការព្រួយបារម្ភអំពីការរិះគន់របស់អ្នកដទៃ។**
12. **ខ្ញុំមានទំនុកចិត្ត ក្នុងការសម្រេចចិត្តដើម្បីប្រាប់គេថាខ្ញុំជានរណា (អត្តសញ្ញាណភេទ ឬទំនោរផ្លូវភេទ) នៅក្នុងគ្រួសាររបស់ខ្ញុំ និងសហគមន៍។**
13. **ខ្ញុំមិនមានភាពភ័យខ្លាច ក្នុងការនិយាយថាទេចំពោះការរួមភេទជាមួយដៃគូ ឬប្តី ឬប្រពន្ធរបស់ខ្ញុំ។**
14. **ខ្ញុំយល់ច្បាស់ថាខ្ញុំមានសិទ្ធិពេញលេញ ក្នុងការសម្រេចចិត្តយកកូន ឬមិនយកកូន ។**

**ជំហានទី៤៖** ស្នើអ្នកចូលរួមឱ្យឈរនៅទីតាំងដែលបានសំដែងជាតួអង្គរបស់គាត់ ហើយនាំឱ្យមានការពិភាក្សានូវអ្វីដែលកើតឡើងដោយប្រើប្រាស់សំណួរខាងក្រោម៖

- ចាប់ពីអ្នកដែលឈរនៅក្រោយគេ សួរអំពីតួអង្គរបស់គេ
- សួរអ្នកដែលឈរនៅក្រោយគេ ២ ទៅ៣នាក់ ហេតុអ្វីបានជាពួកគេនៅទីនោះ ហើយមានអារម្មណ៍ដូចម្តេចនៅពេលឈរក្រោយគេ?
- សួរអ្នកដែលឈរនៅកណ្តាល ២ទៅ៣នាក់ ហេតុអ្វីបានពួកគេនៅទីនោះ ហើយមានអារម្មណ៍ដូចម្តេចនៅពេលឈរនៅកណ្តាលគេ?
- សួរអ្នកដែលឈរនៅខាងមុខ ២ទៅ៣នាក់ ហេតុអ្វីបានពួកគេនៅទីនោះ ហើយមានអារម្មណ៍ដូចម្តេចនៅពេលឈរខាងមុខ?

**ជំហានទី៥៖** អនុញ្ញាតឱ្យអ្នកចូលរួមពិភាក្សា ផ្អែកលើការសង្កេត និងគំរូដែលបង្ហាញចេញ។ ប្រើប្រាស់សំណួរទាំងនេះ ដើម្បីសម្របសម្រួល និងផ្សារភ្ជាប់ទៅលើអំណាច ឯកសិទ្ធិ សិទ្ធិ ការទទួលបានសេវា និងឱកាស។

- តើលំហាត់អនុវត្តន៍ បានប្រាប់ឱ្យយើងដឹងពីអ្វី?
- អំពីអំណាច? អំពីឯកសិទ្ធិ? អ្នកសម្របសម្រួលគួររំលេច ឱ្យឃើញថាឯកសិទ្ធិ គឺតែងតែជា «អំណាចដែលបានមកដោយមិនចាំបាច់ខំប្រឹងស្វែងរក »។
- តើអ្វីដែលផ្តល់ឱ្យមនុស្សនូវអំណាច និងឯកសិទ្ធិ និងការទទួលបានសិទ្ធិ និងឱកាស?
- (ឧទាហរណ៍៖ ទ្រព្យសម្បត្តិ ឋានៈក្នុងសង្គម អំណាច ភេទ យេនឌ័រ ជាដើម...)

- ហេតុអ្វីបានជាអំណាច និងឯកសិទ្ធិ ជាអ្វីដែលនាំឱ្យមនុស្សដែលត្រូវបានគេផាត់ចេញ មិនទទួលបានសិទ្ធិ និងឱកាស?
- តើ «អំណាច និងឯកសិទ្ធិ» តែងតែជាអ្វី ដែលមិនល្អឬ? ហេតុអ្វី?
- តើអំណាច ឬឯកសិទ្ធិប្រភេទណាដែលយើងមាន? តើពួកយើងប្រើប្រាស់អំណាចទាំងនោះដោយរបៀបណា ដើម្បីធានាថាវាមិនត្រួតត្រា និងមិនធ្វើឱ្យអ្នកដទៃនៅដាច់ដោយឡែក?

**ជំហានទី៦៖** សន្និដ្ឋានថា ភេទ យេនឌ័រ និងតួនាទីក្នុងសង្គមផ្សេងៗ គឺមានភាពចម្រុះគ្នាដែលមានក្នុងសង្គមរបស់យើង។ គ្រប់គ្នាមានសិទ្ធិស្មើគ្នា មានការទទួលបានធនធាន ឱកាស និងផលប្រយោជន៍ស្មើគ្នាក្នុងការអភិវឌ្ឍ ក៏ដូចជាការទទួលបាននូវសិទ្ធិដែលបានចែងក្នុងក្របខ័ណ្ឌអន្តរជាតិ និងជាតិ ដែលយើងបានពិភាក្សាពីខាងលើ។ ប៉ុន្តែអ្វីដែលយើងបានរៀនសូត្រពីលំហាត់អនុវត្ត **"Life walk"** នេះ គឺអ្នក ដែលងាយរងគ្រោះ គឺត្រូវបានគេផាត់ចោល។ ដូច្នេះយើងត្រូវការយន្តការ និងសកម្មភាពគាំទ្រ ដើម្បីធានាថាទាំងអស់គ្នាមានសិទ្ធិស្មើគ្នា។ យើងអាចចាប់ផ្ដើមសកម្មភាពឆ្លើយតប ហើយបន្ទាប់មកបន្តទៅសកម្មភាពមួយទៀត។

**កំណត់ចំណាំសម្រាប់អ្នកសម្របសម្រួល៖**
តួអង្គសំដែង និងចំនួនតួអង្គដែលត្រូវជ្រើសរើសសម្រាប់ការសំដែងសកម្មភាពគួរតែត្រូវបានពិភាក្សានៅក្នុងក្រុមអ្នកសម្របសម្រួល មុនពេលធ្វើសម្របសម្រួលជាមួយអ្នកចូលរួម។ រឿងសំខាន់មួយ គឺត្រូវប្រាកដថាអ្នកបានបញ្ចូលតួអង្គដែលមានអំណាច ឬមានឋានៈខ្ពស់ និងភាពចម្រុះនៃមនុស្សដែលទំនងជាត្រូវបានគេផាត់ចេញពីសង្គម។ តួអង្គទាំងនោះគួរតែមានការទាក់ទងទៅនឹងសកម្មភាពរបស់គម្រោង។

# វគ្គទី៤៖ យុទ្ធសាស្ត្រសម្រាប់លើកកម្ពស់ ឬការទទួលបានសិទ្ធិរបស់ស្ត្រី

ផ្នែកនេះ ផ្ដល់ការណែនាំពីរបៀបនាំអ្នកចូលរួម ឱ្យបង្កើតផែនការសកម្មភាព ក្នុងការគាំទ្រឱ្យស្ត្រីទទួលបានសិទ្ធិ។ ហើយក៏ណែនាំអ្នកចូលរួម ឱ្យគិតពីវិធីស្វែងរកការគាំទ្រពីបុគ្គលដែលមានទំនួលខុសត្រូវក្នុងស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងសមាជិកសហគមន៍ផងដែរ។

## សកម្មភាព ៦ក៖ ផែនការសកម្មភាព

ផ្នែកនេះ ផ្ដល់ការណែនាំពីរបៀបនាំអ្នកចូលរួម ឱ្យបង្កើតផែនការសកម្មភាព ក្នុងការគាំទ្រឱ្យស្ត្រីទទួលបានសិទ្ធិ។ ហើយក៏ណែនាំអ្នកចូលរួម ឱ្យគិតពីវិធីស្វែងរកការគាំទ្រពីបុគ្គលដែលមានទំនួលខុសត្រូវក្នុងស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងសមាជិកសហគមន៍ផងដែរ។

**វត្ថុបំណង៖** បង្កើតផែនការសកម្មភាព លើកកម្ពស់ និងគាំទ្រស្ត្រី (រាប់បញ្ចូលទាំងស្ត្រីមានពិការភាព ស្ត្រីជនជាតិដើម យេនឌ័រចម្រុះ) ក្នុងការទទួលបានសិទ្ធិ។
**ថេរវេលា** ៖ ៤០នាទី
**វិធីសាស្ត្រ៖** ធ្វើការជាក្រុម និងធ្វើបទបង្ហាញក្នុងក្រុមធំ
**សម្ភារៈ និងការរៀបចំ៖** ក្រដាសផ្ទាំងធំចំនួន៦ផ្ទាំង ហ្វឺត ស្កុតក្រដាស និងក្រដាសដែលមានគូរតារាងផែនការសកម្មភាព។

**អ្វីគួរធ្វើ និងអ្វីមិនគួរធ្វើ៖** សម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយក្រុមតូច ប៉ុន្តែមិនគួរប្រាប់អ្នកចូលរួមអំពីអ្វីដែលអ្នកចង់បានទេ។ ឱ្យពួកគេធ្វើផែនការ និងធានាថាផែនការនោះអាចធ្វើទៅរួច និងសមស្របសម្រាប់ពួកគេ និងសហគមន៍របស់ពួកគេ។ សួរសំណួរប្រដេញ និងលើកទឹកចិត្តឱ្យអ្នកចូលរួមពិភាក្សាពីអ្វីដែលពួកគេមានឆន្ទៈក្នុងការធ្វើការងារដើម្បីជួយគាំទ្រស្ត្រី និងអ្នកដទៃទៀតឱ្យទទួលបានសិទ្ធិនៅកម្រិតក្រុមគ្រួសារ សហគមន៍ និងសហការជាមួយអាជ្ញាធរមូលដ្ឋាន ឬវិស័យឯកជន ដើម្បីផ្ដល់ឥទ្ធិពលជាវិជ្ជមាន រាប់បញ្ចូលទាំងគោលនយោបាយសម្រាប់ភាពស្មើគ្នា និងបរិយាបន្ននៃភាពចម្រុះ។

## ការណែនាំអ្នកសម្របសម្រួល៖

**ជំហានទី១៖** ពន្យល់ពីដំណើរការសកម្មភាព វត្ថុបំណង និងការចូលរួមរបស់ពួកគេកំឡុងពេលធ្វើការងារជាក្រុម។

**ជំហានទី២៖** បែងចែកស្ត្រី និងបុរស ដើម្បីពិភាក្សាលើផ្នែកផ្សេងគ្នា ហើយឱ្យពួកគេនៅឱ្យឆ្ងាយពីគ្នា។ ចែកសម្ភារៈទៅឱ្យក្រុមនីមួយៗ ឱ្យអ្នកចូលរួម ២នាក់ធ្វើជាអ្នកដឹកនាំក្រុម ម្នាក់ដឹកនាំការពិភាក្សា ហើយម្នាក់ទៀតកត់ត្រាដោយបំពេញតារាងផែនការដោយប្រើប្រាស់ផែនការសកម្មភាពដែលផ្តល់ឱ្យ។[17] ក្នុងករណីអ្នកចូលរួមមិនអាចសរសេរបាន និងមិនមានភាពងាយស្រួលក្នុងការពិភាក្សា អ្នកសម្របសម្រួលអាចដឹកនាំកិច្ចពិភាក្សា និងកត់ត្រាជំនួសក្រុមបាន។

សំណួរចង់សួរ ឬមានព័ត៌មានចង់បន្ថែមទៅលើផែនការដែរឬទេ។ ចំណាយពេល ២ទៅ៣នាទី ដើម្បីឆ្លើយ និងបិទបញ្ចប់វគ្គ។

**បញ្ចប់វគ្គ៖** ប្រាប់អ្នកចូលរួមអំពីចុងបញ្ចប់នៃសកម្មភាព និងសង្ខេបវគ្គ។ អរគុណអ្នកចូលរួមសម្រាប់ការចូលរួមដ៏សកម្មរបស់ពួកគេ និងបិទបញ្ចប់វគ្គ។[18]

## និយមន័យ

**សិទ្ធិស្ត្រី៖** សិទ្ធិស្ត្រីត្រូវបានផ្តល់ឱ្យដោយស្មើភាពគ្នាដូចនឹងបុរសនៅគ្រប់វិស័យក្នុងសង្គម។[19]
**សិទ្ធិស្ត្រី៖** សិទ្ធិស្ត្រីជាសិទ្ធិមនុស្ស! សិទ្ធិទាំងនេះរួមបញ្ចូលសិទ្ធិរស់រានមានជីវិតដោយគ្មានអំពើហិង្សា និងការរើសអើង។ សិទ្ធិដើម្បីរីករាយនឹងស្តង់ដារសុខភាពផ្លូវកាយ និងផ្លូវចិត្តកម្រិតខ្ពស់ សិទ្ធិទទួលបានការអប់រំ ជាម្ចាស់កម្មសិទ្ធិ សិទ្ធិបោះឆ្នោត និងសិទ្ធិទទួលបានប្រាក់ឈ្នួលស្មើគ្នា។[20]

**អំណាច៖** សមត្ថភាពធ្វើអ្វីមួយ ឬធ្វើសកម្មភាពតាមរបៀបជាក់លាក់មួយ។ សមត្ថភាពក្នុងការដឹកនាំ ឬមានឥទ្ធិពលលើអាកប្បកិរិយារបស់អ្នកដទៃ ឬដំណើរនៃព្រឹត្តិការណ៍ណាមួយ។ "ដំណើរការនយោបាយដែលផ្តល់អំណាចដល់មនុស្សលើជីវិតរបស់ពួកគេ" ។[21]

**អំណាច៖** លទ្ធិស្ត្រីនិយម (Feminists) មានអំណាចលើផ្នត់គំនិត៖ ជាធនធានដែលត្រូវបានបែងចែកឡើងវិញ ជាការត្រួតត្រា និងជាការពង្រឹងសិទ្ធិអំណាច។[22]

**ឯកសិទ្ធិ៖** ជាសិទ្ធិពិសេស អត្ថប្រយោជន៍ ឬអភ័យឯកសិទ្ធិដែលត្រូវបានផ្តល់ ឬមានសម្រាប់តែបុគ្គល ឬក្រុមជាក់លាក់ណាមួយប៉ុណ្ណោះ។ ឧទាហរណ៍៖ "ការអប់រំគឺជាសិទ្ធិ មិនមែនជាឯកសិទ្ធិទេ"

**ឯកសិទ្ធិ៖** ឯកសិទ្ធិ គឺជាផលប្រយោជន៍ និងគុណតម្លៃដែលក្តោបក្តាប់ដោយក្រុមមានអំណាច ឬក្រុមមនុស្សដែលមានសំឡេងច្រើន ដែលបានដោយសារការកៀបសង្កត់ និងបង្ក្រាបក្រុមដែលមានសំឡេងតិច។ ជាងនេះទៅទៀត ឯកសិទ្ធិត្រូវបានឱ្យនិយមន័យដោយក្នុងន័យយុត្តិធម៌សង្គមថា ជាផលប្រយោជន៍ដែលក្រុមមនុស្សទាំងនោះទទួលបាន ដោយពួកគេពុំចាំបាច់គិតអំពីវានោះទេ...។[23]

---

[17] តារាងផែនការសកម្មភាព ដែលភ្ជាប់ក្នុងឧបសម្ព័ន្ធ ៦ក-១
[18] https://dictionary.cambridge.org/dictionary/english/women-s-rights
[19] Women's rights are human rights!. Amnesty International. Retrieved here
[20] Oxford Dictionary.
[21] https://plato.stanford.edu/entries/feminist-power/
[22] Oxford Dictionary.
[23] Privilege and Intersectionality. Rider University library. Retrieved here

## ឧបសម្ព័ន្ធ ១ក-១៖ សន្លឹកកិច្ចការស្ដីពីសិទ្ធិមនុស្ស

| លេខ | ខ្ញុំជឿថាទាំងអស់គ្នាមានសិទ្ធិ | យល់ស្រប √ | មិនយល់ស្រប ✕ | មិនច្បាស់ √ |
|---|---|---|---|---|
| ១ | ធ្វើការសម្រេចចិត្តទៅលើជីវិតរបស់ពួកគេ | | | |
| ២ | និយាយចេញពីការគិតរបស់ពួកគេ | | | |
| ៣ | រកចំណូល (លុយ) | | | |
| ៤ | ធ្វើការសម្រេចចិត្តទៅលើហិរញ្ញវត្ថុ | | | |
| ៥ | សម្រេចចិត្តនៅពេលពួកគេចង់ (និងមិនចង់) រួមភេទ | | | |
| ៦ | ចេញ ចូលផ្ទះដោយសេរី | | | |
| ៧ | ឯកជនភាព | | | |
| ៨ | សម្រាក | | | |
| ៩ | ទទួលបានព័ត៌មាន | | | |
| ១០ | ទទួលបានសុវត្ថិភាព | | | |
| ១១ | ទទួលបានការថែទាំសុខភាព | | | |
| ១២ | ទទួលបានការអប់រំ ឬទៅសាលារៀន | | | |

## ឧបសម្ព័ន្ធ ១ក-២៖ សន្លឹកកិច្ចការស្តីពីសិទ្ធិមនុស្ស ក្នុងភាពជាក់ស្តែង

| លេខ | តើមនុស្សភាគច្រើនមានអំណាចដើម្បី? | បុរសនៅក្នុងសហគមន៍របស់អ្នក | | | ស្ត្រីនៅក្នុងសហគមន៍របស់អ្នក | | | ក្រុមអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងសហគមន៍របស់អ្នក | | |
|---|---|---|---|---|---|---|---|---|---|---|
| | | មែន√ | ទេ✕ | មិនច្បាស់ | មែន √ | ទេ ✕ | មិនច្បាស់ | មែន √ | ទេ ✕ | មិនច្បាស់ |
| ១ | ធ្វើការសម្រេចចិត្តទៅលើជីវិតរបស់ពួកគេ | | | | | | | | | |
| ២ | និយាយចេញពីការគិតរបស់ពួកគេ | | | | | | | | | |
| ៣ | រកចំណូល (លុយ) | | | | | | | | | |
| ៤ | ធ្វើការសម្រេចចិត្តទៅលើហិរញ្ញវត្ថុ | | | | | | | | | |
| ៥ | សម្រេចចិត្តនៅពេលពួកគេចង់ (និងមិនចង់) រួមភេទ | | | | | | | | | |
| ៦ | ចេញ ចូលផ្ទះដោយសេរី | | | | | | | | | |
| ៧ | ឯកជនភាព | | | | | | | | | |
| ៨ | សម្រាក | | | | | | | | | |
| ៩ | ទទួលបានព័ត៌មាន | | | | | | | | | |
| ១០ | រស់នៅដោយគ្មានភាពភ័យខ្លាច | | | | | | | | | |
| ១១ | មានសុវត្ថិភាព នៅផ្ទះ និងនៅទីសាធារណៈ | | | | | | | | | |
| ១២ | ការពារខ្លួនពីជំងឺកាមរោគ (ជំងឺឆ្លងតាមការរួមភេទ) | | | | | | | | | |
| | **បូកសរុបចំនួនសញ្ញា √** | | | | | | | | | |

# ឧបសម្ព័ន្ធ ១ក-៣៖ សន្លឹកកិច្ចការផែនការ

| កម្រិត និងផ្នែកនៃការផ្លាស់ប្ដូរ | តើសកម្មភាពឬអ្វីដែលអ្នកនឹងធ្វើក្នុងផ្នែកនីមួយៗ ដើម្បីលើកកម្ពស់ ការទទួលបានសិទ្ធិរបស់ស្ត្រី? | តើអ្នកនឹងធ្វើដោយរបៀបណា? | តើអ្នកនឹងធ្វើនៅពេលណា? | តើអ្នកត្រូវការការគាំទ្រអ្វី ហើយត្រូវការពីនរណា? |
|---|---|---|---|---|
| បុគ្គល | ១ | | | |
| | ២ | | | |
| | ៣ | | | |
| គ្រួសារ | ១ | | | |
| | ២ | | | |
| | ៣ | | | |
| សហគមន៍ | ១ | | | |
| | ២ | | | |
| | ៣ | | | |

# ម៉ូឌុល ៦៖

## ការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី



**ថេរវេលា៖** ៣ម៉ោង

**វត្ថុបំណង៖** លើកកម្ពស់ការចូលរួមរបស់ស្ត្រី និងក្មេងស្រីក្នុងវិស័យសេដ្ឋកិច្ច ដោយមានអត្ថប្រយោជន៍ និងបន្ទុកការងារស្មើភាពគ្នា ដើម្បីគាំទ្រសមភាពយេនឌ័រ និងសុខុមាលភាពបុគ្គល គ្រួសារ និងសហគមន៍។

**សេចក្តីផ្តើម៖**

**ថេរវេលា៖** ១០ ទៅ ១៥ នាទី

**វត្ថុបំណង៖** ស្វាគមន៍អ្នកចូលរួម ឬសមាជិកសហគមន៍មកកាន់វគ្គបណ្តុះបណ្តាល។ បង្ហាញពីដំណើរការ ប្រាប់ និងបង្កើតបរិយាកាសការងារវិជ្ជមានមុននឹងចាប់ផ្តើមសកម្មភាព។

**ការណែនាំសម្រាប់អ្នកសម្របសម្រួល៖**

**ជំហានទី១៖** ស្វាគមន៍អ្នកចូលរួម ឬសមាជិកសហគមន៍។ ណែនាំអំពីក្រុមអ្នកសម្របសម្រួល ស្ថាប័នដៃគូក្នុងតំបន់ អាជ្ញាធរភូមិ និងអ្នកផ្សេងទៀតដែលមានវត្តមាននៅក្នុងវគ្គបណ្តុះបណ្តាល។

**ជំហានទី២៖** បង្ហាញពីគោលបំណងនៃវគ្គ ប្រាប់អ្នកចូលរួមអំពីថេរវេលាដែលត្រូវការសម្រាប់វគ្គ ពន្យល់ពីដំណើរការ និងសុំអនុញ្ញាតអ្នកចូលរួមក្នុងការថតរូប និងប្រើប្រាស់រូបថត (ប្រើប្រាស់ទម្រង់នៃគោលការណ៍ណែនាំរបស់ស្ថាប័ន និងទម្រង់នៃគោលការណ៍កិច្ចព្រមព្រៀង។

**ជំហានទី៣៖** បង្កើតបរិយាកាសវិជ្ជមានជាមួយអ្នកចូលរួមដោយដាក់ចេញនូវផ្នត់គំនិតសង្គមដែលសាមញ្ញៗ។ ប្រើប្រាស់សំណួរខាងក្រោមដើម្បីពិភាក្សា៖

- តើយើងគួរធ្វើដូចម្តេច ដើម្បីធានាថាអ្នកគ្រប់គ្នាមានឱកាសបង្ហាញពីគំនិតរបស់ពួកគេ និងមានអារម្មណ៍ល្អ និងសុវត្ថិភាព ក្នុងការចូលរួមក្នុងកិច្ចពិភាក្សា?
- តើយើងគួរធ្វើដូចម្តេច នៅពេលអ្នកដទៃទៀត បញ្ចេញយោបល់របស់គេ?
- តើយើងគួរធ្វើដូចម្តេចក្នុងការបង្ហាញពីការគោរពទៅកាន់អ្នកដទៃ ដើម្បីទទួលបានភាពនូវភាពសុខដុម និងសាមគ្គីភាព?
- តើយើងគួរធ្វើដូចម្តេចទៀត ដើម្បីធានាថាកិច្ចពិភាក្សារបស់យើងនឹងបញ្ចប់ទៅតាមពេលកំណត់ និងមានអត្ថន័យ?

កំឡុងពេល ការពិភាក្សាលើសំណួរខាងលើ អ្នកសហការសម្របសម្រួល កត់ត្រាចម្លើយរបស់អ្នកចូលរួមនៅលើក្រដាសផ្ទាំងធំ និងសង្ខេបសារគន្លឹះទៅអ្នកចូលរួម និងរំលឹកឡើងវិញអំពីអ្វី ដែលសមាជិកនឹងធ្វើតាម។ សួរអ្នកចូលរួម ថាតើពួកគេមានសំណួរដែរឬទេ ប្រសិនបើមាន សូមចំណាយពេល ២ ទៅ ៣នាទី ឆ្លើយសំណួរដោយភ្ជាប់ជាមួយសកម្មភាពបន្ទាប់ និងធ្វើសកម្មភាពបន្ត។

## វគ្គទី១៖ សេចក្តីណែនាំ និងការបើកឱ្យមានបរិយាកាសសុវត្ថិភាព

### សកម្មភាព ១៦៖ “ការណាត់ជួប” “SPEED DATING”[24]

**វត្ថុបំណង៖** សិក្សាពីគ្នាទៅវិញទៅមក កសាងការទុកចិត្ត បង្កើតបរិយាកាសសុវត្ថិភាព និងទំនាក់ទំនងក្នុងចំណោមអ្នកចូលរួម និងចែករំលែកតម្រូវការ និងក្តីស្រមៃ សម្រាប់ការពង្រឹងសេដ្ឋកិច្ចគ្រួសារ ដើម្បីសុភមង្គលគ្រួសារ និងសុខុមាលភាព។

[24] Adapted from CARE GED training tool kit (Introduction activity)

**ថេរវេលា៖** ២០នាទី
**វិធីសាស្ត្រ៖** ធ្វើការងារជាដៃគូ ការពិភាក្សាដែលសកម្ម ការស្វែងរកខ្លួនឯង និងការចែករំលែក។
សម្ភារៈ និងការរៀបចំ៖ ក្រដាសផ្ទាំងធំចំនួន២សន្លឹក ហ្វឺតពណ៌ចំនួន៣ដើម ស្កុតក្រដាស១ដុំ រៀបចំបញ្ជីសំណួរសម្រាប់ពិភាក្សា។

**អ្វីគួរធ្វើ និងអ្វីមិនគួរធ្វើ៖** លើកទឹកចិត្តអ្នកចូលរួមឱ្យចែករំលែកគំនិតរបស់ពួកគេ ប៉ុន្តែមិនបង្ខិតបង្ខំ មិនវិនិច្ឆ័យ និងឱ្យតម្លៃនូវគំនិតយោបល់របស់គ្រប់គ្នា។ ប្រើប្រាស់ការលើកដាក់សម្លេងទន់ភ្លន់ និងត្រឹមត្រូវ។ ធានាថាគ្រប់គ្នាមានភាពងាយស្រួល និងរួចរាល់ក្នុងការចូលរួមក្នុងការពិភាក្សា។ អ្នកសម្របសម្រួលជានិច្ចកាលគួរប្រើប្រាស់ការទំនាក់ទំនងទៅវិញទៅមក និងលើកកម្ពស់ឱ្យមានការពិភាក្សាតាមរយៈវិធីសាស្ត្ររៀនសូត្របែបមនុស្សពេញវ័យ។[25] មិនត្រូវប្រើប្រាស់ “កំប្លែងបែបអាសអាភាស” ឬ “រឿងអស់សំណើច” ដែលទាក់ទងនឹង ជាតិសាសន៍ អំបូរ យេនឌ័រ នៅក្នុងសកម្មភាពល្បែងថាមពល។

## ការណែនាំសម្រាប់អ្នកសម្របសម្រួល៖

**ជំហានទី១៖** ពន្យល់ពីវិធីសាស្ត្រធ្វើសកម្មភាព ឬដំណើរការ និងបង្ហាញពីវត្ថុបំណងនៃសកម្មភាព។

**ជំហានទី២៖** ធ្វើការងារ និងពិភាក្សាជាដៃគូ។ អ្នកចូលរួមអាចជ្រើសរើសដៃគូផ្ទាល់ខ្លួន ឬអ្នកដែលអង្គុយជិតជាដៃគូ។ អ្នកសម្របសម្រួលសួរសំណួរនាំ ដើម្បីដឹកនាំឱ្យមានការពិភាក្សាដូចខាងក្រោម។ អ្នកចូលរួមឆ្លាស់វេនគ្នាសួរសំណួរ។ ប្រើពេល៣នាទី ពិភាក្សាសំណួរនីមួយៗ បន្ទាប់ពីអ្នកចូលរួមបានបញ្ចប់ការពិភាក្សាសំណួរនីមួយៗ ឱ្យដៃគូដែលស្ម័គ្រចិត្ត ២ទៅ៣គូ ធ្វើការចែករំលែកលទ្ធផលនៃការពិភាក្សារបស់ពួកគេ។

**សំណួរនាំ៖**

- តើអ្វីជាមុខរបរ ឬសកម្មភាពសេដ្ឋកិច្ចចម្បង ដែលផ្តល់ចំណូលឱ្យគ្រួសាររបស់អ្នក?
- តើសមាជិកគ្រួសារបានចូលរួមយ៉ាងដូចម្តេចក្នុងមុខរបរនេះឬសកម្មភាពសេដ្ឋកិច្ចនេះ?
- តើការគាំទ្រប្រភេទណា និង/ឬ គោលនយោបាយណាដែលអ្នកបានទទួលពីអាជ្ញាធរក្នុងតំបន់ ឬអ្នកមានមុខរបរសម្រាប់ដំណើរការមុខរបរ ឬសកម្មភាពសេដ្ឋកិច្ចនេះ?
- តើអ្នកមានបំណងបង្កើនប្រាក់ចំណូលគ្រួសាររបស់អ្នកឬទេ? ហេតុអ្វី?

តាមយោបល់របស់អ្នក តើការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីគឺជាអ្វី?
ក្នុងពេលដែលអ្នកចូលរួមចែករំលែកការពិភាក្សារបស់ពួកគេ អ្នកសម្របសម្រួល កត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ និងចាត់ថ្នាក់ចម្លើយទៅតាមសំណួរនីមួយៗ។

**ជំហានទី៣៖** ធ្វើសេចក្តីសន្និដ្ឋានទៅលើសកម្មភាព ដោយសង្ខេបលទ្ធផលចេញពីសំណួរនីមួយៗ។ ចែករំលែក និងពន្យល់អំពីនិយមន័យ នៃការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី ដូចខាងក្រោម។

ការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី គឺជាស្នូលនៃការយល់ដឹងពីសិទ្ធិស្ត្រី និងសមភាពយេនឌ័រ។ ការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី រាប់បញ្ចូលសមត្ថភាពស្ត្រីក្នុងការចូលរួមដោយស្មើភាពក្នុងទីផ្សារដែលមានស្រាប់ ការទទួលបាន និងការគ្រប់គ្រងទៅលើធនធានដែលមានផលិតភាពទទួលបានការងារសមរម្យ ការគ្រប់គ្រងលើពេលវេលា ជីវិត និងរាងកាយដែលជារបស់ខ្លួនផ្ទាល់ និងបង្កើនសំឡេង ភ្នាក់ងារ និងការចូលរួមដែលមានអត្ថន័យក្នុងការសម្រេចចិត្តផ្នែកសេដ្ឋកិច្ច នៅគ្រប់កម្រិត ចាប់ពីកម្រិតគ្រួសារ ទៅដល់កម្រិតស្ថាប័នអន្តរជាតិ។[26]

[25] https://www.ispringsolutions.com/blog/adult-learning-theories)
[26 ] https://www.unwomen.org/en/what-we-do/economic-empowerment/facts-and-figures

រំលឹកអ្នកចូលរួមថាអ្នកចូលរួមពួកគេនឹងពិភាក្សាពីលទ្ធផលទាំងនេះ ជាពិសេសលើការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី និងស្វែងរកវិធីសាស្ត្រធ្វើការជាមួយគ្នាក្នុងគ្រួសារ និងសហគមន៍ក្នុងសកម្មភាពបន្ទាប់។

**កំណត់សម្គាល់៖** អ្នកសម្របសម្រួលអាចដឹកនាំអ្នកចូលរួមឱ្យអនុវត្តន៍ល្បែងថាមពលប្រសិនគាត់ត្រូវការ។ អ្នកអាចសម្រេចចិត្តថាត្រូវលេងល្បែងថាមពលអ្វី ផ្អែកលើការសង្កេតរបស់អ្នក។ ប្រសិនអ្នកចូលរួមមិនទាន់រួចរាល់ក្នុងការចូលរួមពិភាក្សាទេ សូមប្រើពេល ៥នាទីលេងល្បែងថាមពល។ ជាការល្អដែលបាននាំពួកគេពិភាក្សាដោយកសាងទំនាក់ទំនងតាមរយៈល្បែងថាមពល។

## វគ្គទី២៖ តួនាទីស្ត្រី និងបុរសក្នុងវិស័យសេដ្ឋកិច្ច

### សកម្មភាព ២ខ៖ "ដូងអណ្តែតទឹក" "FLOATING COCONUT"[27]

វត្ថុបំណង៖ ដើម្បីស្វែងយល់ពីតួនាទីរបស់ស្ត្រី បុរស ក្មេងប្រុស និងក្មេងស្រី និងភាពចម្រុះយេនឌ័រក្នុងវិស័យសេដ្ឋកិច្ចក៏ដូចជាយល់ពីរបាំង និងឧបសគ្គដែលក្រុមនីមួយៗជួបប្រទះ និងធ្វើការកត់សម្គាល់ពីវិធីសាស្ត្រដោះស្រាយឧបសគ្គ ដើម្បីគាំទ្រគ្រួសារ និងសហគមន៍ និងទទួលបានសុខុមាលភាពដែលមានភាពស្មើគ្នា។

**ថេរវេលា ៖ ៥០នាទី**
វិធីសាស្ត្រ៖ បែងចែកក្រុមស្ត្រី និងបុរសសម្រាប់ក្រុមពិភាក្សា (ច្រើនបំផុត១៥នាក់ក្នុង១ក្រុម)។ ការបែងចែកបុរស និងស្ត្រីឱ្យធ្វើការងារក្នុងក្រុមផ្សេងគ្នា គឺមានសារៈសំខាន់ដើម្បីពួកគេឱ្យពួកគេមានអារម្មណ៍ងាយស្រួលក្នុងការចែករំលែក និងការពិភាក្សាដោយបើកចំហរ។
**សម្ភារៈ និងការរៀបចំ៖** ក្រដាសផ្ទាំងធំចំនួន១០សន្លឹក ហ្វឺត១០ដើម កាតដែលមាន៥ពណ៌ ស្កុតក្រដាស គូររូបដូងអណ្តែតទឹក (សូមមើលរូបក្នុងជំហានទី៤) និងរៀបចំបញ្ជីសំណួរពិភាក្សា។

**អ្វីគួរធ្វើ និងអ្វីមិនគួរធ្វើ៖** ធ្វើការសម្របសម្រួលយ៉ាងជិតស្និទ្ធក្នុងក្រុមតូច និងក្រុមធំ ប៉ុន្តែមិនផ្តល់ និងស្នើចម្លើយទេ គោរពគំនិតរបស់អ្នកចូលរួម ហើយរក្សាការសម្របសម្រួលការពិភាក្សាដែលពាក់ព័ន្ធនឹងប្រធានបទ និងធានាថាអ្នកចូលរួម ចូលរួមពិភាក្សា នឹងចែករំលែកបទពិសោធន៍ផ្សេងៗគ្នា និងឧបសគ្គដែលពួកគេជួបប្រទះ។ ជៀសវាងការពិភាក្សាដែលអាចនាំទៅដល់ការផាត់ចេញ ជាប់ទាក់ទងនឹងហិង្សាផ្លូវចិត្ត ឬការអាម៉ាស។ ធានាថាក្រុមនីមួយៗមានអ្នកសម្របសម្រួលចំនួន ២នាក់ធ្វើការជាមួយគ្នា និងរាប់បញ្ចូលអ្នកចម្រុះយេនឌ័រ (ប្រសិនជាមាន) ដើម្បីបង្កើតបរិយាកាសប្រកបដោយបរិយាបន្ន។ ក្រុមនីមួយៗត្រូវបំពេញជំហានទី៣ ដល់ទី៤ ក្នុងសកម្មភាពនេះមុននឹងត្រឡប់មកក្រុមធំវិញ។ នៅក្នុងករណីដែលមានអ្នកចម្រុះយេនឌ័រចូលរួម អ្វីដែលត្រូវធ្វើគឺត្រូវបែងចែកក្រុមដោយផ្អែកលើភេទ ឬក៏ឱ្យពួកគេជ្រើសរើសក្រុមដោយខ្លួនឯងដើម្បីពិភាក្សា។

## ការណែនាំសម្រាប់អ្នកសម្របសម្រួល៖

**ជំហានទី១៖** បង្ហាញពីវត្ថុបំណង ពន្យល់ពីវិធីសាស្ត្រធ្វើសកម្មភាព និងចែកសម្ភារៈសម្រាប់ក្រុមការងារ។

**ជំហានទី២៖** បែងចែកជាក្រុមស្ត្រី និងក្រុមបុរស ឬចែកអ្នកចូលរួមជាក្រុមតូចប្រសិនបើមានតែស្ត្រី ឬបុរសក្នុងវគ្គ។ ធានាថាក្រុមនីមួយៗនៅឆ្ងាយពីគ្នា ដូច្នេះពួកគេមិនធ្វើឱ្យមានការរំខាន។
ជំហានទី៣៖ ឱ្យពេល២០នាទីសម្រាប់ក្រុមពិភាក្សា។ មុននឹងចាប់ផ្តើមសកម្មភាព, ពន្យល់អ្នកចូលរួមថា ការពិភាក្សាគឺអំពីតួនាទីយេនឌ័រ ក្នុងសកម្មភាពសេដ្ឋកិច្ចផ្អែកទៅលើបទពិសោធន៍ជីវិតរបស់ពួកគេ។ ប្រើប្រាស់ឧទាហរណ៍នៃសកម្មភាពនីមួយៗខាងក្រោម ដើម្បីនាំការពិភាក្សា ប៉ុន្តែកុំប្រាប់អ្នកចូលរួមលម្អិតអំពីសកម្មភាពនីមួយៗ។ សកម្មភាពរួមមាន៖ (១) សកម្មភាពសេដ្ឋកិច្ចក្នុងប្រព័ន្ធ (២) សកម្មភាពសេដ្ឋកិច្ចក្រៅប្រព័ន្ធ (៣) សកម្មភាពមើលថែទាំក្នុងផ្ទះ (៤) សកម្មភាពសហគមន៍ និង (៥) ការសម្រេចចិត្តលើប្រាក់កាស។

[27] Adapted from International Development Agency (Gender and Economic Tool Kit)

1. **សកម្មភាពសេដ្ឋកិច្ចក្នុងប្រព័ន្ធ៖** សកម្មភាព ឬការងារដែលជាប់ទាក់ទងនឹងការបង់ពន្ធជូនរដ្ឋ, ការអនុវត្តការងារនៅស្ថាប័នរាជរដ្ឋាភិបាល ក្រុមហ៊ុនដែលចុះបញ្ជី រោងចក្រ ហាង ភោជនីយដ្ឋាន កងកំលាំង មន្ទីរពេទ្យ សាលារៀន កម្មករសំណង់អចិន្ត្រៃយ៍ អ្នកកាន់មុខជំនួញ បើកហាងសម្ផស្ស ហាងកាត់សក់ គ្រប់គ្រងមុខជំនួញខ្នាតតូចរបស់គ្រួសារ និងសហគ្រិន ជាដើម..។
2. **សកម្មភាពសេដ្ឋកិច្ចក្រៅប្រព័ន្ធ៖** មុខជំនួញលក្ខណៈគ្រួសារ កម្មករកុងត្រារយៈពេលខ្លី ដាំបន្លែ ដកដំឡូង ដាំអំពៅ ដាំពោត ចិញ្ចឹមជ្រូក មាន់ គោ ក្របី សម្រាប់លក់ បើកហាងលក់បន្ត នៅផ្ទះ ឬតាមផ្លូវក្បែរផ្ទះ ឬនៅផ្សារ កាត់ដេរ បើកឡានតាក់ស៊ី ជាដើម...។
3. សកម្មភាពមើលថៃទាំផ្ទះ៖ មើលកូន មើលថែមនុស្សចាស់ មានជំងឺ អ្នកមានពិការភាព ដាំស្ល សម្អាត...។
4. **សកម្មភាពសហគមន៍៖** ចូលរួមក្នុងពិធីសាសនា ដាំស្លសម្រាប់កម្មវិធីសហគមន៍ អាពាហ៍ពិពាហ៍ ឡើងផ្ទះ ចូលរួមប្រជុំ ធ្វើស្រែ ចូលរួមក្នុងក្រុមសន្សំចូលរួមក្នុងព្រឹត្តការណ៍សហគ្រិនភាពសង្គមខ្នាតតូច និងក្រៅប្រព័ន្ធ ជាដើម...។
5. **ធ្វើការសម្រេចចិត្តលើប្រាក់កាស៖** ទិញម្ហូប សំលៀកបំពាក់កូន ការសិក្សារបស់កូន ថ្លៃព្យាបាល សម្ភារៈធ្វើកសិកម្ម ឡាន ម៉ូតូ វិនិយោគ យកកម្ចី សងកម្ចី ជាដើម...។

**ប្រើប្រាស់សំណួរនាំខាងក្រោមដើម្បីសម្របសម្រួល៖**
១. តើការងារ ឬសកម្មភាពសេដ្ឋកិច្ចណាខ្លះដែលអ្នកបានធ្វើនៅក្នុងខែចុងក្រោយនេះ និងនៅពេលបច្ចុប្បន្ន? (ផ្តោតលើសកម្មភាពផ្នែកទី១ ដល់ទី៤)
២. តើការសម្រេចចិត្តណាខ្លះ ដែលអ្នកបានធ្វើលើការចំណាយលុយក្នុងផ្ទះរបស់អ្នក? (ផ្តោតលើសកម្មភាពផ្នែកទី៥)

**ជំហានទី៤៖** កំឡុងពេលពិភាក្សា សមាជិកក្រុម ឬអ្នកសម្របសម្រួលសរសេរសកម្មភាពដែលអ្នកចូលរួមពួកគេពិភាក្សានៅលើកាត (ក្នុងករណីអ្នកចូលរួមមិនអាចសរសេរបាន) ១ពណ៌ សម្រាប់ ១សកម្មភាពសេដ្ឋកិច្ច ការងារ១ ឬសកម្មភាព១ សម្រាប់កាត១។ ស្នើអ្នកចូលរួមឱ្យដាក់កាតលើផ្នែកនីមួយៗនៃផ្លែដូង ដូចរូបភាពខាងក្រោម។

## ផ្លែដូងអណ្តែត



**ជំហានទី៥៖** ពិភាក្សាក្នុងក្រុមធំ៖ នៅពេលដែលក្រុមនីមួយៗបានបញ្ចប់ការបំពេញទៅលើផ្លែដូងរបស់ពួកគេ អ្នកសម្របសម្រួលនាំអ្នកចូលរួមទាំងអស់គ្នាមកក្រុមធំវិញ ហើយឱ្យអ្នកតំណាងក្រុមបង្ហាញពីការងាររបស់ក្រុមរបស់ពួកគេទៅកាន់ក្រុមធំ។ អ្នកសម្របសម្រួល ដឹកនាំការពិភាក្សាក្នុងក្រុមធំ ដោយប្រើប្រាស់សំណួរនាំដូចតទៅ៖

- តើអ្នកមានអារម្មណ៍ដូចម្តេច នៅពេលអនុវត្តសកម្មភាពនេះជាមួយគ្នា?
- តើអ្នកបានរៀនសូត្រអ្វីខ្លះពីសកម្មភាពនេះ?
- មើលទៅផ្លែដូង តើមានចំណុចខុសគ្នាណាខ្លះរវាងក្រុមស្ត្រី និងក្រុមបុរស? ហេតុអ្វីបានជាបែបនេះ?
- តើអ្នកគិតថាវាស្មើគ្នា ឬទេ? បើមិនទេតើមកពីហេតុអ្វី?
- ភាគច្រើន តើនរណាជាអ្នកមានឱកាសធ្វើការងារក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ដែលជាការងារមានសុវត្ថិភាព និងប្រហែលជាទទួលបានប្រាក់ឧបត្ថម្ភខ្ពស់ ប្រៀបធៀបនឹងអ្នកដែលធ្វើការងារក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ? ហេតុអ្វីបានជាបែបនេះ?
- ភាគច្រើន តើនរណាជាអ្នកមានឱកាសធ្វើការងារក្នុងសកម្មភាពសេដ្ឋកិច្ចក្រៅប្រព័ន្ធ? ហេតុអ្វីបានជាបែបនេះ?
- ភាគច្រើន តើនរណាជាអ្នកមិនអាចចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចក្នុងប្រព័ន្ធ? ហេតុអ្វី?
- ភាគច្រើន តើនរណាជាអ្នកធ្វើការសម្រេចចិត្តលើការចំណាយប្រាក់កាស? ហេតុអ្វី?
- ភាគច្រើន តើនរណាជាអ្នកធ្វើការងារថែទាំផ្ទះ? តើនឹងមានឧបសគ្គអ្វីកើតឡើង នៅពេលដែលបុគ្គលនេះ ចូលរួមក្នុងមុខជំនួញ (ទាំងសេដ្ឋកិច្ចក្នុង និងក្រៅប្រព័ន្ធ)?
- ចុះចំណែកឯក្មេងស្រី និងក្មេងប្រុសវិញ អ្នកមានពិការភាព ជនជាតិដើម និងអ្នកដែលមានយេនឌ័រចម្រុះ តើពួកគេអាចចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចក្នុងប្រព័ន្ធបានដែរឬទេ? ប្រសិនបើបាន តើពួកគេបានចូលរួម ឬមានទំនាក់ទំនងយ៉ាងដូចម្តេចជាមួយនឹងសកម្មភាពសេដ្ឋកិច្ចទាំងនេះ? ប្រសិនមិនបាន តើអ្វីជាឧបសគ្គសម្រាប់ពួកគេ? ហើយតើអាជ្ញាធរក្នុងតំបន់ និងគម្រោងផ្សេងៗ ធ្វើដូចម្តេចដើម្បីគាំទ្រពួកគេ?

**ជំហានទី៦៖ សន្និដ្ឋាន**

- សង្ខេបដោយខ្លីនូវសកម្មភាព ដោយគូសបង្ហាញសកម្មភាពសំខាន់ៗក្នុងផ្នែកនីមួយៗនៃផ្លែដូង។
- ស្គាល់ពីសារៈសំខាន់នៃតួនាទីរវាងស្ត្រី និងបុរស និងក្រុមដែលមានយេនឌ័រចម្រុះក្នុងផ្នែកសេដ្ឋកិច្ច ហើយតួនាទីទាំងនោះ គឺសំខាន់ក្នុងការអភិវឌ្ឍគ្រួសារ និងសេដ្ឋកិច្ចសហគមន៍។
- គូសបង្ហាញនូវរបាំង និងឧបសគ្គដែលស្ត្រី បុរស ក្រុមងាយរងគ្រោះជួបប្រទះ ក្នុងសកម្មភាពសេដ្ឋកិច្ច។
- ប្រាប់អ្នកចូលរួមថា យើងនឹងធ្វើសកម្មភាពបន្ទាប់ ដើម្បីសិក្សា និងវិភាគពីសារៈសំខាន់នៃតួនាទីស្មើគ្នារវាងស្ត្រី និងបុរស ក្មេងស្រី និងក្មេងប្រុស គឺដើម្បីគាំទ្រសុភមង្គល និងសុខុមាលភាពគ្រួសារ និងសហគមន៍។ ពិនិត្យថាតើអ្នកចូលរួមមានសំណួរដែរឬទេ ប្រសិនបើមាន ប្រើពេល ២ទៅ៣នាទី ដើម្បីឆ្លើយ និងភ្ជាប់ការពិភាក្សាទៅសកម្មភាពបន្ទាប់។

## វគ្គទី៣៖ ការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី សុភមង្គល និងសុខុមាលភាពគ្រួសារ

### សកម្មភាព ៣ខ៖ “ទម្រង់បែបសម្បុកពីងពាង នៃគ្រួសារមានសុភមង្គល និងសុខុមាលភាព” “Family Happiness and Wellbeing’s Spider Web”[28]

**វត្ថុបំណង៖** ដើម្បីវិភាគថា តើយេនឌ័រនៅក្នុងសកម្មភាពសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធមានភាពស្មើគ្នាយ៉ាងណា និងមានសារៈសំខាន់យ៉ាងណាចំពោះស្ត្រី និងបុរស និងកុមារ ដើម្បីគាំទ្រសុភមង្គល និងសុខុមាលភាពគ្រួសារ។
**ថេរវេលា** ៖ ៣០នាទី

**អ្វីគួរធ្វើ និងអ្វីមិនគួរធ្វើ៖** ធានាថាគ្រប់គ្នាបានចូលរួមក្នុងការពិភាក្សា មិនមានការវិនិច្ឆ័យ និងលើកទឹកចិត្តអ្នកចូលរួមដើម្បីពិភាក្សាដោយរីករាយ (រំលឹកពីកិច្ចព្រមព្រៀងសាមញ្ញៗដែលទើបបានបង្កើតក្នុងក្រុម)។

### ការណែនាំសម្រាប់អ្នកសម្របសម្រួល៖

ជំហានទី១៖ ណែនាំពីវត្ថុបំណងសកម្មភាព និងដំណើរការវគ្គ។
ជំហានទី២៖ ដាក់រូបភាពសំបុកពីងពាងដែលបានគូររួច នៅលើជញ្ជាំង ហើយត្រូវប្រាកដថាគ្រប់គ្នាអាចមើលឃើញច្បាស់ពីចំងាយ (មើលរូបភាពខាងក្រោម)។




**ជំហានទី៣៖** ប្រើប្រាស់សំណួរនាំ ដែលមាននៅក្នុងតារាងខាងក្រោមដើម្បីពិភាក្សា និងវាស់វែងពីកម្រិតនៃភាពរីករាយ អាហារ សុខភាព ទ្រព្យសម្បត្តិ សេដ្ឋកិច្ចគ្រួសារ និងការអភិវឌ្ឍសហគមន៍។
គូសចំណាំ និងភ្ជាប់លេខពីជុំទី១នៃការពិភាក្សា ធ្វើដូចគ្នាសម្រាប់ជុំទី២នៃការពិភាក្សា។
**កំណត់សម្គាល់៖** លេខ១ គឺជាពិន្ទុទាបជាងគេ។ លេខ២ គឺមធ្យម និងលេខ៣ គឺខ្ពស់ជាងគេ។ ពិន្ទុអាចត្រូវបានដាក់ឱ្យនៅលើចំណុច ចន្លោះពី ១ដល់៣ អាស្រ័យលើការព្រមព្រៀងជាមួយមតិភាគច្រើនពីអ្នកចូលរួម។

[28] Adapted from Helvetas Laos (Women’s Empowerment tool)

| | សំណួរពិភាក្សាជុំទី១ | សំណួរពិភាក្សាជុំទី២ |
|---|---|---|
| ១. ភាពរីករាយរបស់ស្ត្រី និងប្រពន្ធ | ១. ប្រសិនបើស្ត្រីមិនមានប្រាក់ចំណូលថេរទេ តើភាពរីករាយរបស់ពួកគេស្ថិតនៅលេខប៉ុន្មាន? | ១. ប្រសិនបើស្ត្រីមានប្រាក់ចំណូលថេរទេ តើភាពរីករាយរបស់ពួកគេស្ថិតនៅលេខប៉ុន្មាន? |
| ២. ភាពរីករាយរបស់បុរស និងប្តី | ២. ប្រសិនប្រពន្ធរវល់ជាមួយកិច្ចការងារផ្ទះ គាត់មិនអាចធ្វើរួចទាន់ពេលវេលា បាត់បង់ការងារ និងប្រាក់ចំណូល តើភាពរីករាយរបស់ប្តីស្ថិតនៅលេខប៉ុន្មាន? | ២. ប្រសិនបើប្តីធ្វើការងារផ្ទះ អ្នកទាំងពីរអាចធ្វើការរកប្រាក់ចំណូល និងសម្រាកស្មើគ្នា តើភាពរីករាយរបស់ប្តីស្ថិតនៅលេខប៉ុន្មាន? |
| ៣. ភាពរីករាយរបស់កូន | ៣. ប្រសិនប្តី និងប្រពន្ធ ឈ្លោះទាស់ទែងគ្នា តើភាពរីករាយរបស់កូនស្ថិតនៅលេខប៉ុន្មាន? | ៣. ប្រសិនប្តី និងប្រពន្ធ មិនឈ្លោះទាស់ទែងគ្នា និងមានសាមគ្គីភាព តើភាពរីករាយរបស់កូនស្ថិតនៅលេខប៉ុន្មាន? |
| ៤. គ្រួសារមានម្ហូបអាហារគ្រប់គ្រាន់ និងមានសុវត្ថិភាព និងសុខភាពល្អ | ៤. ប្រសិនមានតែប្រពន្ធ ឬប្តីតែម្នាក់គត់ជាអ្នករកប្រាក់សម្រាប់ទិញម្ហូបអាហារសម្រាប់គ្រួសារ តើការផ្គត់ផ្គង់ម្ហូបអាហារ និងសុខភាពរបស់គ្រួសារស្ថិតនៅលេខប៉ុន្មាន? | ៤. ប្រសិនប្រពន្ធ និងប្តីជាអ្នករកប្រាក់សម្រាប់ទិញម្ហូបអាហារសម្រាប់គ្រួសារ តើការផ្គត់ផ្គង់ម្ហូបអាហារ និងសុខភាពរបស់គ្រួសារស្ថិតនៅលេខប៉ុន្មាន? |
| ៥. ជំលោះ និងអំពើហិង្សា | ៥. ប្រសិនប្រពន្ធ និងប្តីពិគ្រោះ និងចូលរួមក្នុងការសម្រេចចិត្តយក និងសងកម្ចី តើជម្លោះ និងអំពើហិង្សាក្នុងគ្រួសារស្ថិតនៅលេខប៉ុន្មាន? | ៥. ប្រសិនមានតែប្រពន្ធ ឬប្តីតែម្នាក់គត់ដែលពិគ្រោះ និងចូលរួមក្នុងការសម្រេចចិត្តយក និងសងកម្ចី តើជម្លោះ និងអំពើហិង្សាក្នុងគ្រួសារស្ថិតនៅលេខប៉ុន្មាន? |
| ៦. ទ្រព្យសម្បត្តិ និងកម្មសិទ្ធិដីធ្លីសម្រាប់កូន | ៦. ប្រសិនមានតែកូនប្រុស ដែលទទួលបានមរតកដី និងទ្រព្យសម្បត្តិគ្រួសារ តើសន្តិសុខទ្រព្យសម្បត្តិរបស់កូនស្រីស្ថិតនៅលេខប៉ុន្មាន? | ៦. ប្រសិនកូនស្រី និងកូនប្រុស មាន សិទ្ធិស្មើគ្នាក្នុងការទទួលមរតកដី និងទ្រព្យសម្បត្តិគ្រួសារ តើសន្តិសុខទ្រព្យសម្បត្តិរបស់កូនស្រីស្ថិតនៅលេខប៉ុន្មាន? |
| ៧. សុភមង្គលគ្រួសារ | ៧. ប្រសិនសមាជិកគ្រួសារមិនចែករំលែកការងារផ្ទះ និងមិនគាំទ្រគ្នាទៅវិញទៅមក, តើសុភមង្គលគ្រួសារស្ថិតនៅលេខប៉ុន្មាន? | ៧. ប្រសិនសមាជិកគ្រួសារចែករំលែកការងារផ្ទះស្មើគ្នា និងគាំទ្រគ្នាទៅវិញទៅមក, តើសុភមង្គលគ្រួសារស្ថិតនៅលេខប៉ុន្មាន? |
| ៨. ការអភិវឌ្ឍសេដ្ឋកិច្ចសហគមន៍ | ៨. ប្រសិនសេដ្ឋកិច្ចនៅក្នុងគ្រួសារចុះខ្សោយ តើការអភិវឌ្ឍសេដ្ឋកិច្ចសហគមន៍ស្ថិតនៅលេខប៉ុន្មាន? | ៨. ប្រសិនសេដ្ឋកិច្ចនៅក្នុងគ្រួសារខ្លាំង តើការអភិវឌ្ឍសេដ្ឋកិច្ចសហគមន៍ស្ថិតនៅលេខប៉ុន្មាន? |

**ជំហានទី៤៖** នៅពេលដែលអ្នកស្រមើស្រមៃរូបភាពពីការពិភាក្សាក្នុងជំហានទី៣ ប្រើប្រាស់រូបភាពពេញលេញដើម្បីដឹកនាំការពិភាក្សា បង្កើនការពិភាក្សាដោយប្រើប្រាស់សំណួរនាំដូចខាងក្រោម៖

**សំណួរនាំ៖**

១. តើរង្វង់បង្កើតឡើងដោយជុំទាំង២នៃការពិភាក្សា មានចំណុចដូច និងខុសគ្នាមែនឬទេ? ប្រសិនបើមិនដូចគ្នា តើរង្វង់ណាដែលធំជាងគេ? ហើយហេតុអ្វី?

២. ប្រៀបធៀបរង្វង់ទាំង២ដែលអ្នកបានជ្រើសរើស ត្រូវបានគេធ្វើការផ្លាស់ប្តូរទៅលើតួនាទីរបស់បុរស និងស្ត្រីក្នុងផ្នែកសេដ្ឋកិច្ច តើអ្នកនឹង៖

ក. ផ្លាស់ប្តូរខ្លួនឯង?
ខ. តើសមាជិកគ្រួសារអាចធ្វើអ្វី ដើម្បីគាំទ្រគ្នាទៅវិញទៅមកក្នុងការថែទាំផ្ទះ?
គ. ចុះអាជ្ញាធរក្នុងតំបន់វិញ បុគ្គលផ្សេងទៀតក្នុងមុខជំនួញ ធ្វើដូចម្តេចដើម្បីនាំយកភាពយុត្តិធម៌ និងសមភាពទៅលើសេដ្ឋកិច្ចបុគ្គល គ្រួសារ និងសហគមន៍ ជាពិសេសសម្រាប់ស្ត្រី បុរស និងក្រុមមនុស្សដែលងាយរងគ្រោះ រាប់បញ្ចូលទាំងគោលនយោបាយគាំទ្រ?

**ជំហានទី៥៖** សន្និដ្ឋានថា រាល់គំនិតរបស់អ្នកចូលរួម គឺមានតម្លៃហើយចាំបាច់យកមកអនុវត្តន៍ ដូច្នេះពួកយើងនឹងធ្វើសកម្មភាពទាំងអស់គ្នាដើម្បីធានាថាពួកយើងអាចទៅដល់ និងអនុវត្តន៍រង្វង់នៃភាពរីករាយ និងសុខុមាលភាពដែលយើងបានជ្រើសរើស។ បន្តទៅសកម្មភាពបន្ទាប់។

# វគ្គទី៤៖ លើកកម្ពស់សមភាព ដើម្បីគាំទ្រការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី ដើម្បីសុភមង្គល និងសុខុមាលភាពគ្រួសារ

## សកម្មភាព ៤ខ៖ ផែនការសកម្មភាព

**វត្ថុបំណង៖** យកលទ្ធផលការពិភាក្សាដែលចេញពីវគ្គនីមួយៗមកដាក់ជាការអនុវត្ត ដើម្បីលើកកម្ពស់ការផ្លាស់ប្តូរឥរិយាបថ និងសមភាពយេនឌ័រ ក្នុងការគាំទ្រការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី និងឆ្ពោះទៅសុភមង្គល និងសុខុមាលភាពនៅកម្រិតបុគ្គល គ្រួសារ និងសហគមន៍។

**ថេរវេលា៖** ៣០នាទី
**វិធីសាស្ត្រ៖** ពិភាក្សាជាក្រុមតូច និងបង្ហាញទៅក្រុមធំ
សម្ភារៈ និងការរៀបចំ៖ ក្រដាសផ្ទាំងធំចំនួន៦សន្លឹក ហ្វឺត ស្កុតក្រដាស និងគូរតារាងផែនការសកម្មភាព។

**អ្វីគួរធ្វើ និងអ្វីមិនគួរធ្វើ៖** សម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយក្រុមតូច ប៉ុន្តែមិនត្រូវបង្ហាញអ្នកចូលរួមអំពីអ្វីដែលអ្នកសម្របសម្រួលចង់បានទេ។ ស្នើឱ្យពួកគេធ្វើផែនការ និងធានាថាផែនការនោះអាចធ្វើទៅរួច និងសមស្របសម្រាប់ពួកគេ និងសហគមន៍របស់ពួកគេ។ សួរសំណួរប្រដេញ និងលើកទឹកចិត្តឱ្យអ្នកចូលរួមពិភាក្សាអ្វីដែលពួកគេមានឆន្ទៈក្នុងការអនុវត្ត ដើម្បីជួយគាំទ្រស្ត្រី និងអ្នកដទៃទៀតឱ្យទទួលបានសិទ្ធិនៅកម្រិតក្រុមគ្រួសារ សហគមន៍ និងសហការជាមួយអាជ្ញាធរមូលដ្ឋាន វិស័យឯកជន ដើម្បីមានឥទ្ធិពលលើការផ្លាស់ប្តូរគោលនយោបាយ សម្រាប់ភាពស្មើគ្នា និងបរិយាបន្នចម្រុះ។

## ការណែនាំសម្រាប់អ្នកសម្របសម្រួល៖

**ជំហានទី១៖** ពន្យល់ពីដំណើរការសកម្មភាព គោលបំណង និងការចូលរួមរបស់ពួកគេកំឡុងពេលធ្វើការជាក្រុម។ (រំលឹកពីកិច្ចព្រមព្រៀងសាមញ្ញៗដែលទើបបានបង្កើតក្នុងក្រុម)។

**ជំហានទី២៖** បែងចែកជាក្រុមស្ត្រី និងក្រុមបុរស ឱ្យពិភាក្សាផ្សេងគ្នា និងរក្សាឯកជនភាព។ ធ្វើរបៀបនេះអាចឱ្យពួកគេមានអារម្មណ៍ងាយស្រួល និងអាចពិភាក្សាដោយបើកចំហរនៅក្នុងក្រុមតូច ដូច្នេះពួកគេមានអារម្មណ៍សុវត្ថិភាព និងអាចបង្កើតផែនការបានដោយសេរី ដែលពួកគេមានបំណងចង់ធ្វើដោយគ្មានសំពាធ និងមិនទទួលឥទ្ធិពលពីអ្នកផ្សេង។ ចែកសម្ភារៈទៅក្រុមនីមួយៗ ស្នើឱ្យអ្នកចូលរួមដឹកនាំ ម្នាក់ដឹកនាំការពិភាក្សា ហើយម្នាក់ទៀតកត់ត្រាដោយបំពេញតារាងផែនការសកម្មភាពដែលបានផ្តល់ឱ្យ។[29] ក្នុងករណីអ្នកចូលរួមមិនអាចសរសេរបាន ឬមានអារម្មណ៍មិនងាយស្រួល អ្នកសម្របសម្រួលអាចដឹកនាំការពិភាក្សា និងកត់ត្រាជំនួសបាន។

សួរអ្នកចូលរួម ថាតើពួកគេមានសំណួរអ្វីទៀត ឬមានព័ត៌មានចង់បន្ថែមទៅលើផែនការដែរឬទេ។ សូមប្រើពេល ២ទៅ៣នាទីដើម្បីឆ្លើយ និងបន្តទៅសកម្មភាពបន្ទាប់។

[29] Action plan template is attached as an annex 4b-1.

## សកម្មភាព ៥ខ៖ តើមានច្បាប់ និងគោលនយោបាយអ្វីខ្លះ ដែលនិយាយអំពីការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីនៅប្រទេសកម្ពុជា?

**វត្ថុបំណង៖** ស្វែងយល់អំពីច្បាប់ និងគោលនយោបាយ ស្តីពីការលើកកម្ពស់ការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីនៅប្រទេសកម្ពុជា។
**ថេរវេលា៖** ២០ នាទី
វិធីសាស្ត្រ៖ សង្ខេប ចែករំលែកព័ត៌មាន និងពិភាក្សា សំណួរ និងចម្លើយ (១០នាទី)
**សម្ភារៈ និងការរៀបចំ៖** បទបង្ហាញទាក់ទងនឹងព័ត៌មានដែលពាក់ព័ន្ធនឹងការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីនៅប្រទេសកម្ពុជា

**អ្វីគួរធ្វើ និងអ្វីមិនគួរធ្វើ៖** អ្នកសម្របសម្រួលមិនត្រូវបង្ខំអ្នកចូលរួមឱ្យឆ្លើយ ប្រសិនពួកគេមិនចង់ឆ្លើយនោះទេ។ សូមសង្កេតមើល ប្រសិនបើអ្នកចូលរួមមានអារម្មណ៍មិនងាយស្រួលក្នុងការពិភាក្សាអំពីច្បាប់ឬគោលនយោបាយ ដែលអ្នកខ្លះប្រហែលជានិយាយ ហើយអ្នកខ្លះទៀតប្រហែលជាមិននិយាយអំពីគោលនយោបាយ ឬច្បាប់នោះទេ។ លើកកម្ពស់ឥរិយាបថ និងឥទ្ធិពលជាវិជ្ជមានទៅអ្នកចូលរួម ដើម្បីឱ្យពួកគេយល់ថាច្បាប់ និងគោលនយោបាយនោះមានរូបរាងយ៉ាងដូចម្តេច ក្នុងការគាំទ្រសមភាពយេនឌ័រ ការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី និងស្ថានភាពសេដ្ឋកិច្ចស្មើគ្នាសម្រាប់អ្នកទាំងអស់គ្នា និងគ្រប់យេនឌ័រទាំងអស់។

## ការណែនាំសម្រាប់អ្នកសម្របសម្រួល៖

**អ្វីគួរធ្វើ និងអ្វីមិនគួរធ្វើ៖** អ្នកសម្របសម្រួលមិនត្រូវបង្ខំអ្នកចូលរួមឱ្យឆ្លើយ ប្រសិនពួកគេមិនចង់ឆ្លើយនោះទេ។ សូមសង្កេតមើល ប្រសិនបើអ្នកចូលរួមមានអារម្មណ៍មិនងាយស្រួលក្នុងការពិភាក្សាអំពីច្បាប់ឬគោលនយោបាយ ដែលអ្នកខ្លះប្រហែលជានិយាយ ហើយអ្នកខ្លះទៀតប្រហែលជាមិននិយាយអំពីគោលនយោបាយ ឬច្បាប់នោះទេ។ លើកកម្ពស់ឥរិយាបថ និងឥទ្ធិពលជាវិជ្ជមានទៅអ្នកចូលរួម ដើម្បីឱ្យពួកគេយល់ថាច្បាប់ និងគោលនយោបាយនោះមានរូបរាងយ៉ាងដូចម្តេច ក្នុងការគាំទ្រសមភាពយេនឌ័រ ការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី និងស្ថានភាពសេដ្ឋកិច្ចស្មើគ្នាសម្រាប់អ្នកទាំងអស់គ្នា និងគ្រប់យេនឌ័រទាំងអស់។

### ក្របខណ្ឌច្បាប់អន្តរជាតិ និងក្របខណ្ឌច្បាប់ជាតិ ទាក់ទងនឹងសមភាពយេនឌ័រ និងកំណើនសេដ្ឋកិច្ច (ឆ្នាំ២០១៦ ដល់ឆ្នាំ២០២៣)៖

- SDG5/CSDG5៖ សម្រេចឱ្យបាននូវសមភាពយេនឌ័រ និងពង្រឹងសិទ្ធិ អំណាចរបស់ស្ត្រី និងក្មេងស្រី
- SDG8/CSDG8៖ លើកកម្ពស់និរន្តរភាព បរិយាបន្ន និងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព មានការងារធ្វើពេញលេញ ប្រកបដោយផលិតភាព និងកំណើនការងារសម្រាប់គ្រប់គ្នា។

### រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ២០០៨)៖

**មាត្រា ៣៥៖** ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ។
**មាត្រា ៤៥៖** ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទត្រូវបំបាត់ចោល។ការធ្វើអាជីវកម្ម លើការងាររបស់ស្ត្រីត្រូវហាមឃាត់។ បុរស និងស្ត្រី មានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ។

**មាត្រា ៤៦៖** អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារី ត្រូវបានហាមឃាត់។ មិនត្រូវមានការបញ្ឈប់ការងារចំពោះនារី ដោយមូលហេតុមានគភ៌។ នារីមានសិទ្ធិឈប់សម្រាលកូនដោយទទួលប្រាក់បៀវត្ស និងមានការធានារក្សាសិទ្ធិអតីតភាពក្នុងការងារ និងអត្ថប្រយោជន៍សង្គមផ្សេងៗទៀត។ រដ្ឋ និងសង្គមយកចិត្តទុកដាក់បង្កលក្ខណៈឱ្យនារី ជាពិសេសនារីនៅជនបទ ដែលគ្មានទីពឹង បានទទួលការឧបត្ថម្ភដើម្បីមានមុខរបរ មានលទ្ធភាពព្យាបាលជំងឺ ឱ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ។

**មាត្រា ៦១៖** រដ្ឋជំរុញការអភិវឌ្ឍសេដ្ឋកិច្ចគ្រប់វិស័យ ជាពិសេសវិស័យកសិកម្ម សិប្បកម្ម ឧស្សាហកម្ម ចាប់ពីតំបន់ដាច់ស្រយាលដោយយកចិត្តទុកដាក់ទៅលើនយោបាយទឹក ភ្លើង ផ្លូវ និងមធ្យោបាយដឹកជញ្ជូន បច្ចេកទេសទំនើប និងប្រព័ន្ធឥណទាន។

**ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ នៅកម្ពុជា៖**

**មាត្រា ២៦៖** ចំពោះបទល្មើសដែលជាអំពើហិង្សាប៉ះពាល់ខាងផ្លូវចិត្តឬផ្លូវជីវភាពសេដ្ឋកិច្ច និងបទល្មើសមជ្ឈិមស្រាលឬបទលហុ ការផ្សះផ្សាឬសម្រុះសម្រួលអាចធ្វើទៅបានតាមការល្មើសមជ្ឈិមស្រាលឬបទលហុ ការផ្សះផ្សាឬសម្រុះសម្រួលអាចធ្វើទៅបានតាមការយល់ព្រមពីភាគីទាំងសងខាង។ សមាជិកគ្រួសារអាចជ្រើសរើសវិធីណាមួយដោយស្នើសុំឪពុកម្តាយ សាច់ញាតិ ព្រះសង្ឃ ចាស់ព្រឹទ្ធាចារ្យ មេភូមិ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ធ្វើជាអ្នកអាជ្ញាកណ្តាលដោះស្រាយបញ្ហា ដើម្បីថែរក្សាបាននូវភាពសុខដុមរមនាក្នុងគ្រួសារតាមទំនៀមទម្លាប់ប្រពៃណីល្អរបស់ជាតិ ស្របតាមមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

**រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ (ខែសីហា ឆ្នាំ២០២៣)៖**

- **យុទ្ធសាស្ត្របញ្ចកោណ៖**

បញ្ចកោណទី១៖ ការអភិវឌ្ឍមូលធនមនុស្ស មុំទី៥៖ ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអារ្យធម៌ខ្ពស់ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន ទី៧៖ ការបន្តលើកកម្ពស់ការគោរព សីលធម៌តម្លៃស្ត្រី សេចក្តីថ្លៃថ្នូរក្នុងគ្រួសារ និងពលរដ្ឋសកល។

- យុទ្ធសាស្ត្របញ្ចកោណ៖ បញ្ចកោណទី៤៖ ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន មុំទី១៖ ការធ្វើបរមភាវូបនីយកម្មផលលាភប្រជាសាស្ត្រ និងការលើកកម្ពស់សមភាពយេនឌ័រ (ទី៤៖ ការបង្កើនការវិនិយោគលើយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី និងក្មេងស្រី នៅក្នុងវិស័យសេដ្ឋកិច្ច អប់រំ សុខភាព និងការដឹកនាំសាធារណៈ ដើម្បីទាញយកអត្ថប្រយោជន៍ពីភាគលាភយេនឌ័រ បង្កលក្ខណៈអំណោយផលដល់ស្ត្រី ក្នុងការទទួលបានសិទ្ធិលើការសម្រេចចិត្តអំពីគ្រួសារ និងចំនួនកូន កាត់បន្ថយភាពងាយរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រទៅលើស្ត្រី និងក្មេងស្រី និងលើកកម្ពស់ទំនាក់ទំនងអន្តរជំនាន់)។

**នារីរតនៈទី៥៖ ផែនការយុទ្ធសាស្ត្រដើម្បីជំរុញការបញ្ជ្រាបយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី៖**

**យុទ្ធសាស្ត្រទី១៖ ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី**
**គោលបំណង៖** ជំរុញការឆ្លើយតបយេនឌ័រទៅក្នុងក្របខណ្ឌគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីជាតិពាក់ព័ន្ធនឹងការអភិវឌ្ឍសហគ្រិនភាព និងសក្តានុពលរបស់ស្ត្រី នៅក្នុងវិស័យសេដ្ឋកិច្ចឱ្យឆ្លើយតបនឹងបរិបទសង្គមជាពិសេសក្នុងការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងការឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤ ប្រកបដោយបរិយាបន្ន។

**យុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ (ឆ្នាំ២០១៩ ដល់ឆ្នាំ២០២៥)៖**

«បង្កើនលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុផ្លូវការដែលមានគុណភាព កាត់បន្ថយអត្រាស្ត្រីដែលមិនទាន់ទទួលបានសេវាហិរញ្ញវត្ថុឱ្យបានពាក់កណ្តាលពី២៧% មកនៅ១៣% និងពង្រីកការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការពី៥៩% ទៅ ៧០% ត្រឹមឆ្នាំ២០២៥ ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពគ្រួសារ និងគាំទ្រកំណើនសេដ្ឋកិច្ច»។

ការលើកកម្ពស់យុទ្ធសាស្ត្រយេនឌ័រ តាមរយៈការរៀបចំគោលនយោបាយដែលអាចធានានូវបរិស្ថានគាំទ្រយេនឌ័រ នឹងជួយឱ្យសម្រេចបានសមភាពយេនឌ័រ និងការផ្តល់សិទ្ធិដល់ស្ត្រី និងកុមារី (គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ចំណុចទី៥) ទាក់ទងនឹងបរិយាបន្នហិរញ្ញវត្ថុ។ ការរៀបចំយុទ្ធសាស្ត្រច្បាស់លាស់ ដោយសហការជាមួយដៃគូដើម្បីបង្កើតសេវាសន្សំសម្រាប់ស្ត្រី និងកសាងសមត្ថភាពផ្នែកហិរញ្ញវត្ថុ និងជំនាញគ្រប់គ្រងដល់សហគ្រិនជាស្ត្រីដែលមានសក្តានុពល នឹងជួយកាត់បន្ថយគម្លាតយេនឌ័រទាក់ទងនឹងបរិយាបន្នហិរញ្ញវត្ថុ។

**ជំហានទី៣៖** រំលឹកអ្នកចូលរួមថា ច្បាប់ និងគោលនយោបាយទាំងអស់នេះ ជះឥទ្ធិពលទៅលើការរស់នៅ និងមុខជំនួញរបស់អ្នក។ តើអ្នកអាចចែករំលែកអំពី៖

- តើអ្នកបានធ្វើអ្វីខ្លះ ក្នុងការអនុវត្តច្បាប់ និងគោលនយោបាយទាំងអស់នេះ?
- តើគោលនយោបាយហិរញ្ញវត្ថុអ្វីខ្លះ ដែលអ្នកបានប្រើប្រាស់ ហើយប្រើប្រាស់យ៉ាងដូចម្តេច?
- តើអ្នកគួរធ្វើដូចម្តេច ដើម្បីធ្វើឱ្យមានការអនុវត្តគោលនយោបាយហិរញ្ញវត្ថុ ដោយផ្តោតលើសមភាពយេនឌ័រ ដើម្បីជាផលប្រយោជន៍ចំពោះអ្នក គ្រួសាររបស់អ្នក និងមនុស្សក្នុងសហគមន៍?

**ជំហានទី៤៖ <u>សេចក្តីសន្និដ្ឋាន</u>** ទាំងអស់នេះគឺជាក្របខណ្ឌច្បាប់ និងគោលនយោបាយលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ស្ត្រី និងបរិយាបន្នហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា និងបទពិសោធន៍របស់អ្នកក្នុងការអនុវត្ត។ គ្រប់ការងារទាំងអស់ដែលអ្នកធ្វើដើម្បីលើកកម្ពស់សមភាពយេនឌ័រ យុទ្ធសាស្ត្រពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី និងបរិយាបន្នហិរញ្ញវត្ថុ គឺបានចូលរួមចំណែកក្នុងការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងគាំទ្រខ្លួនអ្នក គ្រួសាររបស់អ្នក និងសហគមន៍របស់អ្នក។

**សេចក្តីបញ្ចប់៖** ជូនដំណឹងទៅកាន់អ្នកចូលរួមអំពីសកម្មភាពនៃទីបញ្ចប់ ការសង្ខេបលទ្ធផលនៃសកម្មភាព ថ្លែងសេចក្តីអំណរគុណសម្រាប់ការចូលរួមយ៉ាងសកម្មរបស់អ្នកចូលរួម និងបិទបញ្ចប់កម្មវិធី។

## និយមន័យ[30]

**គុណតម្លៃសមភាពយេនឌ័រ៖** សមភាពយេនឌ័រមានគុណតម្លៃ ដែលមានន័យថាជាតម្លៃ ភាពទូលំទូលាយ និងគុណភាពនៃផលប្រយោជន៍ដែលត្រូវទទួលដោយស្ត្រី (រាប់បញ្ចូលក្រុមដែលគ្មានបុព្វសិទ្ធិ) ដែលយ៉ាងហោចណាស់ស្មើទៅនឹងអ្វីដែលបុរសទទួលបាន។ អត្ថប្រយោជន៍ គឺមិនមែនគ្រាន់ជាការផ្តល់សាច់ប្រាក់ទៅកាន់បុគ្គលិក ដែលជាកញ្ចប់ទូទាត់ប្រាក់នោះទេ។

**ភាពតំណាងនៃយេនឌ័រ** ៖ ភាពតំណាងនៃយេនឌ័រ គឺជាទស្សនៈទូទៅឬការគិតទុកជាមុនអំពីអាកប្បកិរិយាឥរិយាបថ និងតួនាទីដែលផ្សាភ្ជាប់ជាមួយស្ត្រី ឬបុរស ដូចជា «បុរសគឺជាអ្នកដឹកនាំ» ហើយ «ស្ត្រីគឺជាអ្នកថែទាំ»។ ភាពតំណាងនៃយេនឌ័រប្រហែលជាខុសគ្នាទៅតាមវប្បធម៌ ប៉ុន្តែអត្ថន័យនៃលក្ខណៈរបស់វាគឺមើលទៅលើ សេដ្ឋកិច្ចសង្គម និងតួនាទីនយោបាយសម្រាប់ស្ត្រីដែលខុសពីបុរស។

**សមភាពយេនឌ័រ៖** សំដៅលើគោលការណ៍ មិនមានការរើសអើងទៅលើមូលដ្ឋានយេនឌ័រ និងគោលដៅ។ ដូច្នេះបុរស ស្ត្រី កូនប្រុស និងកូនស្រី (និងអ្នកចម្រុះយេនឌ័រ) មានឱកាស តម្លៃ ធនធាន និងការយកចិត្តទុកដាក់ដូចគ្នាក្នុងគ្រួសារ សហគមន៍ ស្ថាប័ន និងសង្គម។

**សមធម៌យេនឌ័រ៖** សំដៅលើគោលការណ៍ យុទ្ធសាស្ត្រ មធ្យោបាយ ឬវិធីសាស្ត្រវិជ្ជមានដែលបង្កើត ឬផ្តល់ឱកាសសម្រាប់បុគ្គល ឬក្រុមនៃយេនឌ័រផ្សេងៗ (បុរស និងស្ត្រី និងអ្នកដែលមានភេទមិនកំណត់) ដើម្បីកាត់បន្ថយគម្លាត និងសម្រេចឱ្យបានសមភាពយេនឌ័រពិតប្រាកដ។

**វិសមភាពយេនឌ័រ៖** សំដៅលើការរើសអើងទៅលើឥរិយាបថ និងអាកប្បកិរិយាចំពោះយេនឌ័រផ្សេងៗ និងបញ្ហា ឬគម្លាតរវាងបុរស ស្ត្រី កូនប្រុស និងកូនស្រី (និងអ្នកចម្រុះយេនឌ័រ) ដែលកើតឡើងក្នុងសង្គម សហគមន៍ ស្ថាប័ន និងគ្រួសារ ជាដើម។

---

[30] Based on definition indicated in the documents of the Royal Government of Cambodia - Neary Rattanak: Five Year Strategy (2019-2023) and UN Women - Guidance note: Women’s Economic Empowerment Index (2021)

**ការបញ្ជ្រាបយេនឌ័រ៖** យុទ្ធសាស្ត្រ និងយន្តការសម្រាប់ឆ្លើយតបនឹងវិសមភាពយេនឌ័រក្នុងគោលនយោបាយ តំបន់ភូមិសាស្ត្រ កម្មវិធី ឯកសារ បទដ្ឋានច្បាប់ ស្ថាប័ន និងគ្រួសារ ជាដើម។

**ការពង្រឹងសិទ្ធិអំណាចរបស់ស្ត្រី៖** សំដៅទៅលើយន្តការបង្កើនសមត្ថភាព អភិវឌ្ឍន៍សក្តានុពល និងការពារផលប្រយោជន៍របស់ស្ត្រី (រាប់បញ្ចូលស្ត្រីមានពិការភាព ស្ត្រីជនជាតិដើម)។

ការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី៖ ស្ត្រីត្រូវបានពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ច នៅពេលពួកគេមានទាំងសមត្ថភាពដើម្បីធ្វើឱ្យជោគជ័យ និងបង្កើនសេដ្ឋកិច្ចតាមរយៈ ការចូលរួមក្នុងសកម្មភាពរកប្រាក់ចំណូល និងអំណាចក្នុងការធ្វើការសម្រេចចិត្តលើសេដ្ឋកិច្ច។

**បរិយាបន្ន៖** សំដៅលើការរាប់បញ្ចូលនូវការយកចិត្តទុកដាក់ និងការឆ្លើយតបទៅក្រុមគោលដៅក្នុងសង្គម ស្ថាប័ន និងគ្រួសារ សំដៅលើការ «មិនទុកនរណាម្នាក់ចោល» ក្នុងចំណោមអ្នកងាយរងគ្រោះ និងអ្នកបាត់បង់ឱកាសក្នុងសង្គម ដូចជាជនមានពិការភាព ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ជនជាតិដើមភាគតិច ក្មេង ស្ត្រី មនុស្សចាស់ជាដើម។

**ការវិភាគយេនឌ័រ៖** សំដៅលើការវិភាគអំពីឫសគល់ និងឥទ្ធិពលនៃវិសមភាពយេនឌ័រក្នុងសង្គមទៅតាមផ្នែក និងស្ថាប័ន។

**អំពើហិង្សាទាក់ទងនឹងយេនឌ័រ៖** សំដៅលើការរំលោភបំពានផ្លូវភេទដោយផ្អែកលើភេទ ដែលត្រូវបានគេចាត់ទុកថាជាភេទទន់ខ្សោយ ដែលងាយរងនឹងការឈឺចាប់លើផ្នែករូបរាងកាយ ផ្លូវភេទ ផ្លូវចិត្តឬសេដ្ឋកិច្ច ដោយផ្អែកលើយេនឌ័ររបស់បុគ្គលម្នាក់ៗ។

**តុល្យភាពជីវិត និងការងារនៅកន្លែងធ្វើការ៖** សំដៅលើវិធីសាស្ត្ររបស់ស្ថាប័ន និងរដ្ឋក្នុងការគាំទ្របុគ្គលិក និងគ្រួសារជាមួយគោលដៅរក្សាតុល្យភាពគុណភាពជីវិត និងការងារ រាប់បញ្ចូលការពិចារណា និងការឆ្លើយតប ការលំហែមាតុភាព និងបិតុភាព ការសម្រាកសម្រាប់គ្រួសារ ការរៀបផែនការមើលថែកូនជាមួយការបត់បែនម៉ោងការងារ។

**សវនកម្មយេនឌ័រ៖** ឧបករណ៍ និងវិធីសាស្ត្រ និងការទទួលព័ត៌មានអំពីដំណើរការ ឧបសគ្គ គម្លាត ឱកាស និងការស្នើរសុំសម្រាប់លើកកម្ពស់សមភាពយេនឌ័រក្នុងស្ថាប័ន ឬផ្នែក ដោយប្រៀបធៀបការប្តេជ្ញាចិត្ត ឬគោលនយោបាយរបស់ស្ថាប័ន ឬផ្នែកជាមួយស្ថានភាពជាក់ស្តែង។

**យេនឌ័រដែលមានលក្ខណៈឆ្លើយតប៖** សំដៅលើការពិចារណាលើបញ្ហាវិសមភាព នៅគ្រប់ដំណាក់កាល និងផ្នែកនៃដំណើរការ ឬការងារ ឬស្ថាប័ន។ ឧទាហរណ៍៖ គោលនយោបាយយេនឌ័រដែលមានលក្ខណៈឆ្លើយតប សំដៅលើគោលនយោបាយដែលដោះស្រាយវិសមភាពយេនឌ័រក្នុងដំណាក់កាលបង្កើត តាមរយៈការវិភាគយេនឌ័រ និងវិធីសាស្ត្រជាក់លាក់ ដើម្បីដោះស្រាយវិសមភាពយេនឌ័រនៅក្នុងគោលនយោបាយនោះ។

# ឧបសម្ព័ន្ធ ៤ខ - ១៖ ទម្រង់ផែនការសកម្មភាព៖

| កម្រិត និងផ្នែកនៃការផ្លាស់ប្តូរ | តើសកម្មភាពឬអ្វីដែលអ្នកនឹងធ្វើក្នុងផ្នែកនីមួយៗ ដើម្បីលើកកម្ពស់ការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី? | តើអ្នកនឹងធ្វើដោយរបៀបណា? | តើអ្នកនឹងធ្វើនៅពេលណា? | តើអ្នកត្រូវការការគាំទ្រអ្វី និងពីនរណា? |
|---|---|---|---|---|
| បុគ្គល | 1. | | | |
| | 2. | | | |
| | 3. | | | |
| គ្រួសារ | 1. | | | |
| | 2. | | | |
| | 3. | | | |
| សហគមន៍ | 1. | | | |
| | 2. | | | |
| | 3. | | | |

# ម៉ូឌុល គ៖

## អំពើហិង្សាទាក់ទងនឹងយេនឌ័រ



### ផ្នែកទី ៣៖ ឧបករណ៍សម្រាប់អនុវត្តន៍ (គ)

### ម៉ូឌុល គ៖ អំពើហិង្សាទាក់ទងនឹងយេនឌ័រ

**ថេរវេលា៖** មួយថ្ងៃ កន្លះ
**វត្ថុបំណង៖** វត្ថុបំណងនៃកញ្ចប់ទំនាក់ទំនងផ្លាស់ប្តូរឥរិយាបថទៅលើអំពើហិង្សាទាក់ទងនឹងយេនឌ័រ គឺដើម្បីដោះស្រាយបញ្ហាដែលស្ត្រីជួបប្រទះ និងបង្កើនចំណេះដឹងដល់សមាជិកសហគមន៍ ដើម្បីស្វែងយល់ និងស្វែងរកការគាំទ្រនៅក្នុងសហគមន៍របស់ពួកគេ អង្គការអភិវឌ្ឍន៍ អង្គការក្នុងស្រុក និងដៃគូអភិវឌ្ឍនៅពេលពួកគេជួបប្រទះបញ្ហាអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

**សេចក្តីផ្តើម**
**ថេរវេលា៖** ១០ ទៅ ១៥នាទី
**វត្ថុបំណង៖** ដើម្បីស្វាគមន៍អ្នកចូលរួម និងឱ្យពួកគេស្គាល់គ្នា បង្ហាញពីដំណើរការ ឬរបៀបវារៈរបស់វគ្គ ចែករំលែកលទ្ធផលការស្ទាបស្ទង់មតិ ឬការរំពឹងទុក។ ប្រាប់ និងបង្កើតបរិយាកាសការងារវិជ្ជមាន មុនពេលចាប់ផ្តើមសកម្មភាពវគ្គ។

## ការណែនាំសម្រាប់អ្នកសម្របសម្រួល៖

**ជំហានទី១៖** ស្វាគមន៍អ្នកចូលរួម ឬសមាជិកសហគមន៍។ ណែនាំក្រុមអ្នកសម្របសម្រួល ដៃគូក្នុងតំបន់ អាជ្ញាធរភូមិទាំងអស់ដែលមានវត្តមាននៅក្នុងកម្មវិធី។

**ជំហានទី២៖** បង្ហាញពីគោលបំណងនៃវគ្គ បង្ហាញដំណើរការ ឬរបៀបវារៈ និងសុំការអនុញ្ញាតថតរូប និងប្រើប្រាស់រូបថតពីអ្នកចូលរួម។

**ជំហានទី៣៖** បង្កើតការសិក្សា និងបរិយាកាសចូលរួមបែបវិជ្ជមានជាមួយអ្នកចូលរួម។ អនុវត្តតាមការព្រមព្រៀងដូចតទៅ៖

១. រក្សាការសម្ងាត់
២. ការចែករំលែកគឺជាជម្រើស ឬការសម្រេចចិត្តរបស់អ្នកចូលរួម។ អ្នកចូលរួមអាចចាកចេញ និងផ្លាស់ប្តូរទៅទីតាំងផ្សេងប្រសិនបើត្រូវការ។
៣. ដឹងពីតួនាទីរបស់ខ្លួន និងទីតាំងដែលមានជាសុវត្ថិភាពសម្រាប់ខ្លួនឯង៖
    ក. យើងនឹងមិនកំណត់ឱ្យអ្នកចូលរួមចែករំលែករឿងរ៉ាវរបស់ខ្លួននោះទេ
    ខ. សម្រាប់អ្នកដែលមានតួនាទីខ្ពស់ និងឯកសិទ្ធិ គឺអាចបង្កើតឱ្យមានបរិយាកាសមិនងាយស្រួល
៤. បង្ហាញពីបទពិសោធន៍ផ្ទាល់ខ្លួន ដោយប្រើប្រយោគចាប់ផ្តើមដោយ «ខ្ញុំ»
៥. អនុវត្តន៍ការស្គាល់ពីខ្លួនឯង និងការថែទាំខ្លួនឯង

៦. គ្មានអ្នកណាអាចនិយាយត្រូវគ្រប់ពេលនោះទេ
៧. សម្រេចចិត្តលើសកម្មភាពពិតប្រាកដ
៨. មនុស្សម្នាក់ៗមានជម្រើសផ្សេងៗពីគ្នា ដោយមិនមានជាបញ្ហាអ្វីទេ។ ធ្វើការចែករំលែកដោយការគោរពគ្នាទៅវិញទៅមក។

បង្ហាញ ការព្រមព្រៀងខាងលើនេះនៅក្នុងក្រុម និងពន្យល់អត្ថន័យម្តងមួយៗ។ សាកសួរអ្នកចូលរួមប្រសិនមាននរណាម្នាក់ចង់ចែករំលែក ឬបន្ថែម។

**ជំហានទី៤៖** ចែករំលែកលទ្ធផលការស្ទាបស្ទង់មតិ ឬការរំពឹងទុក និងសួរអ្នកចូលរួមប្រសិនគាត់ចង់បន្ថែមការរំពឹងទុកក្នុងករណីគាត់មិនបានធ្វើការស្ទាបស្ទង់មតិ។

**ជំហានទី៥៖** សង្ខេបការវិភាគបរិបទនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងប្រទេសកម្ពុជា ស្នើសុំក្រុមការងារម្នាក់ដែលមានជំនាញបច្ចេកទេសដើម្បីចែករំលែកលទ្ធផល។

## កំណត់ចំណាំសម្រាប់អ្នកសម្របសម្រួល៖

អ្នកសម្របសម្រួលត្រូវតែធានាទីកន្លែងសុវត្ថិភាពសម្រាប់អ្នកចូលរួម ហើយដឹងច្បាស់អំពីគោលនយោបាយការពារសុវត្ថិភាពនៅក្នុងស្ថាប័នពួកគេ។ អ្នកសម្របសម្រួលត្រូវប្រាកដថា ពួកគេបានរៀបចំធ្វើការប៉ាន់ស្មានពីហានិភ័យជាមុន ដើម្បីឱ្យអ្នកចូលរួមមានសុវត្ថិភាពពីការបៀតបៀនផ្លូវភេទ ឬករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រកំឡុងពេលបណ្តុះបណ្តាល។ គួរតែមានកំណត់ត្រាសម្រាប់អ្នកចូលរួមនៅពេលមានការរាយការណ៍ ដោយប្រើប្រាស់យន្តការរាយការណ៍ ឬយន្តការផ្តល់មតិត្រឡប់ នៅពេលដែលមានករណី ឬឧប្បត្តិហេតុកើតឡើង ដើម្បីឱ្យស្ថាប័នអាចធ្វើការឆ្លុះបញ្ចាំង និងពង្រឹងការរៀបចំវគ្គបណ្តុះបណ្តាលរបស់ពួកគេ។

# វគ្គទី១៖ ទស្សនៈសំខាន់ៗអំពីយេនឌ័រ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ

វត្ថុបំណង៖ ដឹងពីទស្សនៈសំខាន់អំពីយេនឌ័រ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ

## សកម្មភាព ១គ៖ ប្រអប់យេនឌ័រ “Deep Dive” Gender Box

**វត្ថុបំណង៖** កត់សម្គាល់ និងធ្វើការវិភាគពីតួនាទីទូទៅ ឥរិយាបថ និងបទដ្ឋានដែលដាក់ទៅលើបុរសឬរំពឹងពីបុរស ស្ត្រី និងក្រុមអ្នកស្រឡាញ់ភេទដូចគ្នាក្នុងសហគមន៍ ថាតើវាត្រូវបានប្រកាន់ខ្ជាប់ដូចម្តេច ហើយតើវាត្រូវបានផ្លាស់ប្តូរដូចម្តេច?
**ថេរវេលា៖** ៦០ នាទី
**វិធីសាស្ត្រ៖** ធ្វើការជាក្រុម ការពិភាក្សាដែលមានទំនាក់ទំនងគ្នា ស្វែងរក និងចែករំលែកអំពីបទដ្ឋានសង្គម។
សម្ភារៈ និងការរៀបចំ៖ ក្រដាសផ្ទាំងធំ ហ្វឺត ឬប៊ិចដែលមានពណ៌ផ្សេងគ្នា កាត ស្កុតក្រដាស។ រំលឹកឡើងវិញអំពីជំហានសម្រាប់អ្នកសម្របសម្រួល និងសម្រេចចិត្តថាវិធីសាស្ត្រណាដែលត្រូវបានប្រើប្រាស់សម្រាប់សម្របសម្រួល ហើយបញ្ជាក់ពីតួនាទី ប្រសិនបើមានអ្នកសម្របសម្រួលច្រើនជាងម្នាក់ ហើយសម្រេចថាតើវិធីសាស្ត្រណាដែលត្រូវប្រើសម្រាប់សម្របសម្រួល (ឧទាហរណ៍៖ ក្រុមនីមួយៗគូររូបយេនឌ័ររបស់ខ្លួន រូបផ្ទុយពីយេនឌ័ររបស់ខ្លួន)។

**អ្វីគួរធ្វើ និងអ្វីមិនគួរធ្វើ៖** ប្រសិនចំណុចមួយចំនួន ឬការពិភាក្សាដែលផុសឡើងមានលក្ខណៈរសើបទៅក្នុងបរិបទនោះ អ្នកសម្របសម្រួលត្រូវតែយកចិត្តទុកដាក់ ហើយធានាថាមានការគោរពចំពោះបរិបទវប្បធម៌ ជាមួយនឹងបទដ្ឋានសង្គមទៅលើយេនឌ័រ និងផ្តួចផ្តើមដឹកនាំឱ្យមានការពិភាក្សា។

## ការណែនាំសម្រាប់អ្នកសម្របសម្រួល៖

**ជំហានទី១៖** ផ្តល់ការណែនាំសង្ខេបអំពីសកម្មភាពដូចជា៖ «ថ្ងៃនេះពួកយើងនឹងពិភាក្សាពីការរំពឹងទុកដែលយើងមាន ដែលមិត្តភក្តិយើងមាន ដែលគ្រួសារយើងមាន និងអ្វីដែលសហគមន៍យើងមានសម្រាប់ស្ត្រី បុរស និងក្រុមអ្នកស្រឡាញ់ភេទដូចគ្នា។ ពួកយើងនឹងហៅការរំពឹងទុកទាំងអស់នេះថាជា "យេនឌ័រ" របស់យើង។»

**ជំហានទី២៖** បែងចែកអ្នកចូលរួមជាក្រុមស្ត្រី ក្រុមបុរស និងក្រុមអ្នកស្រឡាញ់ភេទដូចគ្នា។ ប្រសិនពួកគេជាក្រុមដែលមានភេទតែមួយ ស្នើសុំឱ្យចំនួនពាក់កណ្តាលនៃក្រុមធ្វើការពិភាក្សាអំពីក្រុមដែលមានភេទផ្សេង (ឧទាហរណ៍៖ ស្ត្រីបង្ហាញទស្សនៈពីបុរស ប្រសិនបើមិនមានបុរសនៅក្នុងក្រុមទេ)។

**ជំហានទី៣៖** ឱ្យក្រុមនីមួយៗគូរប្រអប់រាងការេ ទំហំសមល្មម ហើយប្រាប់ពួកគេថានេះជា «ប្រអប់យេនឌ័រ»។ នៅក្នុងប្រអប់ ឱ្យក្រុមស្ត្រីគូររូបស្ត្រី «ដែលជាទូទៅត្រូវបានសង្គមសម្គាល់ជាស្ត្រី» ហើយក្រុមបុរសគូររូបបុរស «ដែលជាទូទៅត្រូវបានសង្គមសម្គាល់ជាបុរស» ហើយក្រុមអ្នកស្រឡាញ់ភេទដូចគ្នាគូររូបអ្នកស្រឡាញ់ភេទដូចគ្នា «ដែលជាទូទៅត្រូវបានសង្គមសម្គាល់ជាអ្នកស្រលាញ់ភេទដូចគ្នា»។ សកម្មភាពនេះគួរតែធ្វើការបែងចែកមុនពេលចាប់ផ្តើមធ្វើសកម្មភាពវគ្គ។

**ជំហានទី៤៖** ឱ្យក្រុមនីមួយៗពិភាក្សាអំពីបទពិសោធន៍របស់ពួកគេអំពីតួនាទី ឥរិយាបថ និងបទដ្ឋានសង្គម ដែលសង្គមរំពឹងទុកទៅលើ ស្ត្រី បុរស និងអ្នកស្រឡាញ់ភេទដូចគ្នា រួចគូរសញ្ញា ឬសរសេរចំណុចគន្លឹះនៅក្នុងប្រអប់។

**ក. ឧទាហរណ៍សម្រាប់ស្ត្រី៖** ចេះចម្អិនអាហារអោយបានល្អ មើលថែបងប្អូន និងក្មេងតូចៗ ត្រូវបញ្ចប់ការសិក្សាថ្នាក់មូលដ្ឋាន រៀបការមុនអាយុកំណត់ មានកូនប្រុសយ៉ាងតិចមួយនាក់ មើលទៅស្រស់ស្អាត រក្សាព្រហ្មចារីយ៍រហូតដល់ពេលរៀបការ មិនឈ្លោះប្រកែកជាមួយប្តីនៅទីសាធារណៈជាដើម។

**ខ. ឧទាហរណ៍សម្រាប់បុរស៖** មានការងារ មានបទពិសោធន៍ទាក់ទងនឹងការរួមភេទ បានបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យ រៀបការមុនអាយុកំណត់ មានកូនម្នាក់ ឬកូនប្រុសម្នាក់ មានរាងកាយមាំមួន គ្រប់គ្រងប្រពន្ធ ចូលរួមជាមួយសកម្មភាពសហគមន៍ ជាដើម។

**គ.** សម្រាប់ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា គួរតែនៅក្នុងផ្នែកសេវាកំសាន្ត ជំនាញតុបតែងមុខ អ្នកច្នៃសំលៀកបំពាក់ (ជាពិសេសសម្រាប់ក្រុមអ្នកផ្លាស់ប្តូរយេនឌ័រ) អ្នកបម្រើសេវាផ្លូវភេទ (ជាពិសេសអ្នកផ្លាស់ប្តូរយេនឌ័រ) ចំណាយលុយដើម្បីរួមភេទជាមួយបុរស មិនមានជីវិតធម្មតា និងសប្បាយរីករាយនៅក្នុងសង្គម ធ្វើឱ្យដាច់ពូជមនុស្ស នៅតែជាមួយក្រុមអ្នកស្រឡាញ់ភេទដូចគ្នា។

**ជំហានទី៥៖** នៅពេលដែលគំនិត «នៅក្នុងប្រអប់» ត្រូវបានបំពេញ សួរសមាជិកក្រុម តើការរំពឹងទុកទាំងនោះបានមកពីណា ឬពួកគេរៀនមកពីអ្នកណា។ ណែនាំសមាជិកក្រុមឱ្យសរសេរពីប្រភព នៃការរំពឹងទុកជុំវិញប្រអប់យេនឌ័រ គូរវង្វង់ជុំវិញពាក្យទាំងនោះ ឬប្រភពនីមួយៗ។

**ជំហានទី៦៖** បន្ទាប់មក ឱ្យអ្នកចូលរួមពិភាក្សានៅក្នុងក្រុមរបស់ពួកគេ អំពីតួនាទី ឥរិយាបថ និងបទដ្ឋានសង្គមកំណត់ឱ្យស្ត្រី បុរស និងអ្នកស្រឡាញ់ភេទដូចគ្នាដែលសង្គមគិតថាមិនមានលក្ខណៈទូទៅ ហើយគូរ ឬសរសេរនៅក្រៅប្រអប់។ ឱ្យក្រុមពិភាក្សាអំពីផលវិបាកដែលជាលទ្ធផលបានពីការអនុវត្តឥរិយាបថនៅក្រៅប្រអប់។ឧទាហរណ៍សម្រាប់ស្ត្រី៖ ការស្លៀកពាក់ដូចបុរស មានសកម្មភាពផ្លូវភេទ មុនពេលរៀបការ និយាយស្តីព្ទៗ ឬនិយាយនៅទីសាធារណៈ ជក់បារី ផឹកស្រា ចេញក្រៅផ្ទះដោយមិនសុំការអនុញ្ញាត ឬដើរលេងពេលយប់ជាដើម។ ឧទាហរណ៍សម្រាប់បុរស ៖ មិនមានប្រាក់ចំណូលឬលុយ យំនៅទីសាធារណៈ ទន់ខ្សោយ និយាយតិចៗ ចម្អិនអាហារ រែកទឹក ឬធ្វើការងារផ្ទះផ្សេងៗទៀតជាដើម។ ឧទាហរណ៍សម្រាប់ ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា៖ ស្លៀកពាក់តាមបែបណាមួយ រអ៊ូរទាំ ស្ថិតនៅក្នុងការពង្វក់ មានការងារល្អ មិនរៀបការ ជ្រើសរើសអត្តសញ្ញាណដោយខ្លួនឯងជាដើម។ល។

**ជំហានទី៧៖** បន្ទាប់ពីក្រុមបានរៀបរាប់ពីការរំពឹងទុករួច អំពីឥរិយាបថ អាកប្បកិរិយា រូបរាងខាងក្រៅ «ដែលសង្គមកំណត់ថាជាបុរស ស្ត្រី» និង«បុរស ស្ត្រីដែលមិនមានលក្ខណៈរួមដូចដែលសង្គមកំណត់» ឱ្យតំណាងក្រុមស្ត្រីម្នាក់ តំណាងក្រុមបុរសម្នាក់ និងក្រុមអ្នកស្រឡាញ់ភេទដូចគ្នាម្នាក់ដើម្បីបង្ហាញនូវប្រអប់យេនឌ័ររបស់ក្រុមនីមួយៗ ហើយឱ្យក្រុមនីមួយៗបន្ថែមចំពោះការបកស្រាយ និងឱ្យក្រុមធំលើកឡើងដើម្បីបញ្ជាក់ ឬមានអ្វីពីការសង្កេតរបស់ពួកគេ។

**ជំហានទី៨៖** យោងតាមបទបង្ហាញ សួរអ្នកចូលរួម ៣ ទៅ ៦សំណួរដូចខាងក្រោម៖

- តើតួនាទី និងការរំពឹងទុកអ្វីខ្លះដែលត្រូវបានដាក់ទៅឱ្យស្ត្រី? បុរស? ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា? តើដូចគ្នា ឬខុសគ្នា? ហេតុអ្វីបានជាមានភាពខុសគ្នា?
- តើការរំពឹងទុកទាំងនេះអាចជួយបាន ឬមានប្រយោជន៍ឬទេ? ប្រសិនដូច្នេះ តើអ្នកណាដែលត្រូវបានជួយ ហើយជួយដោយរបៀបណា?
- តើការរំពឹងទុកទាំងនេះធ្វើឱ្យមានការឈឺចាប់ឬទេ? ប្រសិនដូច្នេះ តើពួកគេបង្កការឈឺចាប់ដល់អ្នកណា និងដោយរបៀបណា?

តាមរយៈការពិភាក្សា សួរអ្នកចូលរួមប្រសិនពួកគេមានសំណួរ ឬមានចំណុចដែលចង់លើកយកមកពិភាក្សា។ បន្ទាប់មក អរគុណអ្នកចូលរួមសម្រាប់ការចូលរួមរបស់ពួកគេ និងជួយគ្នាឱ្យស្វែងយល់បន្ថែមអំពីស្ថានភាពរបស់អ្នកដទៃ។ សរុបសេចក្តីសម្រាប់វគ្គ ដោយឱ្យនិយមន័យយេនឌ័រ និងការបែងចែកការងារទៅតាមយេនឌ័រ។

## គោលគំនិតគន្លឹះ

**យេនឌ័រ** គឺជាការបង្កើតឡើងដោយសង្គម ដែលកំណត់ពីតួនាទី ឬថាអ្វីទៅហៅថា បុរស និងស្ត្រី ក្មេងប្រុស ឬក្មេងស្រី។

**យេនឌ័រ** គឺមិនមែនជាកត្តាជីវសាស្ត្រទេ

**យេនឌ័រ** គឺមានលក្ខណៈបុគ្គល និងផ្អែកតាមសង្គម។

ឆ្លុះបញ្ចាំង ពីរបៀបដែលទំនាក់ទំនងយេនឌ័រ និងបទដ្ឋានសង្គមជះឥទ្ធិពលទៅក្នុងគ្រប់ស្ថានភាពនៃជីវិត៖



- ធ្វើការឆ្លុះបញ្ចាំងទៅលើជីវិតរបស់យើង និងអ្នកដែលយើងធ្វើការងារជាមួយ គិតអំពីរបៀបដែលយេនឌ័រមានឥទ្ធិពលទៅលើឧបសគ្គ និងឱកាស ដែលអាចរាប់បញ្ចូល (តាមទិសដៅទ្រនិចនាឡិកា)៖

    1. អ្នកណាដែលទទួលខុសត្រូវក្នុងការធានាឱ្យមានការផ្គត់ផ្គង់ទឹក
    2. ទទួលបានការអប់រំ (ក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ)
    3. ទទួលបានការងារ (ក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ)
    4. ការចាត់ចែងក្នុងផ្ទះ
    5. ប្រើប្រាស់សេវាពីរាជរដ្ឋាភិបាល ឬស្ថាប័នហិរញ្ញវត្ថុ
    6. ប្រើប្រាស់សេវាសុខភាព និងការថែទាំ
    7. ទាក់ទងនឹងកម្មសិទ្ធិដីធ្លី និងការងារកសិកម្ម

៨.ការយល់ឃើញរបស់បុគ្គល ការយល់ឃើញផ្ទាល់ខ្លួន ការជឿជាក់លើខ្លួនឯង
៩.ទំនាក់ទំនងផ្ទាល់ខ្លួន ដៃគូស្និទ្ធស្នាល និងទំនាក់ទំនងចំពោះការយកចិត្តទុកដាក់។

**កំណត់សម្គាល់៖** អ្នកសម្របសម្រួលរំលឹកអ្នកចូលរួមថា បទពិសោធន៍ផ្ទាល់ខ្លួន និងបទពិសោធន៍ដែលចែករំលែកកំឡុងពេលពិភាក្សា គួរតែត្រូវបានទុកនៅតែក្នុងក្រុម លើកទឹកចិត្តអ្នកចូលរួមឱ្យចែករំលែកប្រសិនបើគាត់មានអារម្មណ៍សុវត្ថិភាពក្នុងការចែករំលែក អំពីថាតើបញ្ហាអ្វីខ្លះដែលត្រូវបានលើកមកពិភាក្សា ហើយតើពួកគេបានរៀនសូត្រអ្វីខ្លះពីគ្រួសារ និងមិត្តភក្តិរបស់គាត់ដែលមិនមានវត្តមាននៅទីនេះ។ ចុងបញ្ចប់ ឱ្យអ្នកចូលរួមគិតពីវិធីជំនះឧបសគ្គដែលបានពិភាក្សា ដែលអាចជួយបន្តកិច្ចសន្ទនាសម្រាប់វគ្គបន្ទាប់។

## សកម្មភាព ២គ៖ ជ្រើសរើសដោយប្រើជើង (Vote with your feet)

**វត្ថុបំណង៖** ស្វែងយល់អំពីភាពចម្រុះគ្នានៃគំនិត និងផ្តល់ឱកាសឱ្យអ្នកទាំងអស់គ្នាឆ្លុះបញ្ចាំងទៅលើឥរិយាបថរបស់ពួកគេជុំវិញការប្រកាន់យកជំនឿផ្សេងៗ ដែលទាក់ទងនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

**ថេរវេលា៖** ៤៥ នាទី
**វិធីសាស្ត្រ៖** លំហាត់អនុវត្តរៀងខ្លួន និងជាក្រុម
**សម្ភារៈដែលត្រូវការ៖** កាត ហ្វឺត និងស្កុតក្រដាស
អ្វីគួរធ្វើ និងអ្វីមិនគួរធ្វើ៖ អ្នកសម្របសម្រួលគួរតែប្រុងប្រយ័ត្នអំពីការបង្ហាញនូវជំនឿផ្ទាល់ខ្លួន ឬតម្លៃផ្ទាល់ខ្លួន ជាពិសេសចេញមកពីបរិបទផ្សេងគ្នា។ ជំនួសមកវិញ អ្នកសម្របសម្រួលគួរតែផ្តល់ទីកន្លែងដែលមានសុវត្ថិភាពដើម្បីឱ្យពួកគេចែករំលែកគំនិត។

## ការណែនាំសម្រាប់អ្នកសម្របសម្រួល៖

**ជំហានទី១៖** រៀបចំកាតចំនួន២ជាមួយពាក្យ «យល់ស្រប» និង «មិនយល់ស្រប» ដែលសរសេរ ឬគូរជាសញ្ញាសម្រាប់អ្នកចូលរួមដែលមិនអាចអានអក្សរបាន។ ប្រសិនបើមានក្រុមអ្នកមិនអាចអានអក្សរបាន សូមធ្វើការសម្រេចចិត្តជាមួយគ្នាទៅលើសញ្ញាដែលបរិយាយពីអារម្មណ៍ «យល់ស្រប» និង «មិនយល់ស្រប»។

**ជំហានទី២៖** ពន្យល់ពីគោលបំណងនៃឧបករណ៍ទៅអ្នកចូលរួមថា នេះគឺជាក្រុមអនុវត្តន៍លំហាត់ដើម្បីរៀនសូត្រដែលអ្នករាល់គ្នានៅក្នុងក្រុមមានគំនិតផ្ទាល់ខ្លួនទៅលើប្រយោគ ស្តីអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងធ្វើការឆ្លុះបញ្ចាំងលើឥរិយាបថរបស់ពួកគេរៀងខ្លួនអំពីជំនឿផ្សេងៗ។

**ជំហានទី៣៖** ដាក់កាត «យល់ស្រប» ឬ «មិនយល់ស្រប» នៅទីតាំងផ្ទុយគ្នា ដែលអ្នករាល់គ្នាអាចមើលឃើញ ព្រមជាមួយនឹងគម្លាតដែលអាចឱ្យអ្នកចូលរួមធ្វើបម្លាស់ទីបាន។

**ជំហានទី៤៖** អានប្រយោគម្តងមួយៗ ដោយប្រើបញ្ជីនៃប្រយោគ អំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រខាងក្រោម។ ឱ្យអ្នកចូលរួមធ្វើការឆ្លុះបញ្ចាំងស្ងាត់ៗ (ដោយមិនពិភាក្សាជាមួយគ្នា) អំពីឥរិយាបថ ឬគំនិតផ្ទាល់ខ្លួនអំពីប្រយោគដែលអ្នកសម្របសម្រួលបានអាន បន្ទាប់មកធ្វើបម្លាស់ទីទៅរកកាតដែលបង្ហាញពីគំនិតរបស់ពួកគេ (យល់ស្រប ឬមិនយល់ស្រប)។

| ប្រយោគ |
| --- |
| • បុរសតែងតែជាជនបង្កអំពើហិង្សា ហើយស្ត្រីគឺជាជនរងគ្រោះ។<br>• ការរំលោភសេពសន្ថវៈ មិនគួរត្រូវបានគេយកមកផ្តល់ជាចំណេះដឹងជាសាធារណៈទេ។<br>• ប្រពន្ធគួរតែបំពេញតម្រូវការផ្លូវភេទរបស់ប្តី ហើយវាមិនត្រូវបានរាប់បញ្ចូលជាការរំលោភសេពសន្ថវៈទេក្នុងករណីទំនាក់ទំនងអាពាហ៍ពិពាហ៍រវាងប្តី និងប្រពន្ធ។<br>• ស្ត្រីដែលស្លៀកពាក់សិចស៊ី ជាអ្នកបង្កឱ្យមានការបៀតបៀនផ្លូវភេទ ឬរំលោភសេពសន្ថវៈ។<br>• វាគួរតែមិនអីទេសម្រាប់បុរសដែលប៉ះពាល់ស្ត្រីដែលធ្វើការនៅបារ (ក្លិបកំសាន្ត)។<br>• វាជារឿងដែលអាចទទួលយកបាន ប្រសិនបើស្ត្រីដែលជាអ្នកគ្រប់គ្រង ស្នើសុំការអនុគ្រោះផ្លូវភេទជាមួយបុរស ដើម្បីជាថ្នូរឱ្យការផ្តល់ការងារឱ្យបុរសនោះ។<br>• រឿងដែលអាចទទួលយកបាន សម្រាប់បុរសដែលមានសម្ព័ន្ធភាពស្នេហាជាមួយនារីដទៃ ឬបុរសដទៃ អំឡុងពេលដែលគាត់ស្ថិតក្នុងចំណងអាពាហ៍ពិពាហ៍ជាមួយប្រពន្ធរបស់គាត់។<br>• បុរសត្រូវតែវាយធ្វើបាបប្រពន្ធរបស់គាត់ ដើម្បីអាចគ្រប់គ្រងប្រពន្ធរបស់គាត់បាន។<br>• បុរសដែលប្រើប្រាស់ ភាសា ឬពាក្យពេចន៍ អាក្រក់ ឬមិនសមរម្យ បៀតបៀន ឬជេរប្រពន្ធរបស់គាត់ គឺគាត់ស្រឡាញ់ប្រពន្ធរបស់គាត់ណាស់ (សូមមើលកំណត់សម្គាល់របស់អ្នកសម្របសម្រួលដូចខាងក្រោម)។<br>• ស្ត្រីគួរតែមានទំនួលខុសត្រូវទៅលើសុខភាពបន្តពូជរបស់គាត់ ដោយខ្លួនឯង គ្មានអ្វីពាក់ព័ន្ធជាមួយបុរសឡើយ។<br>• គ្មានការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍នោះទេ។<br>• ស្ត្រីដែលបដិសេធការរួមភេទជាមួយប្តីរបស់គាត់ គឺសមនឹងទទួលបានការវាយដំ។<br>• ស្ត្រីមិនត្រូវនិយាយអំពីផ្លូវភេទទេ។<br>• ស្ត្រីដែលមិនអាចមានកូនប្រុសបាន គួរតែត្រូវបានហាមឃាត់ក្នុងការចូលរួមក្នុងគ្រួសារ។<br>• បុរស ឬស្ត្រីដែលស្រឡាញ់ភេទដូចគ្នាត្រូវតែទទួលការព្យាបាលដោយប្រើថ្នាំ ឬការបង្ខំ។<br>• ស្ត្រីមិនគួរត្អូញត្អែរអំពីការបៀតបៀនផ្លូវភេទនោះទេ ប្រសិនបើវាកើតឡើងចំពោះគាត់ នៅពេលដែលគាត់ដើរលេងយប់។ |

**ជំហានទី៥៖** នៅពេលអ្នកចូលរួមទាំងអស់បម្លាស់ទី ឱ្យពួកគេពិភាក្សាជាមួយអ្នកដែលនៅជិតពួកគេ អំពីមូលហេតុដែលពួកគេបានជ្រើសរើសក្រុមនោះ ប្រសិនបើពួកគេអាចឆ្លើយបាន។

**ជំហានទី៦៖** ឱ្យអ្នកចូលរួមនៃក្រុមនីមួយៗចែករំលែកពីហេតុផលដែលពួកគេការបានជ្រើសរើស ទាំងយល់ស្រប ឬមិនយល់ស្រប។ អ្នកសម្របសម្រួលសួរថា៖

- តើមាននរណាម្នាក់ដែលចង់ចែករំលែកជាមួយក្រុមផ្សេងទៀត ពីមូលហេតុដែលពួកគេឈរនៅទីនោះទេ?
- តើពួកគេមានអារម្មណ៍ដូចម្តេចដែលបាននៅក្នុងក្រុមដែលពួកគេជ្រើសរើស?

(កំណត់សម្គាល់៖ ក្រុមតូចប្រហែលជាមានតែមនុស្ស ២ ទៅ ៣នាក់ ដូច្នេះអ្នកសម្របសម្រួលសួរថា៖ តើពួកគេមានអារម្មណ៍ដូចម្តេចដែលបាននៅក្នុងក្រុមដែលមានគ្នាតិច?)

**ជំហានទី៧៖** បន្ទាប់ពីស្តាប់ឮពីមតិរបស់ក្រុមនីមួយៗរួច សួរអ្នកចូលរួមថាតើមាននរណាដែលចង់ផ្លាស់ប្តូរទីកន្លែង និងផ្លាស់ទីទៅរកកាតផ្សេងដែរឬទេ។ ប្រសិនអ្នកចូលរួមដែលបានផ្លាស់ប្តូរទីតាំងនោះចង់ចែករំលែក អ្នកសម្របសម្រួលគួរតែសួរថាតើហេតុអ្វីបានជាពួកគេផ្លាស់ប្តូរទីតាំង។

**ជំហានទី៨៖** ប្រើប្រាស់សំណួរឆ្លុះបញ្ចាំងមុននឹងបិទបញ្ចប់ មុនពេលធ្វើការពិភាក្សាពីផែនការសកម្មភាព៖

- តើអ្នកបានរៀនសូត្រអ្វីថ្មីពីការពិភាក្សានេះ? មានអ្វីដែលធ្វើឱ្យអ្នកភ្ញាក់ផ្អើលទេ? តើការពិភាក្សានេះផ្លាស់ប្តូរការយល់ឃើញរបស់អ្នកអំពីជំនឿ ឬបទដ្ឋានសង្គមឬទេ? តើមានគុណប្រយោជន៍អ្វីខ្លះពីការពិភាក្សា កត្តាប្រឈម ឬការផ្លាស់ប្តូរជំនឿ ឥរិយាបថ និងអាកប្បកិរិយា?តើមានគុណវិបត្តិ ផលវិបាក ឬទណ្ឌកម្មអ្វីខ្លះ? តើយើងគួរជួយគ្នា ដើម្បីផ្លាស់ប្តូរជំនឿដែលយើងបានពិភាក្សា ហើយជួយផ្លាស់ប្តូរឥរិយាបថទាំងនោះដោយរបៀបណា?

**ជំហានទី៩៖** សរុបសេចក្តីដោយអរគុណអ្នកចូលរួមសម្រាប់ការចូលរួមរបស់ពួកគេ និងធ្វើការសង្ខេបដោយប្រើប្រាស់ចំនុចគន្លឹះដូចជា៖ យើងទាំងអស់គ្នាមានជំនឿវិជ្ជមាន និងអវិជ្ជមាន ឥរិយាបថ អាកប្បកិរិយាដែលជះឥទ្ធិពលមកលើយើងតាមរបៀបផ្សេងគ្នា។ ឧបករណ៍នេះ បានបង្ហាញពីទស្សនៈដែលសហគមន៍ប្រកាន់ខ្ជាប់ទាក់ទិនបទដ្ឋានសង្គមនៃការរាលដាលទៅលើអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ឥរិយាបថ និងគុណតម្លៃរបស់យើងតែងតែត្រូវបានធ្វើឱ្យស្របតាមបរិបទ និងស្ថានភាព ប៉ុន្តែមិនមែនអ្វីៗគឺត្រូវតែមានស ខ្មៅនោះទេ ដូច្នេះវាមិនមែនជាការងាយស្រួល ដើម្បីដឹងថាយើងមានអារម្មណ៍យ៉ាងណា។ ជាការសំខាន់ណាស់ក្នុងការកត់សម្គាល់ថាទាំងអស់គ្នាមិនចាំបាច់ប្រកាន់យកតម្លៃ ឬគំនិតដូចគ្នាទាំងអស់នោះទេ ទៅលើបញ្ហាមួយចំនួន ទោះបីជាវាគ្រាន់តែជាការគិតក៏ដោយ ក៏យើងទាំងអស់គ្នាត្រូវធានាថាមិនធ្វើឱ្យនរណាម្នាក់ឈឺចាប់ដែលកើតចេញពីអ្វីដែលយើងធ្វើ និងប្រាកដជាក់ថាអ្វីដែលយើងធ្វើមិនខុសច្បាប់ និងប៉ះពាល់ដល់សិទ្ធិមនុស្ស។ ទោះជាអ្នកខ្លះដែលមើលទៅហាក់ដូចជាចូលចិត្តយើង និងអ្នកដែលយើងយើងគោរពក៏ដោយ ក៏ពួកគេអាចមានគំនិត និងការយល់ឃើញខុសគ្នាដែរ។ វាជាកិច្ចការរបស់យើងក្នុងការគោរពលើភាពខុសគ្នា និងយល់ពីមូលហេតុរបស់វា។

## កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល៖

រំលឹកអ្នកចូលរួមពីវត្ថុបំណង ដែលមិនមែនជាការប្រកែក ឬបញ្ចុះបញ្ចូលឱ្យអ្នកចូលរួមផ្លាស់ប្តូរការគិតរបស់ពួកគេឡើយ ប៉ុន្តែត្រូវព្យាយាមយល់ និងរៀនសូត្រអំពីការគិតខុសៗគ្នា។ ជាការសំខាន់ដែលត្រូវកត់សម្គាល់ថាឥរិយាបថមួយចំនួនដែលត្រូវបានគេទទួលយកនោះ អាចនាំឱ្យមានអំពើហិង្សាលើរូបរាងកាយ និងធ្វើឱ្យកាន់តែឈឺចាប់ទៅលើជីវិតស្ត្រី នៅពេលដែលគេមិនបានគិតអំពីឥទ្ធិពលតូចៗទៅលើជីវិតរស់នៅប្រចាំថ្ងៃ។

ធ្វើឱ្យប្រាកដថាអ្នកចូលរួមមានឱកាសគ្រប់គ្រាន់ដើម្បីសួរសំណួរ ឬបញ្ជាក់អំពីចំណុចដែលបានលើកឡើងកំឡុងពេលពិភាក្សា។

## និយមន័យ អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងទម្រង់នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ

### ការណែនាំសម្រាប់អ្នកសម្របសម្រួល៖

**ជំហានទី១៖** រកអ្នកស្ម័គ្រចិត្តម្នាក់ឱ្យអានឮៗនូវនិយមន័យ អំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលមាននៅក្នុងបទបង្ហាញ។ អំពើហិង្សាទាក់ទងនឹងយេនឌ័រ គឺជាអំពើហិង្សាដែលប្រឆាំងដោយផ្ទាល់ទៅនឹងបុគ្គល ដែលពាក់ព័ន្ធនឹងយេនឌ័រ ឬភេទ។ វារាប់បញ្ចូលទាំងអំពើដែលធ្វើឱ្យប៉ះពាល់ដល់ផ្លូវកាយ ផ្លូវចិត្ត ឬផ្លូវភេទ ការគំរាមកំហែងនៃទង្វើបែបនេះ ការបង្ខិតបង្ខំ និងការដកហូតសេរីភាពផ្សេងទៀត។ ខណៈពេលដែលស្ត្រី បុរស ក្មេងប្រុស ក្មេងស្រីអាចជាជនរងគ្រោះនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ស្ត្រី និងក្មេងស្រី គឺជាជនរងគ្រោះចម្បង។[31]

អំពើហិង្សាលើស្ត្រី គឺជាទង្វើនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រទាំងឡាយណា ដែលបណ្តាលឱ្យមាន ឬទំនងជាបណ្តាលឱ្យមានផលប៉ះពាល់ដល់រាងកាយ ផ្លូវភេទ ឬផ្លូវចិត្ត ឬរងទុក្ខដល់ស្ត្រី រួមទាំងការគំរាមកំហែងនៃអំពើបែបនេះ ការបង្ខិតបង្ខំ ឬការដកហូតសេរីភាពតាមអំពើចិត្ត ទោះជាកើតឡើងនៅទីសាធារណៈ ឬក្នុងជីវិតឯកជនក៏ដោយ។

[31] Cambodia National Plan of Action to Prevent Violence Against Women 2019-2023

វិសមភាពយេនឌ័រត្រូវបានគេទទួលស្គាល់ជាសកលថាជាឫសគល់នៃអំពើហិង្សាលើស្ត្រី។ ពន្យល់ពីនិយមន័យ និងពាក្យគន្លឹះដែលគួរបន្ទាត់ពីក្រោម។ រំលឹកអ្នកចូលរួមថា អំពើហិង្សាទាក់ទងនឹងយេនឌ័របានចាក់ឫសក្នុងវិសមភាពយេនឌ័រ និងអតុល្យភាពនៃអំណាចដែលធ្វើឱ្យកាន់តែធ្ងន់ធ្ងរ កំឡុងពេលមានជម្លោះ ឬគ្រោះថ្នាក់ណាមួយ។ (ចំណុចនេះនឹងត្រូវបានជជែកបន្ថែមទៀតនៅក្នុងវគ្គបន្ទាប់)។

**ជំហានទី២៖** ឱ្យអ្នកចូលរួមរៀបរាប់ទម្រង់ និងប្រភេទនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រមុននឹងបង្ហាញស្លាយបទបង្ហាញស្តីពីអំពើហិង្សាទៅលើ ផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត សង្គម សេដ្ឋកិច្ច ការមិនទទួលបានបានធនធាន ឬឱកាស។ ចំណុចដែលត្រូវរៀនសូត្រ គឺការយល់ដឹងអំពីប្រភេទផ្សេងគ្នានៃអំពើហិង្សា ហើយអំពើហិង្សាទាំងនោះមិនមែនគ្រាន់តែតាមរយៈផ្លូវកាយនោះទេ។ សួរអ្នកចូលរួមថា តើពួកគេជឿដែរឬទេថាការមិនទទួលបានធនធាន និងឱកាសគឺជាទម្រង់នៃអំពើហិង្សា។ មានការគិតផ្សេងគ្នានៅក្នុងបន្ទប់បណ្តុះបណ្តាល ហើយអ្នកអាចលើកឧទាហរណ៍ជាក់លាក់ទៅតាមបរិបទរបស់អ្នក។

**ជំហានទី២៖** ឱ្យអ្នកចូលរួមរៀបរាប់ទម្រង់ និងប្រភេទនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រមុននឹងបង្ហាញស្លាយបទបង្ហាញស្តីពីអំពើហិង្សាទៅលើ ផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត សង្គម សេដ្ឋកិច្ច ការមិនទទួលបានបានធនធាន ឬឱកាស។ ចំណុចដែលត្រូវរៀនសូត្រ គឺការយល់ដឹងអំពីប្រភេទផ្សេងគ្នានៃអំពើហិង្សា ហើយអំពើហិង្សាទាំងនោះមិនមែនគ្រាន់តែតាមរយៈផ្លូវកាយនោះទេ។ សួរអ្នកចូលរួមថា តើពួកគេជឿដែរឬទេថាការមិនទទួលបានធនធាន និងឱកាសគឺជាទម្រង់នៃអំពើហិង្សា។ មានការគិតផ្សេងគ្នានៅក្នុងបន្ទប់បណ្តុះបណ្តាល ហើយអ្នកអាចលើកឧទាហរណ៍ជាក់លាក់ទៅតាមបរិបទរបស់អ្នក។

នៅក្នុងការណែនាំអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ បានបញ្ជាក់យ៉ាងច្បាស់ថាការមិនទទួលបានធនធាន ឬឱកាសគឺជាទម្រង់នៃអំពើហិង្សា ពីព្រោះតែវាបានបង្កើតឱ្យមានការឈឺចាប់កើតឡើង។ ឧទាហរណ៍៖ ប្រសិនជាក្មេងស្រីម្នាក់មិនទទួលបានការអប់រំ ពីព្រោះគាត់គឺជាក្មេងស្រី នេះគឺជាទម្រង់នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ការឈឺចាប់ដែលកើតចេញពីការមិនទទួលបានការអប់រំនេះ នឹងបន្តនៅក្នុងជីវិតរបស់គាត់ ប្រហែលជាគាត់នឹងមិនចេះអក្សរ និងមិនអាចទទួលបានព័ត៌មានសម្រាប់សុខភាព និងសុវត្ថិភាពរបស់គាត់ គាត់នឹងមិនមានឱកាសក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងប្រហែលជានឹងត្រូវពឹងផ្អែកលើអ្នកដទៃច្រើន ធ្វើឱ្យគាត់ស្ថិតក្នុងហានិភ័យ នៃការរំលោភបំពាន និងការកេងប្រវ័ញ្ច គាត់អាចនឹងឆាប់រៀបការ (ដែលជាទម្រង់នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រដោយផ្ទាល់) ធ្វើឱ្យគាត់ងាយជួបនឹងហានិភ័យនៃការមានផ្ទៃពោះនៅវ័យក្មេង ភាពលំបាកផ្នែកសុខភាព និងអំពើហិង្សាតាមរយៈដៃគូស្និទ្ធស្នាល ជាដើម។

## វគ្គទី២៖ ផលប៉ះពាល់ និង មូលហេតុនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ

**វត្ថុបំណង៖** គោលបំណងនៃលំហាត់នេះ គឺព្យាយាមស្វែងយល់ពីផលប៉ះពាល់នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលប៉ះពាល់ដល់យើងទាំងអស់គ្នា ដូចជា តើទំនាក់ទំនងមានន័យដូចម្តេច នៅពេលដៃគូម្ខាងខ្លាច ដៃគូម្ខាងទៀតហើយបន្ថែមពីលើផលវិបាកធ្ងន់ធ្ងរទាំងនោះ។
**ថេរវេលា៖** ៤៥ នាទី
**វិធីសាស្ត្រ៖** ធ្វើការជាក្រុមតូច ពិភាក្សា និងឆ្លុះបញ្ចាំង
**សម្ភារៈ និងការរៀបចំ៖** ព្រីនសេណារីយ៉ូ ដែលមាននៅខាងចុងខាងក្រោយនៃការណែនាំនេះ

អ្វីគួរធ្វើ និងអ្វីមិនគួរធ្វើ៖ ធានាថាអ្នកចូលរួមមានភាពងាយស្រួលក្នុងការចែករំលែកបទពិសោធន៍របស់ពួកគេដោយគ្មានការវិនិច្ឆ័យ។ នៅពេលជាមួយគ្នានេះ វាអាចមានការលំបាក ដូច្នេះឱ្យអ្នកចូលរួមចែករំលែកអ្វីដែលពួកគេមានអារម្មណ៍ងាយស្រួល និងប្រុងប្រយ័ត្ននៅពេលពិភាក្សាពីអ្វីដែលមានភាពរសើបខ្លាំង ឬអាចធ្វើឱ្យពួកគេមិនសុខស្រួល។

## ការណែនាំសម្រាប់អ្នកសម្របសម្រួល៖

**ជំហានទី១៖** ពន្យល់អ្នកចូលរួមថា នៅក្នុងលំហាត់នេះ យើងអាចស្វែងយល់ពីផលប៉ះពាល់របស់អំពើហិង្សាទាក់ទងនឹងយេនឌ័រមកលើស្ត្រី បុរស កុមារតូចៗ អ្នកស្រឡាញ់ភេទដូចគ្នា និងសហគមន៍ទាំងមូល។

**ជំហានទី២៖** បែងចែកជា ៤ ទៅ ៥ក្រុម។ ក្រុមនីមួយៗនឹងទទួលបានសេណារីយ៉ូមួយដែលនិយាយពីដៃគូ និងពិភាក្សាសំណួរ។ ក្រុមនឹងអានសេណារីយ៉ូ ជាមួយគ្នា បន្ទាប់មកពិភាក្សាសំណួរ។ ក្រុមនីមួយៗមានពេល ១០នាទីដើម្បីពិភាក្សា និង៥នាទីសម្រាប់ធ្វើបទបង្ហាញ។

**ជំហានទី៣៖** ឱ្យសេណារីយ៉ូ (លំហាត់ចំនួន១ សម្រាប់១ក្រុម) និងចាប់ផ្តើមធ្វើលំហាត់។ ពិនិត្យមើលតាមក្រុមដើម្បីធានាថាទាំងអស់គ្នាតាមទាន់។ លើកទឹកចិត្តក្រុមឱ្យធ្វើការស្រមើស្រមៃ ដើរតួក្នុងសេណារីយ៉ូ និងគិតពីផលប៉ះពាល់ពិតប្រាកដ (១០នាទី)។

**ជំហានទី៤៖** បន្ទាប់ពីរយៈពេល ១០នាទីកន្លងផុត នាំក្រុមមកជុំគ្នាវិញ។ ឱ្យក្រុមទី១ធ្វើបទបង្ហាញ។ ឱ្យពួកគេចាប់ផ្តើម ដោយអានសេណារីយ៉ូឮៗទៅកាន់អ្នកចូលរួមទាំងអស់។ ពួកគេអាចអានសំណួរពិភាក្សា និងបង្ហាញចម្លើយរបស់ពួកគេ។ មិនត្រូវប្រាប់ក្រុមអំពីប្រភេទនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងសេណារីយ៉ូរបស់ពួកគេទេ។
សេណារីយ៉ូ បង្ហាញពីប្រភេទនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ៖ ១. អំពើហិង្សាលើរាងកាយ ២. អំពើហិង្សាផ្លូវភេទ ៣. អំពើហិង្សាផ្នែកសេដ្ឋកិច្ច ៤. អំពើហិង្សាផ្លូវចិត្ត។

**ជំហានទី៥៖** បន្ទាប់ពីក្រុមទីមួយបានបញ្ចប់ការធ្វើបទបង្ហាញ សួរអ្នកចូលរួម ថាតើពួកគេមានសំណួរ ឬមានអ្វីចង់បន្ថែមដែរឬទេ។ សួរប្រដេញតាមដែលត្រូវការ ដើម្បីជួយអ្នកចូលរួមឱ្យឆ្លុះបញ្ចាំងថាតើប្រភេទនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រពិតជាប៉ះពាល់ទៅលើបុគ្គលដែលពាក់ព័ន្ធ និងរាំងទំនាក់ទំនងល្អរបស់ដៃគូ និងគ្រួសារពិតមែន។

**ជំហានទី៦៖** បន្តធ្វើបែបនេះជាមួយក្រុមដែលនៅសល់។ សួរប្រដេញតាមដែលត្រូវការ ដើម្បីទាញយកផលវិបាកគន្លឹះៗ។ ឧទាហរណ៍នៃផលប៉ះពាល់រាប់បញ្ចូល (ទាំងនេះនឹងណែនាំអ្នកនៅក្នុងសំណួរប្រដេញដែលអ្នកមិនចាំបាច់អានវាទេ)៖

**ក. ផលប៉ះពាល់លើស្ត្រី៖**

១. រូបរាងកាយ៖ របួសលើរាងកាយ ការមានផ្ទៃពោះដែលមិនចង់បាន បញ្ហាសុខភាពបន្តពូជ។

២. ផ្លូវចិត្ត៖ ភ័យខ្លាច នៅឆ្ងាយពីគេឯង មិនច្បាស់ពីខ្លួនឯង មានទំនុកចិត្តទាប ខ្វះសមត្ថភាពបញ្ចេញសក្តានុពលឱ្យបានពេញលេញ ការរំពឹងទុកទាបចំពោះខ្លួនឯង និងអ្នកដទៃ ភន្តច្រឡំ មិនសប្បាយចិត្ត ទទួលយកនូវអ្វីដែលធ្វើឱ្យពួកគេឈឺចាប់។

**ខ. ផលប៉ះពាល់លើកុមារ៖**

ផលវិបាកលើរូបរាងកាយ និងផ្លូវចិត្ត គិតថាអំពើហិង្សាទាក់ទងនឹងយេនឌ័រគឺជារឿងធម្មតាក្នុងទំនាក់ទំនង (អាចបង្កឱ្យមានអំពើហិង្សានៅពេលធំពេញវ័យ ឬបង្កើតទំនាក់ទំនងដែលមានអំពើហិង្សា) ភ័យខ្លាច នៅឆ្ងាយពីគេឯង ខ្វះទំនុកចិត្ត ខ្វះទំនាក់ទំនងល្អជាមួយឪពុកម្តាយ មិនអាចរកឃើញសក្តានុពលពេញលេញរបស់ខ្លួន។

**គ. ផលប៉ះពាល់ទៅលើទំនាក់ទំនង ឬគ្រួសារ រាប់បញ្ចូលទាំងក្រុមអ្នកស្រឡាញ់ភេទដូចគ្នា៖**

ទំនាក់ទំនង ឬគ្រួសារ មិនមានភាពរឹងមាំ ខ្វះទំនាក់ទំនងដែលមានអត្ថន័យជាមួយដៃគូ ខ្វះការជឿទុកចិត្ត ទំនាក់ទំនងមិនសមតាមតម្រូវការរបស់ដៃគូទាំងសងខាង ទំនាក់ទំនង ឬគ្រួសារមិនមានភាពរីករាយពេញលេញ ខ្វះទំនាក់ទំនងដែលមានអត្ថន័យរវាងអ្នកប្រព្រឹត្ត និងកុមារ មិនមានការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច។

ទាំងអស់នេះផ្តល់ផលប៉ះពាល់អវិជ្ជមានចំពោះបុរស (ទោះជាគាត់ជាអ្នកប្រព្រឹត្តក៏ដោយ) ដោយសារវារារាំងពួកគេពីការមានទំនាក់ទំនងល្អ មិនអាចរស់នៅជាមួយគ្រួសារដែលមានភាពសប្បាយរីករាយ សុខភាពល្អ និងផលិតភាពខ្ពស់។ វានាំឱ្យស្ត្រី និងកុមារភ័យខ្លាច បុរសមិនបានប្រើប្រាស់អំណាចជាវិជ្ជមាន ហើយមិនរីករាយនឹងសារៈប្រយោជន៍នៃទំនាក់ទំនងវិជ្ជមាននោះទេ។

**ជំហានទី៧៖** សន្និដ្ឋានថា បន្ទាប់ពីក្រុមទាំងអស់បានបង្ហាញរួច សួរអ្នកចូលរួម៖ តើអ្នកគិតថាវាប៉ះពាល់ដល់សហគមន៍យ៉ាងដូចម្តេច នៅពេលយើងលើកលែងឱ្យ និងទទួលយកទម្រង់នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងទំនាក់ទំនងរបស់យើង? (គំរូចម្លើយ៖ វារារាំងសហគមន៍យើងពីការអភិវឌ្ឍពេញលេញ និងបន្តប្រើប្រាស់អំណាចបែបអវិជ្ជមានរវាងបុរស និងស្ត្រី)។

## សេណារីយ៉ូទី១៖

ចាន់ និងសុខាគឺជាដៃគូស្នេហានឹងគ្នា។ ពួកគេមានកូន៤នាក់។ ចាន់ធ្វើការងារជាកសិករ ហើយសុខាមើលថែរកូនៗ និងផ្ទះសម្បែង។ ពួកគេទាំង២ចំណាយពេលធ្វើការងារពេញ១ថ្ងៃតែម្តង ដោយសុខាមើលថែទាំអ្វីៗទាំងអស់នៅផ្ទះ ហើយចាន់ធ្វើការងារកសិករ។ ជីវិតអាចជួបនិងការលំបាក។

ចាន់រំពឹងថា ផ្ទះរបស់គាត់មានអ្នកមើលថែបានល្អ ហើយអ្វីៗត្រូវបានរៀបចំឱ្យគាត់ជាស្រេច។ គាត់ជារឿយៗតែងតែខឹងមួម៉ៅជាមួយសុខា នៅពេលអ្វីត្រូវបានរៀបចំមិនបានដូចបំណងរបស់គាត់ ដូចជា ពេលគាត់មកផ្ទះយឺតពេល ហើយអាហារបានត្រជាក់បាត់ទៅហើយ។ នៅពេលគាត់ខឹងម្តងៗ គាត់ស្រែកដាក់សុខា។ គាត់តែងតែវាយសុខា។ គាត់ជឿថាការវិន័យបែបនេះចំពោះប្រពន្ធជារឿងសំខាន់ ដើម្បីរក្សារបៀបរបប សណ្តាប់ធ្នាប់នៅក្នុងផ្ទះសម្បែង។ សុខាព្យាយាមទទួលយកនូវការវាយដំនោះ ជាជាងដែលគាត់តបត។ ប្រសិនបើគាត់ទទួលយកវា ដូច្នេះរឿងឆាប់ចប់ ហើយប្តីគាត់មិនទៅធ្វើអ្វីកូនៗទេ។ ពេលខ្លះសុខា រត់ទៅបន្ទប់មួយទៀតនៅពេលចាន់វាយដំគាត់ដើម្បីលាក់បាំងមិនឱ្យកូនៗឃើញទង្វើរនោះ។ គាត់មិនបានស្វែងរកការព្យាបាលរបួសស្នាមអ្វីទេ។ គាត់គ្រាន់តែដឹងថារឿងទាំងអស់នេះគឺជារឿងឯកជនប៉ុណ្ណោះ។ គាត់ក៏មិនដឹងដែរ ឬក៏គាត់ប្រហែលគិតថា គាត់ធ្វើអ្វីមួយដែលសមនឹងទទួលរងការវាយដំបែបនេះហើយ។ ប្រហែលជាគាត់អាចជាប្រពន្ធល្អហើយ។ សុខាធ្វើការយ៉ាងហត់នឿយស្ទើរតែរាល់ថ្ងៃ ដើម្បីរៀបចំអ្វីៗគ្រប់យ៉ាង ឱ្យដូចប្តីគាត់ចង់បាន ហើយគាត់បានបន់ស្រន់យ៉ាងស្ងៀមស្ងាត់ថា ប្តីគាត់នឹងមកផ្ទះដោយសន្តិភាព។ សុខារង់ចាំដោយមានមន្ទិលខ្វាយខ្វល់នៅឯទ្វារផ្ទះ នៅពេលប្តីមកដល់ផ្ទះ ថាតើប្តីគាត់នឹងមានអារម្មណ៍បែបណា។

**សំណួរពិភាក្សា៖**

១. តើនេះជាអំពើហិង្សាប្រភេទអ្វី?

២. តើអ្នកគិតថាទង្វើរនោះផ្តល់ផលយ៉ាងដូចម្តេចដល់សុខា?

**ក.** តើមានផលវិបាកអ្វីដល់រាងកាយ?

**ខ.** តើមានផលវិបាកអ្វីដល់ផ្លូវចិត្ត?

៣. តើអ្នកគិតថា ទង្វើរនោះធ្វើឱ្យនាងមានអារម្មណ៍យ៉ាងណាចំពោះខ្លួនឯង?

៤. តើអ្នកគិតថាចាន់មានអារម្មណ៍យ៉ាងណាចំពោះខ្លួនឯង? តើអ្នកគិតថាគាត់ជឿជាក់លើអំណាចរបស់គាត់នៅក្នុងចំណងស្នេហានេះយ៉ាងណា?

៥. តើអ្នកគិតថាការដែលបានដឹងឮ ឬឃើញអំពើហិង្សាមានផលប៉ះពាល់យ៉ាងណាដល់កូនៗពួកគេ?

**ក.** តើទង្វើនោះធ្វើឱ្យពួកគេមានអារម្មណ៍យ៉ាងណា?

**ខ.**តើវាបានបង្រៀនអ្វីខ្លះដល់ពួកគេ អំពីទំនាក់ទំនងរវាងស្ត្រី និងបុរស?

## សេណារីយ៉ូទី២៖

**សុខា និងចាន់** ជាដៃគូស្នេហានឹងគ្នា។ ពួកគេមានកូនចំនួន ៤នាក់។ ចាន់ប្រកបការងារជាកសិករ ហើយសុខាមើលថែផ្ទះ និងកូនៗ។ ពួកគេទាំងពីរនាក់ចំណាយពេលធ្វើការយូរ។ សុខាមើលការខុសត្រូវក្នុងផ្ទះ ហើយចាន់ធ្វើការនៅចំការ។ ជីវិតនេះលំបាកណាស់។

សុខា ក្រោកពីព្រលឹម ដើម្បីរៀបចំអាហារ និងផ្ទះជូនអ្នករាល់គ្នា។ នាងធ្វើការពេញមួយថ្ងៃ ហើយពេលល្ងាច គាត់គឺជាអ្នកចុងក្រោយដែលញ៉ាំអាហារពេលល្ងាច ហើយជាអ្នកសម្អាតបន្ទាប់ពីមនុស្សគ្រប់គ្នាញ៉ាំរួច។ នាងអស់កម្លាំងបន្ទាប់ពីធ្វើកិច្ចការងារហើយពេញ១ថ្ងៃ។ ពេលចាន់មកដល់ផ្ទះ គាត់ហូបបាយហើយក៏សម្រាកខ្លះ។ នៅពេលដែលដល់ពេលចូលគេង គាត់ចង់រួមភេទនៅពេលណាដែលគាត់ចង់បាន។
គាត់មិនខ្វល់ថាសុខាក៏ចង់រួមភេទដែរឬទេ ហើយមិនបានជួយរៀបចំនាងនោះទេ។ នាងតែងតែទទួលរងការឈឺចាប់។ បើនាងព្យាយាមបដិសេធ ចាន់នឹងខឹងទាមទារថាជាសិទ្ធិរបស់ប្តីក្នុងការរួមភេទជាមួយប្រពន្ធ ហើយចាន់កាន់តែឆេវឆាវ។ ពេលខ្លះគាត់ស្រែករហូតនាងខ្លាច ឬប្រើកម្លាំងកាយដើម្បីតបតនឹងនាង។ ដូច្នេះហើយ ទើបនាងឈប់បដិសេធ ហើយឱ្យគាត់ធ្វើអ្វីដែលគាត់ចង់ ទោះជាវាធ្វើឱ្យនាងឈឺចាប់ក៏ដោយ។ ពេលខ្លះ ការឈឺចាប់គឺលើសលប់ពេក ដែលធ្វើឱ្យនាងយំ ប៉ុន្តែគាត់ធ្វើមិនដឹង។ ស្ទើររាល់យប់ នាងគ្រាន់តែបន់ស្រន់ក្នុងចិត្ត សូមកុំឱ្យចាន់មកផ្ទះដោយមានអារម្មណ៍ចង់រួមភេទ។ នាងខ្លាច មិនហ៊ានចូលបន្ទប់គេង នៅពេលចាន់នៅផ្ទះ។

**សំណួរពិភាក្សា៖**
១. តើអ្នកគិតថានេះជាអំពើហិង្សាប្រភេទអ្វី?
២. តើអ្នកគិតថាទង្វើរនេះផ្តល់ផលប៉ះពាល់យ៉ាងដូចម្តេចចំពោះសុខា?
   **ក.** តើមានផលវិបាកអ្វីខ្លះដល់រូបរាងកាយ?
   **ខ.** តើមានផលវិបាកអ្វីខ្លះដល់ផ្លូវចិត្ត?
៣. តើអ្នកគិតថាទង្វើនេះធ្វើឱ្យសុខាមានអារម្មណ៍យ៉ាងណា?
៤. តើអ្នកគិតថាវាជះឥទ្ធិពលដល់ចំណងស្នេហារវាងចាន់ និងសុខាយ៉ាងដូចម្តេច?

## សេណារីយ៉ូទី៣៖

**ចាន់ និងសុខា** ជាដៃគូស្នេហានឹងគ្នា។ ពួកគេមានកូនចំនួន ៤នាក់។ ចាន់គឺជាកសិករ ហើយសុខាមើលថែផ្ទះ និងកូនៗ។ ពួកគេទាំងពីរនាក់ចំណាយពេលធ្វើការយ៉ាងយូរ សុខាមើលការខុសត្រូវក្នុងផ្ទះ ហើយចាន់ធ្វើការនៅចំការ។ ជីវិតអាចនឹងលំបាក។ សុខាមិនត្រូវបានអនុញ្ញាតឱ្យធ្វើការនៅក្រៅផ្ទះទេ។ ចាន់ជាអ្នកទទួលខុសត្រូវលើការរកប្រាក់ចំណូល ហើយគាត់គ្រប់គ្រងការចាយវាយដែលគាត់រកបាន។ គាត់បែងចែកលុយមួយចំនួនឱ្យសុខាសម្រាប់ចំណាយលើសម្ភារៈប្រើប្រាស់ក្នុងផ្ទះ។ សុខា មិនអាចដឹងច្បាស់ថាតើចាន់រកលុយបានប៉ុន្មាន ឬមានលុយប៉ុន្មាននោះទេ។ ចំណែកលុយដែលនាងបានទទួល គឺប្រែប្រួលរៀងរាល់សប្តាហ៍ ហើយនាងមិនប្រាកដថា តើចាន់រកចំណូលបានតិច ឬចំណាយលើអ្វីផ្សេងទៀតនោះទេ។ ចាន់មួម៉ៅនៅពេលគាត់រកលុយបានតិចសម្រាប់ចាត់ចែងក្នុងផ្ទះ ដូចជាអាហារ ឬសាប៊ូ ប៉ុន្តែសុខាមិនអាចពិភាក្សារឿងទាំងនេះជាមួយចាន់បានទេ។ នាងបានគិតថាអ្វីដែលត្រូវលក់ និងអ្វីដែលត្រូវសន្សំ ប៉ុន្តែនាងមិនអាចចែករំលែកគំនិតនេះជាមួយចាន់បានទេ ព្រោះការធ្វើបែបនេះមិនមែនជាអ្វីដែលស្ត្រីត្រូវធ្វើទេ។ នាងភ័យខ្លាច ពេលចាន់ត្រឡប់មកផ្ទះវិញពីកន្លែងផឹកស៊ី។

**សំណួរពិភាក្សា៖**
១. តើអ្នកគិតថានេះជាអំពើហិង្សាប្រភេទអ្វី?
២. តើអ្នកគិតថាវាផ្តល់ផលប៉ះពាល់យ៉ាងណាដល់សុខា?
៣. តើអ្នកគិតថាវាធ្វើឱ្យសុខាមានអារម្មណ៍យ៉ាងណា?
៤. តើអ្នកគិតថាវាប៉ះពាល់ដល់ការចាត់ចែងផ្ទះសម្បែងដូចម្តេច?

៥. តើអ្នកគិតថាវាប៉ះពាល់ដល់ចំណងស្នេហារវាងចាន់ និងសុខាដូចម្តេច?
៦. តើអ្នកគិតថា កូនៗរបស់ចាន់ និងសុខារៀនបានអ្វីខ្លះពីទង្វើរនេះ?

## សេណារីយ៉ូទី៤៖

**ចាន់ និងសុខា** ជាដៃគូស្នេហានឹងគ្នា។ ពួកគេមានកូនចំនួន ៤នាក់។ ចាន់ធ្វើការងារជាកសិករ ហើយសុខាមើលថែផ្ទះ និងកូនៗ។ ពួកគេទាំងពីរនាក់ចំណាយពេលធ្វើការយ៉ាងយូររៀងរាល់ថ្ងៃ។ សុខាមើលការខុសត្រូវក្នុងផ្ទះ ហើយចាន់ធ្វើការនៅចំការ។ ជីវិតអាចនឹងរាងលំបាក។ ចាន់ជឿថាគាត់ជាប្តីល្អព្រោះគាត់មានទ្រព្យសម្បត្តិ និងរកចំណូលបានខ្លះ។គាត់តែងតែរំលឹកសុខាថា គាត់គឺជាអ្នកដែលផ្តល់ជម្រក និងអាហារនៅលើតុឱ្យនាង ដូច្នេះហើយ នាងចាំបាច់ត្រូវបង្ហាញថានេះជាតម្លៃដែលនាងបានមកពីចាន់។ ប្រសិនបើចាន់មិនសប្បាយចិត្តនឹងរឿងអ្វីមួយក្នុងគ្រួសារ ដែលជាញឹកញាប់ គាត់ស្រែកដាក់សុខា ឬហៅនាងថា «ល្ងង់» និង «ស្រីល្ងង់»។ ជារឿយៗគាត់រិះគន់រសជាតិអាហារដែលសុខាចម្អិន ហើយប្រាប់នាងថាគាត់គួររើសដៃគូជាមួយនារីណាម្នាក់ដែលយ៉ាងហោចណាស់ក៏ចេះពីរបៀបចម្អិន ឱ្យបានត្រឹមត្រូវសម្រាប់ប្តីគាត់ដែរ។ប៉ុន្តែតឡូវនេះគាត់ «ជាប់គាំង» ជាមួយនាងហើយ។ លើសពីនេះ ពួកគេមិននិយាយគ្នាច្រើនទេ។ ចាន់ ចូលចិត្តចំណាយពេលជាមួយមិត្តភក្តិជាជាងនៅផ្ទះ ហើយញុំាបាយតែម្នាក់ឯងនៅក្នុងផ្ទះ។ ពេលគាត់ត្រូវការអ្វីមួយ គាត់ហៅសុខាមក។ សុខាយករបស់ដែលចាន់ត្រូវការហើយព្យាយាមចាកចេញពីចាន់ ទុកឱ្យគាត់នៅម្នាក់ឯង។ នាងសុខចិត្តមិននិយាយទៅកាន់ចាន់ ជៀសវាងខ្លាចចាន់គាត់រិះគន់ ឬរអ៊ូដាក់នាង។

**សំណួរពិភាក្សា៖**
១. តើអ្នកគិតថានេះជាអំពើហិង្សាប្រភេទអ្វី?
២. តើអ្នកគិតថាមានផលប៉ះពាល់យ៉ាងណាចំពោះសុខា?
៣. តើអ្នកគិតថាវាធ្វើឱ្យសុខាមានអារម្មណ៍យ៉ាងណា?
៤. តើអ្នកគិតថាទង្វើរនោះប៉ះពាល់ដល់ទំនាក់ទំនងរវាងចាន់ និងសុខាយ៉ាងណា?
៥. តើអ្នកគិតថាទង្វើរនោះប៉ះពាល់ដល់កូនៗយ៉ាងណាដែរ?
៦. តើអ្នកគិតថាទង្វើរនេះបង្រៀនកូនៗអ្វីខ្លះអំពីទំនាក់ទំនងរវាងបុរស និងស្ត្រី?

## សេណារីយ៉ូសម្រាប់ដៃគូភេទដូចគ្នា៖

**គីម និងលា** គឺជាដៃគូដែលពួកគេបានជួបគ្នានៅពេលធ្វើការនៅបារមួយកន្លែង។ ពួកគេទាំងពីរបាននិយាយអំពីបញ្ហា និងការរើសអើងដែលពួកគេបានជួបប្រទះដោយសារតែអត្តសញ្ញាណយេនឌ័ររបស់ពួកគេ។ យូរៗទៅទំនាក់ទំនងពួកគេបានកាន់តែជិតស្និទ្ធនឹងគ្នា។ លាបានផ្លាស់ទៅផ្ទះរបស់គីម។ ពីដំបូងពួកគេទាំងពីរស្រឡាញ់គ្នា និងយកចិត្តទុកដាក់គ្នាទៅវិញទៅមក។ គីមសម្គាល់ឃើញថាលា ផឹកស្រាច្រើនរាល់ពេល ទោះបីគាត់មិនបានផឹកនៅមុខគីម ប៉ុន្តែគីមអាចដឹងដោយសារក្លិនស្រា។ នៅពេលដែលគីមកំពុងសម្អាតទូផ្ទះបាយ គីមបានឃើញដបស្រាទទេ។ លា តែងតែដាច់ម៉ៃដោយសារចំណាយលុយច្រើនលើគ្រឿងស្រវឹង។ គីម ធ្វើកិច្ចការផ្ទះ និងការចំណាយទាំងអស់លើអាហារ និងសម្ភារៈចាំបាច់។ លាស្រឡាញ់គីមណាស់ ប៉ុន្តែមិនខ្វល់ច្រើនចំពោះការចែករំលែកការចំណាយក្នុងគ្រួសារ ឬបន្ទុកការងារផ្ទះជាមួយគីមនោះទេ។ លាមកដល់ផ្ទះយប់ជ្រៅទាំងស្រវឹង ហើយដាស់គីមឱ្យទៅផឹកជាមួយ គីមបានបដិសេធ តែលាព្យាយាមបង្ខំ តែគីមថាគាត់គ្មានអារម្មណ៍ផឹកជាមួយទេ។ លាចាប់ផ្តើមស្រែកដាក់គីម ហើយគីមមិនដឹងពីបុគ្គលិកលក្ខណៈរបស់លាបែបនេះទេកន្លងមក។ គីមរន្ធត់ និងឈឺចាប់ ហើយគាត់បានចូលទៅក្នុងបន្ទប់ ហើយចាក់សោរបន្ទប់នៅតែម្នាក់ឯង។

នៅព្រឹកបន្ទាប់ គីមបានសម្រេចចិត្តប្រឈមមុខជាមួយលា អំពីអ្វីគ្រប់យ៉ាងដែលគីមកត់សម្គាល់ និងមានអារម្មណ៍កន្លងមក។ លាបានបញ្ចេញប្រតិកម្មយ៉ាងចាស់ដៃហើយអ្នកទាំងពីរបានចាប់ផ្តើមឈ្លោះគ្នារហូត លាវាយដំលើគីមចំមុខ និងវាយយ៉ាងធ្ងន់ធ្ងរ។ គីមត្រូវរងគ្រោះ និងមានអារម្មណ៍ថាត្រូវបានក្បត់ដោយអាកប្បកិរិយាដ៏ឃោរឃៅរបស់លា ដែលជាអ្នកបានសន្យាតាំងពីដំបូង។

**សំណួរពិភាក្សា៖**
១. តើអ្នកគិតថានេះជាអំពើហិង្សាប្រភេទអ្វី?
២. តើអ្នកគិតថាទង្វើរនេះប៉ះពាល់ដល់គីមយ៉ាងដូចម្តេច?
៣. តើអ្នកគិតថាវាធ្វើឱ្យគីមមានអារម្មណ៍យ៉ាងណា?
៤.តើអ្នកគិតថាប៉ះពាល់ដល់ទំនាក់ទំនងរវាងគីម និងលាយ៉ាងណាដែរ?
៥. តើគីម គួរធ្វើអ្វី?

**កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល៖**
វាអាចជាឧបសគ្គសម្រាប់អ្នកចូលរួម ដើម្បីគិតអំពីផលវិបាកពីមួយថ្ងៃទៅមួយថ្ងៃ នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលកើតមានឡើងក្នុងជីវិតរស់នៅប្រចាំថ្ងៃ និងក្នុងជិវិតដៃគូដែលអំពើហិង្សាទម្រង់ស្រាល។ អ្នកចូលរួមនឹងផ្តោតទៅលើទម្រង់ធ្ងន់ធ្ងរ នៃអំពើហិង្សា និងសង្ខេបតែផលវិបាកធ្ងន់ធ្ងរ ឧទាហរណ៍៖ ធ្វើអត្តឃាត លែងលះ ឈប់រៀន។ វាជាការសំខាន់ណាស់ក្នុងការជួយអ្នកចូលរួមឱ្យផ្សាភ្ជាប់ជាមួយបញ្ហានេះដោយផ្ទាល់ និងសួរប្រដេញតាមរបៀបដែលជួយឱ្យពួកគេកត់សម្គាល់ផលប៉ះពាល់ផ្លូវចិត្តនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងរបៀបដែលទង្វើនោះរារាំងទំនាក់ទំនងល្អក្នុងគ្រួសារ និងក្នុងសហគមន៍។

## សកម្មភាព ៣គ៖ “ភពផែនដីថ្មី” The New Planet

**វត្ថុបំណង៖** ពង្រឹងការយល់ដឹងរបស់អ្នកចូលរួម អំពី **«អំណាចគ្រប់លើ»** ដែលជាឫសគល់នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

**ថេរវេលា៖** ៦០ នាទី
**វិធីសាស្ត្រ៖** ធ្វើការលក្ខណៈបុគ្គល ចែករំលែកជាក្រុម
**សម្ភារៈ និងការរៀបចំ៖** កូពី ហើយកាត់កាតសិទ្ធិ ដែលមានចំនួន ៣០កាត និងកាតជីវិតចំនួន ១៥កាត។ រៀបចំស្កុតក្រដាសចំនួន ៣០ចំណែក។ ដាក់កាតសិទ្ធិ និងកាតជីវិតជាផ្នែកផ្សេងៗគ្នាសម្រាប់ប្រភេទនៃកាតនៅលើតុ នៅកន្លែងណាមួយក្នុងបន្ទប់។ ផ្កាប់កាត ដើម្បីកុំឱ្យអ្នកចូលរួមឃើញអ្វីដែលបានសរសេរ។

**អ្វីគួរធ្វើ និងមិនអ្វីគួរធ្វើ៖** ណែនាំអ្នកចូលរួមអោយបានច្បាស់លាស់ និងទុកកន្លែងឱ្យពួកគេអាចផ្លាស់ទីបាន និងយល់ពីផលប៉ះពាល់ពិតប្រាកដ នៃ**អំណាចដែលគ្រប់លើ** ដែលបង្កើនហានីភ័យទៅលើសិទ្ធិ និងបង្កើតភាពដែលងាយរងគ្រោះនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ផ្តល់ឱកាសឱ្យអ្នកចូលរួមចែករំលែកអារម្មណ៍របស់ពួកគេដោយផ្តល់យោបល់បន្តិចបន្តួច ទៅកាន់អ្នកសម្របសម្រួល។

## ការណែនាំសម្រាប់អ្នកសម្របសម្រួល៖

**ជំហានទី១៖** ពន្យល់អ្នកចូលរួមថា «នៅក្នុងលំហាត់នេះ ពួកយើងនឹងក្លាយទៅជាប្រជាជននៃពិភពថ្មីមួយ។ នៅលើភពមួយនេះ ពួកយើងធ្វើសកម្មភាពតែមួយដដែលៗគ្រប់ពេល។ ស្វាគមន៍គ្នា ហើយពួកយើងស្តាប់ និងធ្វើតាមច្បាប់នៃដែនដីនេះយ៉ាងម៉ឺងម៉ាត់។»

**ជំហានទី២៖** ពន្យល់ថា «អ្នកនឹងដើរជុំវិញបន្ទប់ ហើយណែនាំខ្លួនទៅអ្នកគ្រប់គ្នាម្តងម្នាក់។ គ្រប់ពេលដែលអ្នកជួបនរណាម្នាក់ជាលើកទី២ ឬទី៣ អ្នកគួរតែផ្តល់ព័ត៌មានថ្មីៗអំពីខ្លួនអ្នក (ឧទាហរណ៍៖ តើអ្នករស់នៅឯណា តើអ្នកមានកូនទេ...ជាដើម)។ សម្រាប់ការណែនាំខ្លួននេះ អ្នកគួរតែប្រើប្រាស់ព័ត៌មានពិត។

**ជំហានទី៣៖** ឱ្យអ្នកចូលរួមឈរ និងចាប់ផ្តើមផ្លាស់ទី និងណែនាំខ្លួនទៅវិញទៅមក។ នៅពេលពួកគេកំពុងធ្វើបែបនេះ បើកកាតសិទ្ធិទាំង៤។

**ជំហានទី៤៖** បន្ទាប់ពីការណែនាំខ្លួនរយៈពេល ២នាទី អ្នកសម្របសម្រួលនិយាយថា «ឈប់» ហើយពន្យល់ថា «នៅលើភពថ្មីនេះ មានច្បាប់ពិសេស ហើយមនុស្សនៅទីនេះនឹងធ្វើអ្វីដែលច្បាប់បាននិយាយ។ ខ្ញុំនឹងអានច្បាប់ចំនួន៣ដំបូងគេនៅលើភពនេះ។»

**ច្បាប់ទី១៖** ស្វាគមន៍ប្រជាជនដ៏ខ្ពង់ខ្ពស់នៃភពថ្មីរបស់យើង។ អ្នកគឺជាមនុស្សនៃភពដែល រីករាយ រួសរាយ តែងតែចង់ជួបជាមួយមនុស្សថ្មីៗ តែងតែត្រៀមរួចជាស្រេចក្នុងការប្រាប់អ្នកផ្សេងទៀតអំពីខ្លួនរបស់អ្នក។ ជាប្រជាជននៃភពនេះ ម្នាក់ៗមានសិទ្ធិ ចំនួន៤៖

- **ទី១៖** អ្នកមានសិទ្ធិចំពោះសុវត្ថិភាពនៃរូបរាងកាយ ដែលការពារអ្នកពីការឈឺចាប់លើរាងកាយ។ អ្នកនឹងទទួលកាតនេះម្នាក់មួយដែលបង្ហាញពីសិទ្ធិទៅលើសុវត្ថិភាពរូបរាងកាយរបស់អ្នក។ (បង្ហាញកាតសម្រាប់ «សុវត្ថិភាពរូបរាងកាយ» ទៅកាន់ក្រុម។)
- **ទី២៖** អ្នកមានសិទ្ធិទទួលបានការគោរពពីអ្នកដទៃ ដែលសិទ្ធិនេះជួយការពារអ្នកពីការធ្វើបាប និងរើសអើងរបស់អ្នកដទៃ។ អ្នកនឹងទទួលបានកាតម្នាក់១ តំណាងឱ្យសិទ្ធិរបស់អ្នកដែលទទួលបានការគោរពពីអ្នកដទៃ។ (បង្ហាញកាត «ការគោរពពីអ្នកដទៃ» ទៅកាន់ក្រុម។)
- **ទី៣៖** អ្នកមានសិទ្ធិទទួលបានឱកាសធ្វើការសម្រេចចិត្តដោយខ្លួនឯង ដែលការពារអ្នកពីមនុស្សដែលរារាំងអ្នកពីការមានលុយ ឬទ្រព្យសម្បត្តិ ឬការទទួលបានព័ត៌មាន។ អ្នកនឹងទទួលបានកាត នេះ ដែលតំណាងឱ្យសិទ្ធិរបស់អ្នកក្នុងការទទួលបានឱកាសដើម្បីធ្វើការសម្រេចចិត្តដោយខ្លួនឯង។ (បង្ហាញកាត «ឱកាសដើម្បីធ្វើការសម្រេចចិត្តដោយខ្លួនឯង» ទៅកាន់ក្រុម។ )
- **ទី៤៖** អ្នកមានសិទ្ធិគ្រប់គ្រងលើរាងកាយរបស់អ្នក ដែលការពារអ្នកពីមនុស្សដែលបង្ខំអ្នកក្នុងការរៀបការ ការរួមភេទ ការជួញដូរផ្លូវភេទ ឬប្រភេទនៃសកម្មភាពផ្លូវភេទដែលមិនចង់បាន។ អ្នកនឹងទទួលបានកាតនេះម្នាក់មួយ ដែលតំណាងឱ្យសិទ្ធិរបស់អ្នកក្នុងការគ្រប់គ្រងលើផ្លូវភេទរបស់អ្នក។ (បង្ហាញកាត «ការគ្រប់គ្រងផ្លូវភេទរបស់អ្នក» ទៅដល់ក្រុម។) សូមមកប្រមូលសន្លឹកកាតរបស់អ្នក (កាត១សម្រាប់សិទ្ធិនីមួយៗ) ហើយបន្តការស្វាគមន៍គ្នាទៅវិញទៅមក។

**ជំហានទី៥៖**ខណៈពេលដែលអ្នកចូលរួមបន្តស្វាគមន៍គ្នាទៅវិញទៅមក សូមបង្វេរសន្លឹកកាតទាំង២នៃសងខាងនៅជាប់នឹងស្អុតដែលបានរៀបចំរួច។

**ជំហានទី៦៖** បន្ទាប់ពីរយៈពេល ៣នាទី សូមនិយាយថា “ឈប់!” ហើយឱ្យអ្នកចូលរួមប្រមូលអារម្មណ៍មកក្រុមធំវិញ។

**ជំហានទី៧៖**ពន្យល់ថាឥឡូវនេះដល់ពេលដែលត្រូវអានច្បាប់ទី២ហើយ។

**ច្បាប់ទី២៖**ជូនចំពោះដល់ប្រជាពលរដ្ឋដ៏ថ្លៃថ្នូរទាំងអស់នៃភពថ្មីរបស់យើង។ ចំនួនប្រជាជនទាំងមូលនៃភពផែនដីរបស់យើងឥឡូវនេះនឹងត្រូវបែងចែកជាពីរផ្នែក។ ចំនួនពាក់កណ្តាលនៃអ្នកទាំងអស់គ្នានឹងក្លាយជា "ការ៉េ" ហើយពាក់កណ្តាលទៀតនឹងក្លាយជា "រង្វង់"។ អ្នកនឹងជ្រើសរើសកាតតំណាងឱ្យក្រុមមួយក្នុងចំណោមក្រុមទាំងនេះ។ វាត្រូវបានគេហៅថា កាតជីវិតរបស់អ្នក។ អ្នកត្រូវតែមាន កាតជីវិត ដើម្បីរស់នៅលើភពថ្មីនេះ។ សូមប្រមូលកាតមួយ ហើយបិទវានៅលើទ្រូងរបស់អ្នក។ បន្ទាប់មកបន្តស្វាគមន៍គ្នាទៅវិញទៅមក។

**ជំហានទី៨៖**បន្ទាប់ពីរយៈពេល ៣នាទី សូមបញ្ឈប់អ្នកចូលរួម ហើយអានច្បាប់ចុងក្រោយ។

**ច្បាប់ទីបី៖** ជូនចំពោះពលរដ្ឋដ៏ថ្លៃថ្នូរទាំងអស់នៃភពថ្មីរបស់យើង។ ពេលវេលាបានផ្លាស់ប្តូរ។ ឥឡូវនេះ យើងប្រកាសជាផ្លូវការថា រង្វង់មានអំណាចច្រើនជាងការ៉េ។ ប្រសិនបើខ្ញុំទះដៃ (បន្លឺកណ្តឹង ឬផ្លុំកញ្ចែ) ខណៈពេលដែលរង្វង់ និងការ៉េកំពុងស្វាគមន៍គ្នាទៅវិញទៅមក នោះរង្វង់អាចយកសិទ្ធិមួយក្នុងចំណោមសិទ្ធិទាំងបួនរបស់ការ៉េ។ ប្រសិនបើការ៉េមិនមានសិទ្ធិទៀតទេ រង្វង់អាចយក កាតជីវិតរបស់ការ៉េបាន។ ប្រសិនបើការ៉េបាត់បង់កាតជីវិតរបស់គាត់ គាត់ត្រូវតែឈរនៅមួយកន្លែងរហូតដល់ពេលល្បែងត្រូវបានបញ្ចប់។ ទោះបីជាការ៉េដឹងពីហានិភ័យនេះក៏ដោយ ក៏ពួកគេត្រូវតែបន្តស្វាគមន៍រង្វង់។ សូមបន្តស្វាគមន៍គ្នាទៅវិញទៅមក។

**ជំហានទី៩៖** ទះដៃជាទៀងទាត់ (បន្លឺកណ្តឹង ឬផ្លុំកញ្ចែ)។ នៅពេលដែលអ្នកចូលរួមចំនួនមួយភាគបីកំពុងឈរនៅមួយកន្លែង បញ្ចប់ល្បែងដោយស្រែកថា "ឈប់!" ហើយពន្យល់ថា អរិយធម៌ថ្មី នឹងត្រូវផ្អាក ដើម្បីធ្វើការពិភាក្សាគ្នាសិន។

**ជំហានទី១០៖** ឱ្យក្រុមអង្គុយជារង្វង់ធំមួយ ដើម្បីសង្ខេបពីលំហាត់។

**ជំហានទី១១៖** ពិភាក្សាអំពីបទពិសោធន៍នៃការរស់នៅលើភពថ្មី ដោយប្រើសំណួរខាងក្រោម៖

ក.តើអ្នកមានអារម្មណ៍យ៉ាងណាពេលអ្នកបានទទួលសិទ្ធិទាំងបួនរបស់អ្នក?

ខ.តើអ្នកមានអារម្មណ៍យ៉ាងណាពេលដែលអ្នកត្រូវបានបែងចែកជារង្វង់ និងការ៉េ?

គ.ការ៉េ តើអ្នកមានអារម្មណ៍យ៉ាងណា នៅពេលដែលរង្វង់ត្រូវបានគេផ្តល់អំណាចឱ្យច្រើនជាង? តើអ្នកមានអារម្មណ៍យ៉ាងណាពេលដែលមានហានិភ័យ ដែលសិទ្ធិរបស់អ្នកត្រូវបានគេយកនៅពេលណាមួយ? តើវាប៉ះពាល់ដល់ឥរិយាបថរបស់អ្នកយ៉ាងណា?

ឃ.រង្វង់ តើពេលដែលអ្នកមានអំណាចច្រើនជាងគេបំផុត តើអ្នកយល់ឃើញយ៉ាងម៉េចដែរ?

**ជំហានទី១២៖** គូរការប្រៀបធៀបរវាង ភពថ្មី និងជីវិតនៅក្នុងសហគមន៍របស់យើង ដូចខាងក្រោម៖

**ក. សួរអ្នកចូលរួម៖**

i. តើមនុស្សគ្រប់រូបមានសិទ្ធិទទួលបានវត្ថុ៤យ៉ាងដូចគ្នាឬទេ? (ចាស ឬបាទ!)

ii. តើសហគមន៍របស់យើងត្រូវបានបែងចែកជា «ចំណាត់ថ្នាក់» មនុស្សខុសគ្នាដោយរបៀបណា? (សូមប្រាកដថា «ស្ត្រី និងបុរស» មានឱកាសឆ្លើយតប។)

iii. តើមានអ្វីកើតឡើងនៅពេលដែលសង្គមមួយផ្តល់អំណាចទៅឱ្យក្រុមមួយច្រើនជាងក្រុមមួយទៀត?

iv. ពេលសង្គមផ្តល់អំណាចដល់មនុស្សមួយចំនួនច្រើនជាង តើវាជាការស្មើភាព ឬយុត្តិធម៌ឬទេ? (ទេ)

v. ជាធម្មតា តើអ្នកណាដែលត្រូវបានគេផ្តល់អំណាចច្រើនជាងនៅក្នុងសហគមន៍របស់យើង? (ឧទាហរណ៍៖ បុរស ស្ត្រី ...។ល។)

vi. តើមនុស្សមួយចំនួនប្រើអំណាចនេះ ដោយមិនគោរពសិទ្ធិអ្នកដទៃដែរឬទេ?

vii. តើអតុល្យភាពនៃអំណាចរវាងស្ត្រី និងបុរសកម្រិតជីវិតស្ត្រីក្នុងពិភពលោកដោយរបៀបណា (ឧទាហរណ៍៖ ជម្រើស និងចលនារបស់ពួកគេក្នុងសង្គម)?

**ខ. ពន្យល់៖**

**i.** នៅពេលដែលមានអតុល្យភាពនៃអំណាចរវាងស្ត្រី និងបុរស យើងនិយាយថាបុរសកំពុងប្រើអំណាចមកលើស្ត្រី។ អតុល្យភាពនៃអំណាចនេះកើតមានដោយសារតែសមាជិកសហគមន៍មិនដឹងខ្លួន ហើយទទួលយកវា ឬគ្រាន់តែនៅស្ងៀមស្ងាត់។ នេះគឺជាមូលហេតុនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ។

**ii.** ដើម្បីផ្លាស់ប្តូរស្ថានភាពនេះ យើងត្រូវចាប់ផ្តើមការផ្លាស់ប្តូរចេញពីខ្លួនយើង។

**ជំហានទី១៣៖** សេចក្តីសន្និដ្ឋាន៖ បញ្ចប់វគ្គ ហើយពន្យល់ថាអ្នកគ្រប់គ្នាមានសិទ្ធិនៅក្នុងបន្ទប់នេះ។ យើងទាំងអស់គ្នាគោរពសិទ្ធិគ្នាទៅវិញទៅមក។ មិនមានរង្វង់ និងការ៉េទៀតទេ។ យើងទាំងអស់គ្នាមានសិទ្ធិស្មើគ្នាទៅនឹងអ្វីដែលយើងធ្លាប់មាន។ សុំឱ្យអ្នកចូលរួមចែកចាយកាតសិទ្ធិឡើងវិញ រហូតទាល់តែអ្នកគ្រប់គ្នាមានកាតសិទ្ធិគ្រប់គ្នាដូចដើម។

# វគ្គទី៣៖ វិធីសាស្ត្រផ្លាស់ប្រែយេនឌ័រ ដើម្បីដោះស្រាយ អំពើហិង្សាទាក់ទងនឹងយេនឌ័រ

## ក្របខ័ណ្ឌសមភាពយេនឌ័រ

**វត្ថុបំណង៖** ដើម្បីដោះស្រាយ អំពើហិង្សាទាក់ទងនឹងយេនឌ័រ តាមរយៈវិធីសាស្ត្រផ្លាស់ប្រែយេនឌ័រ ដោយធ្វើការផ្តោតលើ ភ្នាក់ងារ ទំនាក់ទំនង និងរចនាសម្ព័ន្ធ។
**ថេរវេលា៖** ៤៥ នាទី។
**វិធីសាស្ត្រ៖** ការវិភាគជាក្រុម អំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ក្នុងបណ្តុំនៃការផ្លាស់ប្តូរ និងការពិភាក្សា។
**សម្ភារៈ និងការរៀបចំ៖** ក្រដាសផ្ទាំងធំចំនួន៣ផ្ទាំង និងហ្វឺតសម្រាប់ក្រុមនីមួយៗ។

**ការណែនាំអ្នកសម្របសម្រួល**
**ជំហានទី១៖** ជូនដំណឹងដល់អ្នកចូលរួមថា ដើម្បីសម្រេចបាននូវការផ្លាស់ប្តូរយូរអង្វែង និងបញ្ឈប់អំពើហិង្សាទាក់ទងនឹងយេនឌ័រយើងគួរតែនិយាយអំពីបណ្តុំនៃការផ្លាស់ប្តូរចំនួនបី។ អង្គការយែរ ជ្រើសរើសយកទ្រឹស្តីនៃការផ្លាស់ប្តូរស្តីពីសមភាពយេនឌ័រជាមួយនឹងបណ្តុំនៃការផ្លាស់ប្តូរចំនួនបី។ អង្គការផ្សេងៗ អាចមានក្របខ័ណ្ឌផ្ទាល់ខ្លួនសម្រាប់ការផ្លាស់ប្តូររយៈពេលវែងរបស់ពួកគេ។

**ភ្នាក់ងារ៖** ការទទួលបានទំនុកចិត្ត ការកសាងស្មារតី និងភ្នាក់ងារសម្រាប់បុរស ស្ត្រី និង ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ដើម្បីស្វែងរកសិទ្ធិរបស់ពួកគេ និងអភិវឌ្ឍជំនាញ ឬជំនាញអន្តរបុគ្គលដែលត្រូវការ ក្នុងការចូលរួមសម្រេចចិត្តក្នុងគ្រួសារ និងកិច្ចសន្ទនាអភិបាលកិច្ច នៅកម្រិតសហគមន៍ក្នុងការទប់ស្កាត់នឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

**ទំនាក់ទំនង៖** វាជាអំណាចក្នុងការផ្លាស់ប្តូរទំនាក់ទំនងអំណាចមិនស្មើភាព ដូច្នេះការងារដែលផ្តោតអំពើហិង្សាទាក់ទងនឹងយេនឌ័រ មិនគ្រាន់តែជាការឆ្លើយតបផ្នែកបច្ចេកទេសប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការឆ្លើយតបដែលមានលក្ខណៈប្រមូលផ្តុំ ការចូលរួមពីតួអង្គនយោបាយ បណ្តាញអង្គការសង្គមស៊ីវិល និងគាំទ្រដល់អង្គការស្ត្រីដែលធ្វើការលើបញ្ហាអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

**រចនាសម្ព័ន្ធ៖** ការតទល់នឹងបទដ្ឋានយេនឌ័រ ទំនៀមទម្លាប់ដែលជំរុញវិសមភាព និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ការអនុវត្តច្បាប់ គោលនយោបាយ និងនីតិវិធី និងសេវាការពារ និងឆ្លើយតបទៅនឹង អំពើហិង្សាទាក់ទងនឹងយេនឌ័រ។

ការផ្លាស់ប្រែ មានន័យថាការដោះស្រាយឫសគល់នៃរចនាសម្ព័ន្ធក៏ដូចជាឫសគល់បញ្ហាដែលបង្កអំពើហិង្សាទាក់ទងនឹងយេនឌ័រ ជាមួយនឹងគោលបំណងសម្រេចឱ្យបាន នូវការផ្លាស់ប្តូរដ៏យូរអង្វែងនៅក្នុងអំណាច និងជម្រើសដែលអ្នករស់រានមានជីវិតមាន ជាជាងគ្រាន់តែជាការបង្កើននូវឱកាសបណ្តោះអាសន្ន។

តួរលេខខាងក្រោមបង្ហាញពីកម្រិតផ្សេងៗគ្នានៃការរួមបញ្ចូលយេនឌ័រ ជាមួយនឹងការបន្តក្នុងដំណាក់កាលនីមួយៗ។ ការបន្តនេះនឹងជួយក្រុមគម្រោង ឬកម្មវិធីជាមួយនឹងការវាយតម្លៃលើសកម្មភាពអន្តរាគមន៍របស់ពួកគេ ហើយថែមទាំងផ្តល់នូវទិសដៅអំពីរបៀបដែលពួកគេអាចធ្វើឱ្យប្រសើរឡើងនូវអន្តរាគមន៍ ឬសកម្មភាពរបស់ពួកគេ ដើម្បីធ្វើឱ្យពួកគេកាន់តែទទួលបានយេនឌ័រដែលមានលក្ខណៈផ្លាស់ប្រែ (Gender Transformative) ក្នុងការដោះស្រាយ អំពើហិង្សាទាក់ទងនឹងយេនឌ័រ។

| យេនឌ័រដែលមានលក្ខណៈ ធ្វើឱ្យឈឺចាប់ ឬមិនអើពើ (Gender Harmful/ Unaware) | យេនឌ័រដែលមានលក្ខណៈ អព្យាក្រឹត្យ (Gender Neutral) | យេនឌ័រដែលមានលក្ខណៈធ្វើឱ្យ រសើប (Gender Sensitive) | យេនឌ័រដែលមានលក្ខណៈ ឆ្លើយតប (Gender Responsive) | យេនឌ័រដែលមាន លក្ខណៈផ្លាស់ប្រែ (Gender Transformative) |
|---|---|---|---|---|
| វិធសាស្រ្ត គម្រោង ឬកម្មវិធីដែលពង្រឹងភាពមិនស្មើនៃយេនឌ័រ ឬមិនផ្តល់សិទ្ធិអំណាចដល់ក្រុមមនុស្សមួយចំនួនក្នុងដំណើរការអនុវត្ត និងសម្រេចបាននូវគោលដៅគម្រោង ឬកម្មវិធី។ | វិធីសាស្រ្តគម្រោង កម្មវិធី សកម្មភាព ដែលដឹងពីបញ្ហា និងឧបសគ្គនៅក្នុងសហគមន៍ ប៉ុន្តែសកម្មភាពមិនដោះស្រាយយ៉ាងសកម្មនូវភាពលំអៀងយេនឌ័រ និងការរើសអើងដែលកើតឡើងនោះទេ។ | វិធីសាស្រ្ត ឬកម្មវិធី ឬសកម្មភាព ដែលទទួលស្គាល់បញ្ហា និងឧបសគ្គ ហើយដោះស្រាយបញ្ហា និងឆ្លើយតប ទៅនឹងតម្រូវការរបស់បុគ្គល ឬក្រុម។ អន្តរាគមន៍របស់គម្រោង ឬកម្មវិធីមានគោលបំណងធ្វើអោយប្រសើរឡើងនូវលទ្ធភាពទទួលបានសេវា ប៉ុន្តែពួកគេខ្លួនឯងធ្វើសកម្មភាពតិចតួចដើម្បីផ្លាស់ប្តូរបញ្ហាបរិបទធំៗដែលជាឫសគល់នៃវិសមភាពយេនឌ័រ។ មិនមានភាពគ្រប់គ្រាន់ដើម្បីផ្លាស់ប្តូរតុល្យភាពនៃអំណាចនៅក្នុងទំនាក់ទំនងយេនឌ័រ និងភាពចម្រុះនៃទំនាក់ទំនងនោះ។ | វិធីសាស្រ្ត ឬកម្មវិធី ឬសកម្មភាព ដែលទទួលស្គាល់បញ្ហា និងឧបសគ្គ។ សកម្មភាពគាំទ្រ និងជួយស្រ្តី បុរស ជនមានពិការភាព ក្រុមជនជាតិដើម និងភាពចម្រុះយេនឌ័រ ពិនិត្យមើលការរំពឹងទុកយេនឌ័រក្នុងសង្គម ភាពលំអៀងយេនឌ័រ និងផលប៉ះពាល់របស់ពួកគេលើតួនាទី សិទ្ធិ និងទំនាក់ទំនងរបស់ស្រ្តី បុរស និងក្រុមជនក្រីក្រ។ | វិធីសាស្រ្ត ឬសកម្មភាពរបស់គម្រោង ឬកម្មវិធីដែលទទួលស្គាល់បញ្ហា និងឧបសគ្គ ដោះស្រាយបញ្ហា យ៉ាងសកម្ម និងកសាងបទដ្ឋានសង្គមប្រកបដោយសមធម៌ រចនាសម្ព័ន្ធ និងទំនាក់ទំនងបុគ្គល ឬក្រុម ឥរិយាបថនិងអាកប្បកិរិយាប្រកបដោយសមធម៌ យេនឌ័រ។ |

**ជំហានទី២៖** បែងចែកអ្នកចូលរួមជា ៣ក្រុម។ សុំឱ្យពួកគេវិភាគទម្រង់ទូទៅនៃ អំពើហិង្សាទាក់ទងនឹងយេនឌ័រ (អំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ អាពាហ៍ពិពាហ៍វ័យក្មេង និងអាពាហ៍ពិពាហ៍ដោយបង្ខំ) នៅក្នុងបរិបទប្រទេសកម្ពុជា។ ចែកកាតតូចៗចំនួន ៣ ផ្សេងគ្នាដល់ក្រុមនីមួយៗ។

**ជំហានទី៣៖** ប្រគល់ក្រដាសផ្ទាំងធំមួយដល់ក្រុមនីមួយៗ ហើយសុំឱ្យពួកគេគូរត្រីកោណដែលមាន អ្នកតំណាងម្នាក់សរសេរនៅខាងលើ ពីទំនាក់ទំនងនៅជ្រុងខាងស្តាំ និងរចនាសម្ព័ន្ធនៅខាងឆ្វេង។ សុំឱ្យពួកគេចែករំលែកនៅក្នុងក្រុមអំពី ការគំរាមកំហែង បញ្ហាប្រឈមចំពោះភ្នាក់ងារ ទំនាក់ទំនង និងរចនាសម្ព័ន្ធដោយសារតែអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅខាងក្នុងត្រីកោណ។

**ជំហានទី៤៖** ក្រុមនីមួយៗពិភាក្សាគ្នារយៈពេល ១០នាទី ទៅលើផលប៉ះពាល់នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រលើបណ្តុំនៃការផ្លាស់ប្តូរចំនួន ៣ដោយប្រើប្រាស់កាតតូចៗពណ៌បៃតងសម្រាប់ភ្នាក់ងារ ពណ៌ផ្កាឈូកសម្រាប់ទំនាក់ទំនង និងពណ៌លឿងសម្រាប់រចនាសម្ព័ន្ធ។

**ជំហានទី៥៖** បន្ទាប់ពីរយៈពេល ១០នាទី សុំឱ្យក្រុមសរសេរនៅខាងក្រៅត្រីកោណនូវអ្វីដែលពួកគេចង់ផ្លាស់ប្តូរនៅក្នុងបណ្តុំនៃការផ្លាស់ប្តូរទាំង៣។

**ជំហានទី៦៖** បន្ទាប់ពីធ្វើការងារជាក្រុម សុំឱ្យក្រុមដាក់បញ្ឈរតារាងដែលពួកគេបានធ្វើរួច ហើយអញ្ជើញក្រុមនីមួយៗឱ្យធ្វើបទបង្ហាញ។

**ជំហានទី៧៖** ឱ្យអ្នកស្ម័គ្រចិត្តភ្ជាប់កាតដែលពួកគេបានពិភាក្សារួចដែលមានអត្ថន័យស្រដៀងគ្នានៅក្នុងបណ្តុំនីមួយៗ ហើយចាប់ផ្តើមពិភាក្សាអំពីចំណាប់អារម្មណ៍ដែលពួកគេបានពិភាក្សា និងគិតអំពីបណ្តុំនៃការផ្លាស់ប្តូរនីមួយៗ និងនិយាយអំពីការផ្លាស់ប្តូរ។

**ជំហានទី៨៖** សេចក្តីសន្និដ្ឋានៈជូនដំណឹងដល់អ្នកចូលរួមថាគំនិត និងយោបល់របស់ពួកគេមានតម្លៃ។ ហើយទាំងអស់នោះគួរតែយកទៅអនុវត្ត។ ដូច្នេះហើយ យើងនឹងធ្វើផែនការសកម្មភាពរួមគ្នា ដើម្បីប្រាកដថាយើងទាំងអស់គ្នាអាចឈានដល់ និងអនុវត្តវង្វង់នៃសុភមង្គល និងសុខុមាលភាពដែលយើងបានជ្រើសរើស។ បន្តទៅសកម្មភាពបន្ទាប់។

## ចក្តទី៤៖ យន្តការគាំទ្រផ្លូវការ និងក្រៅផ្លូវការ ចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ

### សកម្មភាព ៤គ៖ យន្តការផ្លូវការ និងក្រៅផ្លូវការចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ

**វត្ថុបំណង៖** ដើម្បីស្វែងរកដំណោះស្រាយរួមមួយ ក្នុងការដោះស្រាយអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងយន្តការគាំទ្រផ្លូវការ និងក្រៅផ្លូវការ។

**ថេរវេលា៖** ៤៥ នាទី។

**វិធីសាស្រ្ត៖** ការងារជាក្រុម ការបង្ហាញ និងការពិភាក្សា

**សម្ភារៈ៖** ក្រដាសផ្ទាំងធំ និងហ្វឺត

**អ្វីគួរធ្វើ និងអ្វីមិនគួរធ្វើ៖** សម្របសម្រួលដើម្បីឆ្លុះបញ្ចាំងពីយន្តការដែលមានស្រាប់ និងគាំទ្រពួកគេក្នុងការកំណត់អត្តសញ្ញាណដោយមិនផ្តល់យោបល់លើអ្វីដែលអ្នកគិតថាមានប្រសិទ្ធភាព ឬគ្មានប្រសិទ្ធភាព។ ទុកឱ្យអ្នកចូលរួមចែករំលែកអ្វីដែលអាចដំណើរការបានល្អបំផុត និងអ្វីដែលជាបញ្ហាប្រឈមនៅក្នុងបរិបទរបស់ពួកគេ។

## ការណែនាំសម្រាប់អ្នកសម្របសម្រួលៈ

**ជំហានទី១៖** បែងចែកអ្នកចូលរួមជា ២ ក្រុមដើម្បីពិភាក្សា៖

ក) តើយន្តការគាំទ្រផ្លូវការ និងក្រៅផ្លូវការដើម្បីដោះស្រាយ អំពើហិង្សាទាក់ទងនឹងយេនឌ័រ មានអ្វីខ្លះ?

**ឧទាហរណ៍៖** យន្តការគាំទ្រផ្លូវការអាចរួមបញ្ចូលច្បាប់ ឬគោលនយោបាយដើម្បីដោះស្រាយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដូចជា៖ ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា លិខិតតូបករណ៍អន្តរជាតិអំពីសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ក៏ដូចជារដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា។ សូមមើលចំនុចខាងក្រោមជាឯកសារយោង (នៅចុងបញ្ចប់នៃបទបង្ហាញរបស់ក្រុមសូមចែករំលែកឃ្លាសំខាន់ៗនៅក្នុងបទបង្ហាញ)។

ខ) តើអ្វីជាឧបសគ្គក្នុងការទទួលបានសេវាឆ្លើយតបដែលមានស្រាប់?

**ជំហានទី២៖** ក្រុមទី១នឹងពិភាក្សាអំពីយន្តការគាំទ្រផ្លូវការដែលមាន ហើយឧបសគ្គក្នុងការទទួលបានការគាំទ្រ ឬការរាយការណ៍ករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រហើយក្រុមទី២នឹងពិភាក្សាអំពីយន្តការគាំទ្រក្រៅផ្លូវការ និងឧបសគ្គក្នុងការទទួលបានការគាំទ្រ ឬការរាយការណ៍។

**ជំហានទី៣៖** ផ្តល់រយៈពេល ៣០នាទីឱ្យក្រុម បន្ទាប់ពីនោះសុំឱ្យក្រុមនីមួយៗចែករំលែកបទបង្ហាញរបស់ពួកគេ។ លើកទឹកចិត្តឱ្យសួរសំណួរ ឬផ្តល់យោបល់។ សួរអ្នកចូលរួមប្រសិនបើពួកគេចង់បន្ថែមព័ត៌មានខ្លះទៀត។ ផ្តល់ពេល ១៥នាទីសម្រាប់ការពិភាក្សា។

**ជំហានទី៤៖** សេចក្តីសន្និដ្ឋាន ដោយជូនដំណឹងដល់អ្នកចូលរួមថានៅក្នុងវគ្គបន្ទាប់ ពួកគេនឹងប្រើប្រាស់ព័ត៌មាននេះជាឯកសារយោងដើម្បីពង្រាងផែនការសកម្មភាព។

## ឯកសារយោងសំខាន់ៗ

### សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស

**មាត្រា ១**

មនុស្សទាំងអស់កើតមកមានសេរីភាព និងសមភាពក្នុងផ្នែកសេចក្តីថ្លៃថ្នូរ និងសិទ្ធិ។ មនុស្សមានវិចារណញ្ញាណ និងសតិសម្បជញ្ញៈជាប់ពីកំណើត ហើយគប្បីប្រព្រឹត្តចំពោះគ្នាទៅវិញទៅមកក្នុងស្មារតីភាតរភាពជាបងប្អូន។

**មាត្រា ៣**

បុគ្គលម្នាក់ៗ មានសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។

**មាត្រា ៥**

គ្មានជនណាម្នាក់ ត្រូវទទួលទារុណកម្ម ឬទណ្ឌកម្ម ឬប្រព្រឹត្តិកម្មកាចសាហាវ ឥតមនុស្សធម៌ ឬអំពីថោកទាបបានឡើយ។

**មាត្រា ៦**

មនុស្សគ្រប់រូប មានសិទ្ធិឱ្យទទួលស្គាល់ពីបុគ្គលិកលក្ខណៈគតិយុត្តរបស់ខ្លួន នៅគ្រប់ទីកន្លែង។

**មាត្រា ៧**
មនុស្សគ្រប់រូប មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិទទួលការការពារពីច្បាប់ស្មើៗគ្នា ដោយគ្មានការរើសអើង។ មនុស្សគ្រប់រូប មានសិទ្ធិទទួលបានការការពារស្មើៗគ្នាប្រឆាំងនឹងការរើសអើងណា រំលោភលើសេចក្តីប្រកាសនេះ ព្រមទាំងប្រឆាំងនឹងការញុះញង់ឱ្យមានការរើសអើង។

## ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា ៣១**
ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។

ប្រជាពលរដ្ឋខ្មែរត្រូវមានភាពស្មើគ្នាចំពោះមុខច្បាប់ ទទួលបានសិទ្ធិ និងសេរីភាព និងកាតព្វកិច្ចដូចគ្នា ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ទ្រព្យសម្បត្តិ ឬឋានៈផ្សេងទៀត។ ការអនុវត្តសិទ្ធិ និងសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលណាម្នាក់ មិនត្រូវប៉ះពាល់ដល់សិទ្ធិ និងសេរីភាពរបស់អ្នកដ៏ទៃឡើយ។ ការអនុវត្តសិទ្ធិ និងសេរីភាពនោះត្រូវអនុលោមតាមច្បាប់។

**មាត្រា ៣៨**
- ច្បាប់ហាមឃាត់មិនឱ្យមានការរំលោភបំពានលើរូបរាងកាយរបស់បុគ្គលណាមួយឡើយ។
- ច្បាប់ការពារ ជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។
- ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។
- ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តកម្មណាមួយ ដែលបន្ថែមទម្ងន់ ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវបានហាមឃាត់មិនឱ្យធ្វើឡើយ។
- អ្នកដែដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិត ត្រូវទទួលទោសតាមច្បាប់។
- ការសារភាព ដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ។
- វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។
- ជនជាប់ចោទណាក៏ដោយ ត្រូវចាត់ទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។
- ជនគ្រប់រូប មានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។

## ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សា ក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

**បទប្បញ្ញត្តិទូទៅ មាត្រា ១៖** ច្បាប់នេះមានគោលបំណងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការពារជនរងគ្រោះ និងពង្រឹងវប្បធម៌អហិង្សា និងភាពសុខដុមរមនាក្នុងគ្រួសារ ក្នុងសង្គម នៅព្រះរាជាណាចក្រកម្ពុជា។ ច្បាប់នេះមានទិសដៅបង្កើនយន្តការនីត្យានុកូល ដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការពារជនរងគ្រោះ និងរក្សាភាពសុខដុមរមនាក្នុងគ្រួសារតាមទំនៀមទម្លាប់ និងប្រពៃណីល្អរបស់ប្រទេសជាតិ និងស្របតាមមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដោយបំពេញបន្ថែមលើបទដ្ឋានគតិយុត្តជាធរមាន។

**សមត្ថកិច្ច និងនីតិវិធី មាត្រា ១០៖** ក្នុងគោលដៅទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះ មន្ត្រីនៃក្រសួងកិច្ចការនារី បម្រើការងារលើវិស័យដែលបញ្ញត្តិដោយច្បាប់នេះ ត្រូវបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងអាចធ្វើជាដើមបណ្ដឹងជួសមុខឱ្យជនរងគ្រោះស្របតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន។

**វិធានការទប់ស្កាត់ និងការការពារជនរងគ្រោះ មាត្រា ១៣៖** ដើម្បីទប់ស្កាត់អំពើហិង្សា ដែលកំពុងតែកើត ឬជឿជាក់ថាកើតឡើង អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើអន្តរាគមន៍ជាបន្ទាន់ដោយ៖

- ឃាត់ទុកអាវុធ ឬវត្ថុជាក់ស្ដែងដែលជនមុខសញ្ញាបាន ឬអាចប្រើប្រាស់។
- បង្វែរយកជនមុខសញ្ញាចេញពីកន្លែងកើតហេតុ ឬបង្វែរជនរងគ្រោះចេញពីកន្លែងកើតហេតុ បើមានការស្នើសុំពីជនរងគ្រោះ។ ក្នុងករណីពិសេស ជនរងគ្រោះអាចចេញបានដោយគ្មានការស្នើសុំ ប្រសិនបើមានហេតុផលចាំបាច់ត្រូវធ្វើ។
- ផ្ដល់ឱ្យជនរងគ្រោះនូវជំនួយសមស្របតាមកាលៈទេសៈ ជាពិសេសផ្ដល់កន្លែងជម្រកបណ្ដោះអាសន្ន ដែលអាចធានាសុវត្ថិភាព និងផ្ដល់នូវជំនួយសុខាភិបាលជាបន្ទាន់។
- ពន្យល់ អប់រំ និងសម្រុះសម្រួលគូភាគីទាំងសងខាងឱ្យបញ្ឈប់អំពើហិង្សា និងជូនណែនាំជនរងគ្រោះ អំពីសិទ្ធិរបស់ខ្លួនសម្រាប់ទប់ស្កាត់អំពើហិង្សា ដែលមានចែងក្នុងមាត្រា ២០ និងមាត្រា ២៦ នៃច្បាប់នេះ។

**ទោសប្បញ្ញត្តិ មាត្រា ៣៥៖** អំពើហិង្សាក្នុងគ្រួសារទាំងឡាយណា ដែលចូលជាបទល្មើសព្រហ្មទណ្ឌ ត្រូវផ្ដន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។ មាត្រា ៣៦៖ ការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌ ពុំអាចធ្វើបានឡើយ បើមានសំណើពីជនរងគ្រោះជានីតិជន ដោយបទល្មើសនោះជាបទមជ្ឈិមស្រាល ឬបទលហុ។ ក្នុងករណីដែលមានអំពើហិង្សាក្នុងគ្រួសារកើតឡើងជាថ្មីម្ដងទៀត ដែលល្មើសនឹងច្បាប់ព្រហ្មទណ្ឌ តុលាការត្រូវតែធ្វើការចោទប្រកាន់ជនមុខសញ្ញារូបនោះតាមនីតិវិធីព្រហ្មទណ្ឌ ទោះបីជាមានការស្នើសុំពីជនរងគ្រោះម្ដងទៀតក៏ដោយ។

នេះគឺជាវត្ថុដ៏សំខាន់មួយ ដើម្បីធ្វើឱ្យប្រាកដថា អ្នកសម្របសម្រួលមានព័ត៌មានអំពីឯកសារសម្រាប់គាំទ្រទាំងអស់ រួមទាំងក្របខ័ណ្ឌជាតិ និងអន្តរជាតិ។ រៀបចំ ឬស្រាវជ្រាវឯកសារ ឬអត្ថបទ ឬរបាយការណ៍ពាក់ព័ន្ធ ដែលចង្អុលបង្ហាញអំពីការដោះស្រាយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ឬការរើសអើងដែលជាករណីធ្ងន់ធ្ងរ។

## សកម្មភាព ៥គៈ ផែនការសកម្មភាព

**វត្ថុបំណង៖** ដើម្បីចាត់វិធានការជាក់ស្តែង ដើម្បីលើកកម្ពស់ការផ្លាស់ប្តូរឥរិយាបថលើ អំពើហិង្សាទាក់ទងនឹងយេនឌ័រ ដើម្បីគាំទ្រដល់សិទ្ធិស្ត្រីដែលនាំទៅរកយុត្តិធម៌យេនឌ័រ និងសមភាព។
**ថេរវេលាដែលត្រូវការ៖** ៤៥ នាទី។
**វិធីសាស្ត្រ៖** ការងារជាក្រុម និងការធ្វើបទបង្ហាញទៅកាន់ក្រុមធំ។
**សម្ភារៈ និងការរៀបចំ៖** ក្រដាសផ្ទាំងធំ ចំនួន៦សន្លឹកធំ ហ្វឺត ស្កុតក្រដាស និងគំរូនៃផែនការសកម្មភាព។
**អ្វីគួរធ្វើ និងអ្វីមិនគួរធ្វើ៖** ជួយសម្រួលការងារជាក្រុមយ៉ាងជិតស្និទ្ធ ប៉ុន្តែមិនណែនាំអ្នកចូលរួមអំពីវិធីដែលអ្នកចង់ឱ្យពួកគេសរសេរនោះទេ។ អនុញ្ញាតឱ្យពួកគេរៀបចំផែនការ និងធានាថាវាអាចធ្វើទៅបាន និងសមរម្យសម្រាប់ពួកគេ និងសហគមន៍របស់ពួកគេ។ សួរសំណួរប្រដេញ និងលើកទឹកចិត្តអ្នកចូលរួមពិភាក្សាពីអ្វីដែលពួកគេមានឆន្ទៈធ្វើ ទាក់ទងនឹងការផ្លាស់ប្តូរអាកប្បកិរិយាក្នុងខ្លួនពួកគេនៅក្នុងសហគមន៍ និងសហការជាមួយភាគីពាក់ព័ន្ធ ដើម្បីនាំមកនូវសមភាពយេនឌ័រ និងដោះស្រាយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

## ការណែនាំសម្រាប់អ្នកសម្របសម្រួល៖

**ជំហានទី១៖** ពន្យល់ដល់អ្នកចូលរួមថា ដើម្បីអនុវត្តការផ្លាស់ប្តូរអាកប្បកិរិយាលើអំពើហិង្សាទាក់ទងនឹងយេនឌ័រ យើងនឹងធ្វើការលើផែនការសកម្មភាព។

**ជំហានទី២៖** បែងចែកអ្នកចូលរួមជា ៣ ក្រុម។ ផ្តល់ឱ្យក្រុមនីមួយៗធ្វើការលើគំនិតផ្តួចផ្តើមនៅកម្រិតបុគ្គល សហគមន៍ និងអ្នកពាក់ព័ន្ធ (អង្គការស្ត្រី អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ និងរដ្ឋាភិបាល) នៅក្នុងតំបន់ផ្សេងៗគ្នា និងឆ្ងាយពីគ្នា។

**ជំហានទី៣៖** សុំឱ្យអ្នកចូលរួមប្រើប្រាស់ព័ត៌មានពីវគ្គ ៣ និងវគ្គ ៤ សកម្មភាពទី ១ សម្រាប់ផែនការសកម្មភាព និងព្រាងផែនការជាក់ស្តែងជាមួយនឹងសកម្មភាពដែលអាចធ្វើបានសម្រាប់កម្រិតនីមួយៗ និងពេលវេលាជាក់លាក់។

**ជំហានទី៤៖** ចែកចាយសម្ភារៈដល់ក្រុមនីមួយៗ សុំឱ្យអ្នកចូលរួមពីរនាក់ដឹកនាំការពិភាក្សា មនុស្សម្នាក់ដឹកនាំការពិភាក្សា និងមនុស្សម្នាក់កត់ត្រា បំពេញតារាងនៃផែនការសកម្មភាពដែលបានផ្តល់។[31]

ក្នុងករណីដែលអ្នកចូលរួមមិនអាចសរសេរ និងមានអារម្មណ៍មិនស្រួលក្នុងការធ្វើដូច្នេះ អ្នកសម្របសម្រួលអាចដឹកនាំការពិភាក្សា និងកត់ត្រាជំនួស។

**ជំហានទី៥៖** នៅពេលដែលក្រុមបញ្ចប់ការងារលើផែនការសកម្មភាព សុំឱ្យតំណាងក្រុមបង្ហាញលទ្ធផលទៅកាន់ក្រុមធំមួយ។ បន្ទាប់ពីក្រុមនីមួយៗធ្វើបទបង្ហាញ សូមលើកកម្ពស់ការពិភាក្សាដោយប្រើសំណួរដែលបានស្នើខាងក្រោម។

[32] តារាងផែនការសកម្មភាពដែលបានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ ៥គ-១

- តើផែនការទាំងនេះអាចសម្រេចបានសម្រាប់មនុស្សគ្រប់គ្នា ហើយតើពួកគេនឹងនាំមកនូវការផ្លាស់ប្តូរអាកប្បកិរិយានៅគ្រប់កម្រិត និងការប្តេជ្ញាចិត្តក្នុងការដោះស្រាយ អំពើហិង្សាទាក់ទងនឹងយេនឌ័រដែរឬទេ?
- តើមាននរណាម្នាក់ដែលចង់បន្ថែមសកម្មភាព បន្ថែមទៀតទៅក្នុងផែនការសកម្មភាពរបស់ក្រុមណាមួយទេ?
- តើអ្នកនឹងតាមដានវឌ្ឍនភាពដោយរបៀបណា? តើវាល្អទេក្នុងការធានាភាពជាម្ចាស់នៃផែនការជាមួយភាគីពាក់ព័ន្ធផ្សេងៗ?

**ជំហានទី៦**

**សេចក្តីសន្និដ្ឋានៈ** ចែករំលែកជាមួយអ្នកចូលរួមថាវគ្គនេះមានសារៈសំខាន់ខ្លាំងណាស់សម្រាប់បុគ្គល (ភ្នាក់ងារអ្នកផ្លាស់ប្តូរ ឬជើងឯកយេនឌ័រ) តំណាងសហគមន៍ និងអ្នកពាក់ព័ន្ធ។
ផែនការសកម្មភាពនេះនឹងណែនាំអ្នកគ្រប់គ្នាឱ្យឈានដល់ការផ្លាស់ប្តូរអាកប្បកិរិយា ប្រសិនបើវាត្រូវបានអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព។
សូមចំណាំថា តាមរយៈការអនុវត្តផែនការនេះ មិនមែនគ្រាន់តែដើម្បីគាំទ្រដល់ស្ត្រី បុរស និងមនុស្សគ្រប់រូបនៅក្នុងសហគមន៍របស់អ្នកប៉ុណ្ណោះទេ ប៉ុន្តែដើម្បីរួមចំណែកក្នុងការនាំយកនូវយន្តការការពារ និងការឆ្លើយតបដែលរួមបញ្ចូលក្នុងការដោះស្រាយ អំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ពិនិត្យជាមួយអ្នកចូលរួមប្រសិនបើពួកគេមានសំណួរ ឬត្រូវការការបកស្រាយបំភ្លឺ។

## ឧបសម្ព័ន្ធ ៥គ-១៖ គំរូផែនការសកម្មភាព៖

| កម្រិត និងផ្នែកនៃការផ្លាស់ប្តូរ | តើសកម្មភាពឬអ្វីដែលអ្នកនឹងធ្វើ ដើម្បីដោះស្រាយអំពើហិង្សាទាក់ទងនឹងយេនឌ័រ? | សូចនាករវាស់វែងអំពីការវឌ្ឍនភាព និងការផ្លាស់ប្តូរ | ពេលវេលា? | តើអ្នកត្រូវការការគាំទ្រអ្វី និងពីនរណា? |
|---|---|---|---|---|
| បុគ្គល | 1. | | | |
| | 2. | | | |
| | 3. | | | |
| សហគមន៍ | 1. | | | |
| | 2. | | | |
| | 3. | | | |
| • ភាគីពាក់ព័ន្ធ<br>• អង្គការស្ត្រី<br>• អង្គការក្រៅរដ្ឋាភិបាល<br>• អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ<br>• ម្ចាស់ជំនួយ<br>• រដ្ឋាភិបាល | | | | |
| | | | | |
| | | | | |

# ឯកសារយោង


1. Feminisms and Feminist Movements in Europe. *Digital Encyclopedia of European History.* https://ehne.fr/en/encyclopedia/themes/gender-and-europe/feminisms-and-feminist-movements/feminisms-and-feminist-movements-in-europe
2. Western Feminism. Liberation or Domination? Retrieved here
3. The third wave of feminism. *Britannica.* www.britannica.com/topic/feminism/The-third-wave-of-feminism
4. Women in Development and the world bank group. *World Bank group archives.* www.worldbank.org/en/archive/history/exhibits/Women-in-Development-and-the-World-Bank-Group
5. Gender and Development. *Wikipedia.* Retrieved here.
6. Collective definition from the six feminist organizations in Cambodia.
7. Journal of Current Southeast Asian Affaire – Social movement in Cambodia, April 2019
8. The Ministry of Women Affairs. Retrieved here
9. Gender Lens in Social & Behavior Change Guideline, UNICEF Ethiopia, 2022
10. Author's description by adapted from various training manuals and based on outcome from capacity need assessment and consultation workshop.
11. SNV SSH4A GESI Guideline, 2012
12. Adapted from training of trainer workshop manual from CARE Canada (Make it real: Gender Equality in everyday project management).
13. CARE Emergency toolkits. https://www.careemergencytoolkit.org/gender/
14. Taken from Gender Lens in Social & Behavior Change Guideline, UNICEF Ethiopia, 2022
15. This activity has been adapted from CARE International "Preventing Sexual Exploitation and Abuse Staff Training Facilitator Guide"
16. Cambridge dictionary, definition of Women's rights. Retrieved here
17. Women's rights are human rights!. *Amnesty International*. Retrieved here
18. Oxford Dictionary.
19. Feminist Perspectives on Power. *Standford encyclopedia of philosophy*. Retrieved here
20. Privilege and Intersectionality. *Rider University library.* Retrieved here
21. Adapted from CARE GED training tool kit (Introduction activity)
22. Adult learning theories: Everything you need to know. www.ispringsolutions.com/blog/adult-learning-theories
23. Facts and figures: Economic empowerment. *UN Women.* www.unwomen.org/en/what-we-do/economic-empowerment/facts-and-figures
24. Adapted from International Development Agency (Gender and Economic Tool Kit)
25. Adapted from Helvetas Laos (Women's Empowerment tool)
26. Based on definition indicated in the documents of the Royal Government of Cambodia - Neary Rattanak: Five Year Strategy (2019-2023) and UN Women - Guidance note: Women's Economic Empowerment Index (2021)
27. Cambodia National Plan of Action to Prevent Violence Against Women 2019-2023
28. Universal Declaration of Human Rights 1948
29. The Convention on the Elimination of All Forms of Discrimination against Women 1979
30. The Convention on the Rights of the Child 1989

31. ILO's convention (C190) on the rights of migrant workers, dignify work and prevention of harassment in the world of work 2019
32. Cambodian Constitutional Law 1993-2008
33. The Law on Prevention of Domestic Violence and Protection of Victims 2005
34. The Law on Suppression of Human Trafficking and Sexual Exploitation 2008
35. International & National Gender Equality and Economic Growth Frameworks (2016-2023)
36. Royal Government of Cambodia. Pentagonal Strategy 2023
37. National Financial Inclusion Strategy (2019-2025).



care®

CARE CAMBODIA ©2024

care-cambodia.org

careincambodia

carecambodia

care cambodia